ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ឆ្នាំទី ១៧ លេខ ១១ ត្រីមាសទី ០១ ឆ្នាំ ២០១៧

# រាជកិច្ច

ផ្សាយចេញពី

## ទីស្តីការគណៈរដ្ឋមន្ត្រី

សារបាន

ព្រះរាជក្រម ព្រះរាជក្រឹត្យ អនុក្រឹត្យ សេចក្តីសម្រេច សារាចរ ប្រកាស

# មាតិកា

## I~ព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រ

### ព្រះរាជក្រឹត្យ


| | | |
|---|---|---|
| ០៦-០២-២០១៧ | -ព្រះរាជក្រឹត្យ នស/រកត/០២១៧/១០៥ ស្ដីពី ការផ្ដល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្ម ដល់លោក **ស៊ុន ជៀន** (SUN JIAN) ជនជាតិចិន សញ្ជាតិចិន ដោយប្ដូរឈ្មោះជា **ស៊ុន ជឿន** (SUN CHEUN) | ១០០៦ |
| ០៦-០២-២០១៧ | -ព្រះរាជក្រឹត្យ នស/រកត/០២១៧/១០៦ ស្ដីពី ការតែងតាំងលោក **វឿន រិទ្ធិពង្ស** និងលោកស្រី **តែ កលិកា** ជា ឧកញ៉ា | ១០០៧ |
| ០៦-០២-២០១៧ | -ព្រះរាជក្រឹត្យ នស/រកត/០២១៧/១០៧ ស្ដីពី ការតែងតាំងលោក **ឡេង ហ៊ាន** ជា ឧកញ៉ា | ១០០៨ |
| ០៧-០២-២០១៧ | -ព្រះរាជក្រឹត្យ នស/រកត/០២១៧/១០៩ ស្ដីពី ការបញ្ចប់មុខតំណែងឯកឧត្តម **ឃួន ផុនរតនៈ** ពីឯកអគ្គរាជទូត វិសាមញ្ញ និងពេញសមត្ថភាព នៃព្រះរាជាណាចក្រកម្ពុជា ប្រចាំសាធារណរដ្ឋឥណ្ឌូនេស៊ី និងតែងតាំងឯកឧត្តម **ឃួន ផុនរតនៈ** ជា អនុរដ្ឋលេខាធិការ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | ១០០៩ |
| ០៧-០២-២០១៧ | -ព្រះរាជក្រឹត្យ នស/រកត/០២១៧/១១០ ស្ដីពី ការបញ្ចប់មុខតំណែងឯកឧត្តម **ហោ ណាំបូរ៉ា** ពីឯកអគ្គរាជទូត វិសាមញ្ញ និងពេញសមត្ថភាព នៃព្រះរាជាណាចក្រកម្ពុជា ប្រចាំប្រទេសស្វីស និងជាប្រធានបេសកកម្មអចិន្ត្រៃយ៍ប្រចាំការិយាល័យអង្គការសហប្រជាជាតិ និងអង្គការអន្តរជាតិនានា នៅទីក្រុងហ្សឺណែវ និងតែងតាំងឯកឧត្តម **ហោ ណាំបូរ៉ា** ជា ឯកអគ្គរាជទូត វិសាមញ្ញ និងពេញសមត្ថភាព នៃព្រះរាជាណាចក្រកម្ពុជា ប្រចាំសាធារណរដ្ឋឥណ្ឌូនេស៊ី | ១០១០ |
| ០៧-០២-២០១៧ | -ព្រះរាជក្រឹត្យ នស/រកត/០២១៧/១១១ ស្ដីពី ការបន្តអាណត្តិឯកឧត្តម **ណី សំអុល** ជា ឯកអគ្គរាជទូត វិសាមញ្ញ និងពេញសមត្ថភាព នៃព្រះរាជាណាចក្រកម្ពុជា ប្រចាំប្រទេសស្វីស និងជាប្រធានបេសកកម្មអចិន្ត្រៃយ៍ប្រចាំការិយាល័យអង្គការសហប្រជាជាតិ និងអង្គការអន្តរជាតិនានា នៅទីក្រុងហ្សឺណែវ | ១០១១ |

០៧-០២-២០១៧ -ព្រះរាជក្រឹត្យ នស/រកត/០២១៧/១១២ ស្ដីពី ការតែងតាំងមុខតំណែងឯកឧត្តម **អ៊ាត សីលា** ជាអគ្គលេខាធិការ នៃក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ បន្ថែមលើមុខងារបច្ចុប្បន្ន ១០១២

០៧-០២-២០១៧ -ព្រះរាជក្រឹត្យ នស/រកត/០២១៧/១១៣ ស្ដីពី ការលុបឈ្មោះមន្ត្រីរាជការ ០២ រូប ចេញពីក្របខ័ណ្ឌ មន្ត្រីគ្រប់គ្រងរដ្ឋបាល នៅទីស្ដីការគណៈរដ្ឋមន្ត្រី និងបញ្ចប់មុខងារ ដោយសាមីខ្លួនទទួលមរណភាព ១០១៣

០៧-០២-២០១៧ -ព្រះរាជក្រឹត្យ នស/រកត/០២១៧/១១៤ ស្ដីពី ការតែងតាំងលោក **លី អៀវ** ជា ឧកញ៉ា ១០១៤

០៧-០២-២០១៧ -ព្រះរាជក្រឹត្យ នស/រកត/០២១៧/១១៥ ស្ដីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស ជាតូបការ ចំពោះ ឧកញ៉ា **អៀង ចន្ថា** ១០១៥

០៧-០២-២០១៧ -ព្រះរាជក្រឹត្យ នស/រកត/០២១៧/១១៦ ស្ដីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា តាមលំដាប់ថ្នាក់ ចំពោះ អស់លោក និងលោកស្រី ចំនួន ២៤ រូប ១០១៦

០៧-០២-២០១៧ -ព្រះរាជក្រឹត្យ នស/រកត/០២១៧/១១៧ ស្ដីពី ការផ្ដល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្ម ដល់លោក **កូ យ៉ឿងយូ** (KO HYEONGHYO) ជនជាតិកូរ៉េ សញ្ជាតិកូរ៉េ ដោយប្ដូរឈ្មោះជា **ហ៊ុន ដារ៉ា** (HUN DARA) ១០១៧

០៧-០២-២០១៧ -ព្រះរាជក្រឹត្យ នស/រកត/០២១៧/១១៨ ស្ដីពី ការផ្ដល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្ម ដល់លោក **អូវ ឈៀវ** (OU QIAO) ជនជាតិចិន សញ្ជាតិចិន ដោយប្ដូរឈ្មោះជា **ឈិន សៀវ ឈីវ** (CHEN XIAO QIU) ១០១៨

## II~ក្រុមប្រឹក្សាធម្មនុញ្ញ

០៣-០២-២០១៧ -សេចក្ដីសម្រេចលេខ ១៧១/០១១/២០១៧ កបធ.ច ចុះថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ ២០១៧ លើសំណុំរឿងលេខ ២៩៧/០៣៥/២០១៧ ចុះថ្ងៃទី ២៥ ខែ មករា ឆ្នាំ ២០១៧ ១០១៩

០៤-០២-២០១៧ -សេចក្ដីសម្រេចលេខ ១៧២/០១២/២០១៧ កបធ.ច ចុះថ្ងៃទី ០៤ ខែ កុម្ភៈ ឆ្នាំ ២០១៧ លើសំណុំរឿងលេខ ៣០៤/០៤២/២០១៧ សំណុំរឿងលេខ ៣០៥/០៤៣/២០១៧ សំណុំរឿងលេខ ៣០៦/០៤៤/២០១៧ សំណុំរឿងលេខ ៣០៧/០៤៥/២០១៧ និងសំណុំរឿងលេខ ៣០៨/០៤៦/២០១៧ ចុះថ្ងៃទី ២៧ ខែ មករា ឆ្នាំ ២០១៧ ១០២៧

# គ

## III-រាជរដ្ឋាភិបាល

### អនុក្រឹត្យ


០៨-០២-២០១៧ -អនុក្រឹត្យលេខ ១៨ អនក្រ.បក ស្តីពី ការបង្កើតយន្តការច្រកចេញចូលតែមួយ សម្រាប់ការផ្តល់សេវារដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ១០៣៧

០៧-០២-២០១៧ -អនុក្រឹត្យលេខ ១១៥ អនក្រ.តត ស្តីពី ការជូនមេដាយមុនីសារាភ័ណ្ឌ ១០៦២

០៧-០២-២០១៧ -អនុក្រឹត្យលេខ ១១៦ អនក្រ.តត ស្តីពី ការជូនមេដាយការងារ ១០៦៤

០៧-០២-២០១៧ -អនុក្រឹត្យលេខ ១១៧ អនក្រ.តត ស្តីពី ការជូនមេដាយសុវត្ថារា ១០៦៧

០៨-០២-២០១៧ -អនុក្រឹត្យលេខ ១១៨ អនក្រ.តត ស្តីពី ការជូនមេដាយមុនីសារាភ័ណ្ឌ ១០៦៨

០៨-០២-២០១៧ -អនុក្រឹត្យលេខ ១១៩ អនក្រ.តត ស្តីពី ការជូនមេដាយ ១០៦៩

០៨-០២-២០១៧ -អនុក្រឹត្យលេខ ១២០ អនក្រ.តត ស្តីពី ការជូនមេដាយ ១០៧០

០៨-០២-២០១៧ -អនុក្រឹត្យលេខ ១២១ អនក្រ.តត ស្តីពី ការតែងតាំងមន្ត្រីរាជការ ១០៧២

០៨-០២-២០១៧ -អនុក្រឹត្យលេខ ១២២ អនក្រ.តត ស្តីពី ការតែងតាំងមន្ត្រីរាជការ ១០៧៣

០៨-០២-២០១៧ -អនុក្រឹត្យលេខ ១២៣ អនក្រ.តត ស្តីពី ការជូនមេដាយការងារ ១០៧៤

០៨-០២-២០១៧ -អនុក្រឹត្យលេខ ១២៤ អនក្រ.តត ស្តីពី ការជូនមេដាយការងារ ១០៧៦

០៨-០២-២០១៧ -អនុក្រឹត្យលេខ ១២៥ អនក្រ.តត ស្តីពី ការជូនមេដាយការងារ ១០៧៩


## IV-ការងារបណ្តាក្រសួង

### ទីស្តីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ


០៣-០២-២០១៧ -លិខិតលេខ ៦៥០ សហវ.អសប ស្តីពី ការផ្សព្វផ្សាយ "ឯកសារគោលនយោបាយ ស្តីពីការអភិវឌ្ឍយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន(PPP) សម្រាប់គ្រប់គ្រងគម្រោងវិនិយោគសាធារណៈ ២០១៦-២០២០" *តទៅ រាជកិច្ចលេខ ១២* ១០៨១

# ព្រះរាជក្រឹត្យ

នស/រកត/០២១៧/ ១០៥

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស / រកត / ០៩១៣ / ៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស / រកម / ១០៩៦ / ៣០ ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** ផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក **ស៊ុន ជៀន** (SUN JIAN) ជនជាតិចិន សញ្ជាតិចិន កើតថ្ងៃទី១៣ ខែមេសា ឆ្នាំ១៩៧២ នៅខេត្តជាំងស៊ូ សាធារណរដ្ឋប្រជាមានិតចិន ដោយប្តូរឈ្មោះជា **ស៊ុន ជឿន** (SUN CHEUN)។

**មាត្រា ២ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ចករ**
**នរោត្តម សីហមុនី**

ការៈ ១៧/០២.១០៧

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០១៧*

លេខ: ១៤៤ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ,ថ្ងៃទី ០៩ ខែ កុម្ភៈ ឆ្នាំ២០១៧
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០២១៧/ ១០៦

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

( យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយរបស់ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា )

**ត្រាស់បង្គាប់**

**តែងតាំង :**

**លោក រឿន រិទ្ធីពង្ស**
**លោកស្រី តែ កលិកា**

**ជា**

**ឧកញ៉ា**

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣រស. ១៧០២.១០៧

លេខៈ ១០៧ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ កុម្ភៈ ឆ្នាំ២០១៧
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ស៊ុយ សុខា**

*ធ្វើនៅព្រះបរមរាជវាំង,ថ្ងៃទី ០៦ ខែ កុម្ភៈ ឆ្នាំ ២០១៧*

# ព្រះរាជក្រឹត្យ

នស/រកត/០២១៧/ ១០៧

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

( យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយរបស់ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា )

**ត្រាស់បង្គាប់**

**តែងតាំង :**

**លោក ឡេង ហ៊ាន**

**ជា**

**ឧកញ៉ា**

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

ពរក. ១៧០២.១០៩

*ធ្វើនៅព្រះបរមរាជវាំង,ថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០១៧*

លេខ:១០៦ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ,ថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ២០១៧
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ស៊យ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០២១៧/ ១០៩

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សម្ហោរភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី ០៤ ខែ មេសា ឆ្នាំ ២០១៦ ស្តីពីការបញ្ចប់មុខងារ និងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៤០១/០៨៥ ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីការទូតជាន់ខ្ពស់
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** បញ្ចប់មុខតំណែងឯកឧត្តម **ឃួន ផុនរតនៈ** ពី ឯកអគ្គរាជទូត វិសាមញ្ញ និងពេញសមត្ថភាព នៃព្រះរាជាណាចក្រកម្ពុជាប្រចាំសាធារណរដ្ឋឥណ្ឌូនេស៊ី ។

**មាត្រា ២ :** តែងតាំងឯកឧត្តម **ឃួន ផុនរតនៈ** ជា **អនុរដ្ឋលេខាធិការ** ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ។

**មាត្រា ៣ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

*ការ៧.១៧០៤.១១១*

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ២០១៧*

លេខៈ ១០០ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ .ថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ២០១៧
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ស៊យ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០២១៧/១១០

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានត្ថមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី ០៤ ខែ មេសា ឆ្នាំ ២០១៦ ស្តីពីការបញ្ចប់មុខងារ និងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៤០១/០៨៥ ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីការទូតជាន់ខ្ពស់
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១** : បញ្ចប់មុខតំណែងឯកឧត្តម **ហោ ណាំបូរ៉ា** ពី ឯកអគ្គរាជទូត វិសាមញ្ញ និងពេញសមត្ថភាព នៃព្រះរាជាណាចក្រកម្ពុជាប្រចាំប្រទេសស្វីស និងជាប្រធានបេសកកម្មអចិន្ត្រៃយ៍ប្រចាំការិយាល័យ អង្គការសហប្រជាជាតិ និងអង្គការអន្តរជាតិនានា នៅទីក្រុងហ្សឺណែវ ។

**មាត្រា ២** : តែងតាំងមុខតំណែងឯកឧត្តម **ហោ ណាំបូរ៉ា** ជា ឯកអគ្គរាជទូត វិសាមញ្ញ និងពេញសមត្ថភាព នៃព្រះរាជាណាចក្រកម្ពុជាប្រចាំសាធារណរដ្ឋឥណ្ឌូនេស៊ី ។

**មាត្រា ៣** : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

*ពរ៧.១៧០២.១១២*

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ២០១៧*

លេខ: ៩១ ស.ណ
**សំណៅចំលងចេញតាមច្បាប់ដើម**
រាជធានីភ្នំពេញ .ថ្ងៃទី ០៩ ខែ កុម្ភៈ ឆ្នាំ២០១៧
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ស៊យ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០២១៧/១១១

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី ០៤ ខែ មេសា ឆ្នាំ ២០១៦ ស្តីពីការបញ្ចប់មុខងារ និងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៤០១/០៨៥ ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីការទូតជាន់ខ្ពស់
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១** : បន្តអាណត្តិឯកឧត្តម **ណី សំអុល** ជា ឯកអគ្គរាជទូត វិសាមញ្ញ និងពេញសមត្ថភាព នៃព្រះរាជាណាចក្រកម្ពុជាប្រចាំប្រទេសស្វីស និងជាប្រធានបេសកកម្មអចិន្ត្រៃយ៍ប្រចាំការិយាល័យអង្គការសហប្រជាជាតិ និងអង្គការអន្តរជាតិនានា នៅទីក្រុងហ្សឺណែវ ហូតដល់ **ដំណាច់ខែសីហា ឆ្នាំ២០១៨ ។**

**មាត្រា ២** : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

ការ.៧.១៧០៤.១១៣

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ២០១៧*

លេខៈ ១០៧ ស.ណ
**សំណៅចំលងដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ .ថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ២០១៧
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ស៊យ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០២១៧/១១៤

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការបញ្ចប់មុខងារ និងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១០ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៤០១/០៨៥ ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីការទូតជាន់ខ្ពស់
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

**ត្រាស់បង្គាប់**

**មាត្រា ១** : តែងតាំងមុខតំណែងឯកឧត្តម **អ៊ិត សីលា** ជា **អគ្គលេខាធិការ** នៃក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ បន្ថែមលើមុខងារបច្ចុប្បន្ន ។

**មាត្រា ២** : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

ពរស. ១៧០៤-១១៤

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ២០១៧

លេខៈ ១០៣ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ,ថ្ងៃទី ០៦ ខែកុម្ភៈ ឆ្នាំ២០១៧
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០២១៧/ ១១៧

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

**ត្រាស់បង្គាប់**

**មាត្រា១** : លុបឈ្មោះមន្ត្រីរាជការ ០២រូប ចេញពីក្របខណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល នៅទីស្តីការគណៈរដ្ឋមន្ត្រី និងបញ្ចប់មុខងារ ដោយសាមីខ្លួនទទួលមរណភាព ៖

១. ឯកឧត្តម **គង់ ថៃ** ឧត្តមមន្ត្រីថ្នាក់លេខ១ សមាជិកក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌
២. ឯកឧត្តម **ខៀវ ថវិកា** ឧត្តមមន្ត្រីថ្នាក់លេខ២ ទីប្រឹក្សារាជរដ្ឋាភិបាល។

**មាត្រា២** : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

លេខៈ ១០៧ ស.ណ

**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ កុម្ភៈ ឆ្នាំ២០១៧
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

*ពរ.៧.១៧០២.១១៥*

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ២០១៧*

# ព្រះរាជក្រឹត្យ

នស/រកត/០២១៧/១១៤

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

( យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន**
នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា )

ត្រាស់បង្គាប់

**តែងតាំង :**

លោក លី អៀច

ជា

ឧកញ៉ា

**ព្រះហស្តលេខា និងព្រះរាជលញ្ជករ**
**នរោត្តម សីហមុនី**

លេខៈ ១០៥ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ .ថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០១៧
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

ពរល. ១៧០២ - ១១៦

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ២០១៧*

# ព្រះរាជក្រឹត្យ

នស/រកត/០២១៧/ ១១៥

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សម្ពោហ៍ភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

( យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន**
នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា )

**ប្រោសព្រះរាជទាន**

**នូវ**

គ្រឿងឥស្សរិយយស **ជាតូបការ**

ចំពោះ

ឧកញ៉ា **អៀង ចន្ថា**

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣៧៧ . ១៧០៥ . ១១៧

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ២០១៧

លេខ: ១០៤ ស.ណ

**សំណៅចំលងមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ,ថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ២០១៧
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០២១៧/១១៦

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សម្ហោរតាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

( យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន**
នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា )

**ប្រោសព្រះរាជទាន**
**ដូចៈ**

**ក- គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេរីវឌ្ឍន៍ :**

១-លោក **ចុង ផែត** ២-លោក **ចាន់ សារ៉ា**

**ខ- គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេនា :**

១-លោក **ឡោ ម៉ុនពេជ្រ** ២-លោក **ង៉ែ កេងលី**

**គ- គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេនា :**

១-លោក **ឈឿន គ្រៃយ៉ុង** ៣-លោកស្រី **សៀង សិនេហ៍**
២-លោក **សរ សំណាង**

**ឃ- គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ ធិបឌិន្ទ :**

១-លោក **ខាត់ សារ៉ាន** ៣-លោក **ឈឹន សុរិយា**
២-លោក **រដ្ឋ សុខា**

**ង- គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ សេនា :**

១-លោក **ហោ ញ៉ៀប** ៤-លោក **កេត ចណ្ណស៊ីន**
២-លោក **កែម តារារស្មី** ៥-លោក **នូ យ៉េត**
៣-លោក **ណាង ចន្ធី**

**ច- គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ អស្សឫទ្ធិ :**

១-លោក **ម៉ន ចណ្ណា** ៣-លោក **រឿង សាខយ**
២-លោក **ឈុន ម៉ុនថា** ៤-លោក **ពេជ្រ ដារូ**
៥-លោក **ទិ ទ៉ា** ៨-លោក **ត្រឿង រ៉េត**
៦-លោក **ខែន រិទ្ធី** ៩-លោក **មាស សំណាង**
៧-លោក **ថ្លាង ឡៀង**

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣រ៧. ១៧០៤. ១១៧

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ២០១៧*

លេខៈ ១០៧ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ២០១៧
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ស៊យ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០២១៧/១១៧

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្រ្ទាធរាមហាក្សត្រ**
**ខេមរាជនា សម្ហោហនាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

**ត្រាស់បង្គាប់**

**មាត្រា ១ :** ផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក **កូ ហៀងយូ** (KO HYEONGHYO) ជនជាតិកូរ៉េ សញ្ជាតិកូរ៉េ កើតថ្ងៃទី១០ ខែមករា ឆ្នាំ១៩៧៤ នៅខេត្តជៀលឡាណាម សាធារណរដ្ឋកូរ៉េ ដោយប្តូរឈ្មោះជា **ហ៊ុន ដារ៉ា** (HUN DARA)។

**មាត្រា ២ :** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣៧.១៧០២.១១៩

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ ២០១៧*

លេខៈ ១២១ ស.ណ
**សំណៅចែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ កុម្ភៈ ឆ្នាំ២០១៧
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០២១៧/១១៨

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានត្ថមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស / រកត / ០៩១៣ / ៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស / រកម / ១០៩៦ / ៣០ ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** ផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក **អូវ ឈៅ** (OU QIAO) ជនជាតិចិន សញ្ជាតិចិន កើតថ្ងៃទី២៩ ខែធ្នូ ឆ្នាំ១៩៨៥ នៅខេត្តហ្វូជៀន សាធារណរដ្ឋប្រជាមានិតចិន ដោយប្តូរឈ្មោះជា **ឈិន សៅ ឈីវ** (CHEN XIAO QIU)។

**មាត្រា ២ :** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

ករល-១៧០២-១២០

លេខៈ ១១៩ ស.ណ

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ២០១៧*

**សំណៅចែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ,ថ្ងៃទី ០៩ ខែ កុម្ភៈ ឆ្នាំ២០១៧
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ស៊យ សុខា**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមប្រឹក្សាធម្មនុញ្ញ**

**សំណុំរឿង**
- លេខ : ២៩៧/០៣៥/២០១៧
ចុះថ្ងៃទី ២៥ ខែ មករា ឆ្នាំ២០១៧

**សេចក្តីសម្រេច**
លេខ : ១៧១/០១១/២០១៧ កបធ.ច
ចុះថ្ងៃទី០៣ ខែ កុម្ភៈ ឆ្នាំ២០១៧

# ក្រុមប្រឹក្សាធម្មនុញ្ញ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ២០០៧ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣១៥/០០៣ ចុះថ្ងៃទី ២៦ ខែ មីនា ឆ្នាំ២០១៥ ប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញសេចក្តីសម្រេចលេខ ០៦៧ ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ២០១៧ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដែលតម្កល់សេចក្តីសម្រេចលេខ ០១/១៧ ចុះថ្ងៃទី ១២ ខែ មករា ឆ្នាំ២០១៧ របស់ក្រុមប្រឹក្សាប្រជុំសម្រេចសង្កាត់រការធំ ទុកជាបានការពេញទាំងមូល
- បានឃើញសេចក្តីសម្រេចលេខ ០៩៦ ចុះថ្ងៃទី ២១ ខែ មករា ឆ្នាំ២០១៧ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដែលតម្កល់សេចក្តីសម្រេចលេខ ០២/១៧ ចុះថ្ងៃទី ១២ ខែ មករា ឆ្នាំ២០១៧ របស់ក្រុមប្រឹក្សាប្រជុំសម្រេចឃុំសុព័រទេព ទុកជាបានការពេញទាំងមូល

អាគារស វិមានរដ្ឋចំការមន មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខ័ណ្ឌចំការមន ភ្នំពេញ
ទូរស័ព្ទ / ទូរសារ : (៨៥៥) ២៣ ៧២០ ៩១៣. E-mail: sgcc@camnet.com.kh/ info@ccc.gov.kh, Website :http://www.ccc.gov.kh

- បានឃើញសេចក្ដីសម្រេចលេខ ០៩៨ ចុះថ្ងៃទី ២១ ខែ មករា ឆ្នាំ២០១៧ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដែលតម្កល់សេចក្ដីសម្រេចលេខ ០១/១៧ ស.ប.ស.ស.រ ចុះថ្ងៃទី ១២ ខែ មករា ឆ្នាំ២០១៧ របស់ក្រុមប្រឹក្សាប្រជុំសម្រេចសង្កាត់រការធំ ទុកជាបានការពេញទាំងមូល
- បានឃើញសេចក្ដីសម្រេចលេខ ១០០ ចុះថ្ងៃទី ២១ ខែ មករា ឆ្នាំ២០១៧ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដែលតម្កល់សេចក្ដីសម្រេចលេខ ០០៣/១៧ ចុះថ្ងៃទី ១២ ខែ មករា ឆ្នាំ២០១៧ របស់ក្រុមប្រឹក្សាសង្កាត់សុព័រទេព ទុកជាបានការពេញទាំងមូល
- បានឃើញសេចក្ដីសម្រេចលេខ ១០១ ចុះថ្ងៃទី ២១ ខែ មករា ឆ្នាំ២០១៧ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដែលតម្កល់សេចក្ដីសម្រេចលេខ ០០១/១៧ ចុះថ្ងៃទី ១២ ខែ មករា ឆ្នាំ២០១៧ របស់ក្រុមប្រឹក្សាសង្កាត់សុព័រទេព ទុកជាបានការពេញទាំងមូល
- បានឃើញសេចក្ដីសម្រេចលេខ ១០២ ចុះថ្ងៃទី ២១ ខែ មករា ឆ្នាំ២០១៧ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដែលតម្កល់សេចក្ដីសម្រេចលេខ ០១/១៧ ស.ប.ស.ស.រ ចុះថ្ងៃទី ១២ ខែ មករា ឆ្នាំ២០១៧ របស់ក្រុមប្រឹក្សាសង្កាត់រការធំ ទុកជាបានការពេញទាំងមូល
- បានឃើញសេចក្ដីសម្រេចលេខ ១២៨ ចុះថ្ងៃទី ២២ ខែ មករា ឆ្នាំ២០១៧ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត បដិសេធសេចក្ដីសម្រេចលេខ ០០១/១៧ ចុះថ្ងៃទី ១៤ ខែ មករា ឆ្នាំ២០១៧ របស់ក្រុមប្រឹក្សាប្រជុំសម្រេចសង្កាត់រការធំ ខេត្តកំពង់ស្ពឺ ចោលជាអសារបង់ ដែលរក្សាទុកឈ្មោះ **ជួន ចាន់ថា** ក្នុងបញ្ជីបោះឆ្នោតនៃសង្កាត់រការធំ ខេត្តកំពង់ស្ពឺ
- បានឃើញសេចក្ដីសម្រេចលេខ ១២៩ ចុះថ្ងៃទី ២២ ខែ មករា ឆ្នាំ២០១៧ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត បដិសេធសេចក្ដីសម្រេចលេខ ០០១/១៧ ចុះថ្ងៃទី ១៤ ខែ មករា ឆ្នាំ២០១៧ របស់ក្រុមប្រឹក្សាប្រជុំសម្រេចសង្កាត់រការធំ ខេត្តកំពង់ស្ពឺ ចោលជាអសារបង់ ដែលរក្សាទុកឈ្មោះ **ខួន ឈឿន** ក្នុងបញ្ជីបោះឆ្នោតនៃសង្កាត់រការធំ ខេត្តកំពង់ស្ពឺ
- បានឃើញសេចក្ដីសម្រេចលេខ ១៣០ ចុះថ្ងៃទី ២២ ខែ មករា ឆ្នាំ២០១៧ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដែលបដិសេធសេចក្ដីសម្រេចលេខ ០០១/១៧ ចុះថ្ងៃទី ១៣ ខែ មករា ឆ្នាំ២០១៧ របស់ក្រុមប្រឹក្សាសង្កាត់រការធំ ខេត្តកំពង់ស្ពឺ ចោលជាអសារបង់ ដែលរក្សាទុកឈ្មោះ **ជា គីមឆាទ** ក្នុងបញ្ជីបោះឆ្នោតនៃសង្កាត់រការធំ ខេត្តកំពង់ស្ពឺ
- បានឃើញលិខិតផ្ទេរសិទ្ធិ ចុះថ្ងៃទី ២៥ ខែ មករា ឆ្នាំ២០១៧ របស់លោក **ម៉ក់ ហាន** ជូនលោកស្រីមេធាវី **ម៉េង សុតារី** ក្នុងការដាក់ពាក្យប្ដឹងជំទាស់នឹងសេចក្ដីសម្រេចលេខ ០៦៧ ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ២០១៧ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- បានឃើញលិខិតផ្ទេរសិទ្ធិ ចុះថ្ងៃទី ២៥ ខែ មករា ឆ្នាំ២០១៧ របស់លោក **ឆុយ សុគ័ណ្ណ** ជូនលោកស្រីមេធាវី **ម៉េង សុតារី** ក្នុងការដាក់ពាក្យប្ដឹងជំទាស់នឹងសេចក្ដីសម្រេចលេខ០៩៦ លេខ១០០ និងលេខ១០១ ចុះថ្ងៃទី ២២ ខែ មករា ឆ្នាំ២០១៧ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

- បានឃើញលិខិតផ្ទេរសិទ្ធិ ចុះថ្ងៃទី ២៥ ខែ មករា ឆ្នាំ២០១៧ របស់លោក **ម៉ក់ ហាន** ជូនលោកស្រីមេធាវី **ម៉េង សុភារី** ក្នុងការដាក់ពាក្យប្តឹងជំទាស់នឹងសេចក្តីសម្រេចលេខ០៩៨ និងលេខ ១០២ ចុះថ្ងៃទី ២១ ខែ មករា ឆ្នាំ២០១៧ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- បានឃើញលិខិតផ្ទេរសិទ្ធិ ចុះថ្ងៃទី ២៥ ខែ មករា ឆ្នាំ២០១៧ របស់លោក **ម៉ក់ ហាន** ជូនលោកស្រីមេធាវី **ម៉េង សុភារី** ក្នុងការដាក់ពាក្យប្តឹងជំទាស់នឹងសេចក្តីសម្រេចលេខ១២៨ លេខ១២៩ និងលេខ១៣០ ចុះថ្ងៃទី ២២ ខែ មករា ឆ្នាំ២០១៧ របស់គណៈកម្មការជាតិរៀបចំការបោះឆ្នោត
- បានឃើញលិខិតលេខ១២៣ គ.ជ.ប ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ២០១៧ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ឧទ្ទេសនាមឯកឧត្តម **កែវ ផល្លា** និងលោក **ហួត បូរិន** ដើម្បីមកបំភ្លឺលើពាក្យបណ្តឹងរបស់លោកស្រីមេធាវី **ម៉េង សុភារី**
- បានឃើញពាក្យបណ្តឹងចុះថ្ងៃទី ២៦ ខែ មករា ឆ្នាំ២០១៧ របស់លោកស្រីមេធាវី **ម៉េង សុភារី** តំណាងឲ្យលោក **នុយ សុត័ណ្ឌ** និងលោក **ម៉ក់ ហាន** ប្តឹងជំទាស់នឹងសេចក្តីសម្រេចលេខ០៦៧ ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ២០១៧ លេខ០៩៦ លេខ០៩៨ លេខ១០០ លេខ១០១ និងលេខ១០២ ចុះថ្ងៃទី ២១ ខែ មករា ឆ្នាំ២០១៧ លេខ១២៨ លេខ១២៩ និងលេខ១៣០ ចុះថ្ងៃទី ២២ ខែ មករា ឆ្នាំ២០១៧ របស់គណៈកម្មការជាតិរៀបចំការបោះឆ្នោត
- បានឃើញកំណត់ហេតុឆ្លើយបំភ្លឺរបស់លោកស្រីមេធាវី **ម៉េង សុភារី** កាលពីថ្ងៃទី ០២ ខែ មករា ឆ្នាំ២០១៧ ចំពោះមុខក្រុមទី១ នៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញកំណត់ហេតុបំភ្លឺរបស់ឯកឧត្តម **កែវ ផល្លា** តំណាងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ចំពោះមុខក្រុមទី១ នៃក្រុមប្រឹក្សាធម្មនុញ្ញ កាលពីថ្ងៃទី ០២ ខែ មករា ឆ្នាំ២០១៧ ដោយភ្ជាប់សារណាចំនួន០៣ច្បាប់ ចុះថ្ងៃទី ០២ ខែ កុម្ភៈ ឆ្នាំ២០១៧ និងឯកសារពាក់ព័ន្ធនឹងប្រជាពលរដ្ឋចំនួន ០៩ នាក់ ដែលត្រូវបានប្តឹងថាជាជនជាតិបរទេស
- បានឃើញកំណត់ហេតុចុះស៊ើបអង្កេតនៅសង្កាត់សុព័រទេព និងសង្កាត់រការធំ ក្រុងច្បារមន ខេត្តកំពង់ស្ពឺ របស់មន្ត្រីជំនាញនៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ ចុះថ្ងៃទី ២៩ ខែ មករា ឆ្នាំ២០១៧។

**ក្រោយពីបានស្តាប់របាយការណ៍របស់សមាជិករាយការណ៍**

**ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ**

- យល់ឃើញថា បណ្តឹងចុះថ្ងៃទី ២៦ ខែ មករា ឆ្នាំ២០១៧ របស់លោកស្រីមេធាវី **ម៉េង សុភារី** ស្ថិតក្នុងដំណាក់កាលបិទផ្សាយបញ្ជីបោះឆ្នោតដំបូង។ យោងតាមមាត្រា ៦២ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងមាត្រា ២៦ ចំណុចទី៣ នៃច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្ត

ទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ បណ្តឹងនេះធ្វើឡើងត្រឹមត្រូវតាមទម្រង់ច្បាប់ ដូច្នេះក្រុមប្រឹក្សាធម្មនុញ្ញអាចទទួលយកមកពិនិត្យបាន

- យល់ឃើញថា នៅពេលឆ្លើយបំភ្លឺនៅចំពោះមុខក្រុមទី១ នៃក្រុមប្រឹក្សាធម្មនុញ្ញ លោកស្រីមេធាវី **ម៉េង សុភារី** បានបញ្ជាក់ដូចតទៅ :
  - លោកស្រីមេធាវី **ម៉េង សុភារី** ជាតំណាងឲ្យដើមបណ្តឹងលោក **ឆុយ សុភ័ណ្ឌ** និងលោក **ម៉ត់ ហាន** ប្តឹងជំទាស់នឹងសេចក្តីសម្រេចលេខ០៦៧ ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ២០១៧ លេខ០៩៦ លេខ០៩៨ លេខ១០០ លេខ១០១ និងលេខ១០២ ចុះថ្ងៃទី ២១ ខែ មករា ឆ្នាំ២០១៧ លេខ១២៨ លេខ១២៩ និងលេខ១៣០ ចុះថ្ងៃទី ២២ ខែ មករា ឆ្នាំ២០១៧ របស់គណៈកម្មការជាតិរៀបចំការបោះឆ្នោត។
  - លោកស្រីមេធាវី **ម៉េង សុភារី** មិនស្គាល់អត្តសញ្ញាណប្រជាពលរដ្ឋទាំងនោះទេ ប៉ុន្តែកូនក្តីរបស់លោកស្រីដែលរស់នៅក្នុងសង្កាត់ជាមួយគ្នាគាត់ស្គាល់ច្បាស់ថា ប្រជាពលរដ្ឋទាំងនោះពិតជាជនជាតិវៀតណាម។
  - លោកស្រីមេធាវី **ម៉េង សុភារី** ពុំមានភស្តុតាងអ្វីផ្សេងទៀតទេ តែបើអាចអញ្ជើញប្រជាពលរដ្ឋទាំងនោះមកសួរផ្ទាល់ ទើបអាចយល់ថា ពួកគាត់ជាជនជាតិបរទេស ទោះបីជាពួកគាត់មានអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរក៏ដោយ។
  - លោកស្រីមេធាវី **ម៉េង សុភារី** សំណូមពរសូមឱ្យស្ថាប័នដោះស្រាយវិវាទទាក់ទងនឹងការចុះឈ្មោះបោះឆ្នោតពិនិត្យលើលក្ខខណ្ឌសញ្ជាតិដែលទាក់ទងដល់ការផ្តល់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ។

- យល់ឃើញថា នៅពេលបំភ្លឺចំពោះមុខក្រុមទី១ នៃក្រុមប្រឹក្សាធម្មនុញ្ញ ឯកឧត្តម **គែច ផល្លា** តំណាងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតបានបញ្ជាក់ ដូចតទៅ ៖
  - ខ្លឹមសារបណ្តឹងដែលលោកស្រីមេធាវី **ម៉េង សុភារី** ប្តឹង មានខ្លឹមសារដូចគ្នាទាំងអស់។ គាត់ថា ប្រជាពលរដ្ឋទាំងនោះជាជនបរទេស ហើយមានអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរទៅចុះឈ្មោះបោះឆ្នោត ប៉ុន្តែគាត់ថាការទទួលបានអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែររបស់ប្រជាពលរដ្ឋទាំងនោះ មិនត្រឹមត្រូវ។
  - ការសម្រេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត គឺផ្អែកលើច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ មាត្រា ៤៦ និងមាត្រា ៥១ និងប្រការ ៤.៤ នៃបទបញ្ជា និងនីតិវិធីសម្រាប់ការចុះឈ្មោះបោះឆ្នោត។ បើអ្នកចុះឈ្មោះមានអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ គឺក្រុមចុះឈ្មោះនឹងចុះឈ្មោះជូន។

- តាមការចុះស្រាវជ្រាវរបស់មន្ត្រីជំនាញ នៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតឃើញថា ក្នុងចំណោមប្រជាពលរដ្ឋ ០៩នាក់ ដែលមានឈ្មោះក្នុងបណ្តឹង មាន០៨នាក់ ប្រើអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ និង ០១នាក់ ប្រើ ឯកសារបញ្ជាក់អត្តសញ្ញាណ។
- ចំពោះបញ្ហាស្វែងរកភាពត្រឹមត្រូវនៃការទទួលបានអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ នេះមិនមែនជាសមត្ថកិច្ចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតទេ។
- គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត បានជូនសារណាចំនួន ០៣ច្បាប់ និងឯកសារពាក់ព័ន្ធនឹងបណ្តឹងទាំងប្រាំបួននេះ។
- គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត សំណូមពរនៅពេលមានសវនាការជាសាធារណៈ សូមកុំឱ្យគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតមកក្នុងនាមជាចុងចម្លើយ និងសូមឱ្យក្រុមប្រឹក្សាធម្មនុញ្ញ តម្កល់សេចក្តីសម្រេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតទាំងប្រាំបួន ទុកជាបានការ។

- យល់ឃើញថា លោកស្រីមេធាវី **ម៉េង សុភារី** ជាតំណាងឲ្យដើមបណ្តឹងលោក **ឆុយ សុគ័ណ្ឌា** និងលោក **ម៉ក់ ហាន** ប្តឹងជំទាស់នឹងសេចក្តីសម្រេចលេខ០៦៧ ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ២០១៧ លេខ០៩៦ លេខ០៩៨ លេខ១០០ លេខ១០១ និងលេខ១០២ ចុះថ្ងៃទី ២១ ខែ មករា ឆ្នាំ២០១៧ លេខ១២៨ លេខ១២៩ និងលេខ១៣០ ចុះថ្ងៃទី ២២ ខែ មករា ឆ្នាំ២០១៧ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ក្នុងការសុំលុបឈ្មោះជនជាតិបរទេស ពុំមានឯកសារ ឬភស្តុតាងជាលាយលក្ខណ៍អក្សរ ដែលអាចឲ្យក្រុមប្រឹក្សាធម្មនុញ្ញបដិសេធសេចក្តីសម្រេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតទាំងប្រាំបួននេះបានឡើយ
- យល់ឃើញថា តាមការចុះស៊ើបអង្កេតរបស់មន្ត្រីជំនាញនៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ ប្រជាពលរដ្ឋដែលត្រូវលោកស្រីមេធាវី **ម៉េង សុភារី** ប្តឹង សុទ្ធតែបានបំពេញលក្ខខណ្ឌចុះឈ្មោះបោះឆ្នោត គ្រប់គ្រាន់តាមច្បាប់ បទបញ្ជា និងនីតិវិធីចុះឈ្មោះបោះឆ្នោត
- យល់ឃើញថា សេចក្តីសម្រេចលេខ០៦៧ ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ២០១៧ លេខ០៩៦ លេខ០៩៨ លេខ១០០ លេខ១០១ និងលេខ១០២ ចុះថ្ងៃទី ២១ ខែ មករា ឆ្នាំ២០១៧ លេខ១២៨ លេខ១២៩ និងលេខ១៣០ ចុះថ្ងៃទី ២២ ខែ មករា ឆ្នាំ២០១៧ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតមានមូលដ្ឋានគតិយុត្តត្រឹមត្រូវ
- យល់ឃើញថា ការបញ្ជាក់អំពីធាតុពិតនៃអត្តសញ្ញាណរបស់បុគ្គលណាម្នាក់ មិនមែនជាសមត្ថកិច្ចរបស់ក្រុមប្រឹក្សាធម្មនុញ្ញទេ ។

## សម្រេច

**មាត្រា ១.-** ទទួលពាក្យបណ្តឹងចុះថ្ងៃទី ២៦ ខែ មករា ឆ្នាំ២០១៧ របស់លោកស្រីមេធាវី **ម៉េង សុភារី** ជាតំណាងឲ្យដើមបណ្តឹងលោក **ឆុយ សុភ័ណ្ឌ** និងលោក **ម៉ក់ ហន** ភ្នាក់ងារគណបក្សសង្គ្រោះជាតិ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយខុសនឹងគតិច្បាប់ ។

**មាត្រា ២.-** តម្កល់សេចក្តីសម្រេចលេខ០៦៧ ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ២០១៧ លេខ០៩៦ ចុះថ្ងៃទី ២១ ខែ មករា ឆ្នាំ២០១៧ លេខ០៩៨ ចុះថ្ងៃទី ២១ ខែ មករា ឆ្នាំ២០១៧ លេខ១០០ ចុះថ្ងៃទី ២១ ខែ មករា ឆ្នាំ២០១៧ លេខ១០១ ចុះថ្ងៃទី ២១ ខែ មករា ឆ្នាំ២០១៧ លេខ១០២ ចុះថ្ងៃទី ២១ ខែ មករា ឆ្នាំ២០១៧ លេខ១២៨ ចុះថ្ងៃទី ២២ ខែ មករា ឆ្នាំ២០១៧ លេខ១២៩ ចុះថ្ងៃទី ២២ ខែ មករា ឆ្នាំ២០១៧ និងលេខ១៣០ ចុះថ្ងៃទី ២២ ខែ មករា ឆ្នាំ២០១៧ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ទុកជាបានការពេញទាំងមូល ។

**មាត្រា ៣.-** សេចក្តីសម្រេចនេះ ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ២០១៧ ក្នុងកិច្ចប្រជុំពេញអង្គនៃក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្តីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និង ត្រូវចុះផ្សាយក្នុងរាជកិច្ច។

រាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ២០១៧

ជ.ក្រុមប្រឹក្សាធម្មនុញ្ញ

ប្រធាន

**អ៊ឹម ឈុនលឹម**

ក្រុមប្រឹក្សាធម្មនុញ្ញ
ចូល
លេខ. [illegible]
ថ្ងៃ. [illegible]
បញ្ជាត. [illegible]

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

..............................

## ពាក្យបណ្តឹង

នាងខ្ញុំមេធាវី **ម៉េង សុភារី** ថ្ងៃខែឆ្នាំកំណើត ២០.០៤.១៩៨០ ការិយាល័យផ្ទះលេខ៨៧C ផ្លូវលេខ៣៤៨ សង្កាត់ឃ្មួញ ខណ្ឌសែនសុខ រាជធានីភ្នំពេញ ទូរសព្ទ័លេខ០១២ ៥៦៥២ ៣៨ ជាមេធាវីតំណាងឱ្យៈ

ឈ្មោះ **ទុយ សុភ័ណ្ឌា** ភេទប្រុស ថ្ងៃខែឆ្នាំកំណើត២០-០៤-១៩៨០ សញ្ជាតិខ្មែរ ទីលំនៅបច្ចុប្បន្ននៅភូមិត្រាចជ្រុំ ឃុំសុព័រទេព ក្រុងច្បារមន ខេត្តកំពង់ស្ពឺ ។

ឈ្មោះ **ម៉ក់ ហាន** ភេទប្រុស ថ្ងៃខែឆ្នាំកំណើត១៥-០៥-១៩៥៧ សញ្ជាតិខ្មែរ ទីលំនៅបច្ចុប្បន្ននៅភូមិការជំ សង្កាត់ការជំ ក្រុងច្បារមន ខេត្តកំពង់ស្ពឺ ។

**សូមគោរពជូន**
**ឯកឧត្តម ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ**

**កម្មវត្ថុៈ** ប្តឹងជំទាស់នឹងសេចក្តីសម្រេចៈ
-លេខៈ០៩៦ លេខ១០០ លេខ១០១ ចុះថ្ងៃទី២១/០១/ ២០១៧ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
-លេខៈ០៦៧ ចុះថ្ងៃទី២០/០១/២០១៧ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
-លេខៈ០៩៨ លេខ១០២ ចុះថ្ងៃទី២១/០១/ ២០១៧ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
-លេខៈ១២៨ លេខ១២៩ លេខ១៣០ ចុះថ្ងៃទី២២/០១/២០១៧ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

**យោងៈ** -លិខិតប្រគល់សិទ្ធិតំណាងដោយអាណត្តិចុះថ្ងៃទី២៥/០១/២០១៧របស់ឈ្មោះទុយ សោភ័ណ្ឌ
-លិខិតប្រគល់សិទ្ធិតំណាងដោយអាណត្តិចុះថ្ងៃទី២៥/០១/២០១៧របស់ឈ្មោះម៉ក់ ហន
- សេចក្តីសម្រេចលេខ០១៩ ចុះថ្ងៃទី១៨/០១/២០១៧ របស់គណកម្មាធិការជាតិរៀបចំការបោះឆ្នោត ។
- លេខៈ០៩៦ ចុះថ្ងៃទី២១/០១/ ២០១៧ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- លេខ១០០ ចុះថ្ងៃទី២១/០១/ ២០១៧ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- លេខ១០១ ចុះថ្ងៃទី២១/០១/ ២០១៧ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- លេខៈ០៦៧ ចុះថ្ងៃទី២០/០១/ ២០១៧ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- លេខៈ០៩៨ ចុះថ្ងៃទី២១/០១/ ២០១៧ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- លេខ១០២ ចុះថ្ងៃទី២១/០១/ ២០១៧ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

- លេខ:១២៨ ចុះថ្ងៃទី២២/០១/ ២០១៧ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- លេខ១២៩ ចុះថ្ងៃទី២២/០១/ ២០១៧ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- លេខ១៣០ ចុះថ្ងៃទី២២/០១/ ២០១៧ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

**មូលហេតុ៖** ជនបរទេសទាំង៩នាក់ ពុំមានសញ្ញាតិខ្មែរ ស្របតាមមាត្រា៤៦ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ប៉ុន្តែត្រូវបានគណកម្មាធិកាជាតិរៀបចំការបោះឆ្នោត សម្រេចរក្សាទុកឈ្មោះ ជនទាំង៩នាក់នៅក្នុងបញ្ជីបោះឆ្នោតដំបូងដដែល។ អ្នកទាំង៩នាក់នោះមានឈ្មោះដូចខាងក្រោម៖

១/ ឈ្មោះ សុខ ជា ភេទប្រុស កើតថ្ងៃទី១០/១០/១៩៥៦ ការិយាល័យបោះឆ្នោតលេខ០២៩៩
២/ ឈ្មោះ ដាម វ៉ាង ភេទប្រុស កើតថ្ងៃទី២៥/០២/១៩៨៤ ការិយាល័យបោះឆ្នោតលេខ០៣០១
៣/ ឈ្មោះ សុខ យ៉ាង ភេទប្រុស កើតថ្ងៃទី១/០៩/១៩៩៤ ការិយាល័យបោះឆ្នោតលេខ០២៩៩
៤/ ឈ្មោះ ហេង ទង ភេទ ប្រុស កើតថ្ងៃទី 10 ១ 1969 ការិយាល័យបោះឆ្នោតលេខ០២៨៨
៥/ ឈ្មោះ ជា ប៊ុនថុង ភេទប្រុស កើតថ្ងៃទី៥/០៦/១៩៥៥ ការិយាល័យបោះឆ្នោតលេខ០២៨២
៦/ ឈ្មោះ ហេង ថាំ ភេទប្រុស កើតថ្ងៃទី១/០១/១៩៧៣ ការិយាល័យបោះឆ្នោតលេខ០២៨៨
៧/ ឈ្មោះ ជូ ចាន់ថា ភេទស្រី កើតថ្ងៃទី៤/០៦/១៩៨៣ ការិយាល័យបោះឆ្នោតលេខ០២៨២
៨/ ឈ្មោះ ងួន ឈឿង ភេទស្រី កើតថ្ងៃទី៨/០៥/១៩៧៧ ការិយាល័យបោះឆ្នោតលេខ០២៨៣
៩/ ឈ្មោះ ជា គឹមឆាវ ភេទស្រី កើតថ្ងៃទី១២/០២/១៩៧៩ ការិយាល័យបោះឆ្នោតលេខ០២៨២

នាងខ្ញុំសូមបញ្ជាក់ថា គណកម្មាធិកាជាតិរៀបចំការបោះឆ្នោតដោះស្រាយបណ្តឹងខាងលើដោយពុំបានចុះស្រាវជ្រាវ ឬកោះហៅភាគីដើម្បីតទល់គ្នាឡើយ ។

**សំនូមពរ:** -សុំចុះស៊ើបអង្កេតដល់ទីកន្លែងរស់នៅរបស់ចុងចម្លើយ

-សុំលុបឈ្មោះជនបរទេសចំនួន៣នាក់ដែលមានឈ្មោះសុខ ជា ឈ្មោះដាម វ៉ាង ឈ្មោះសុខ យ៉ាង ចេញពីការិយាល័យក្នុងបញ្ជីបោះឆ្នោតដំបូង នៃឃុំសុព័រទេព ក្រុងច្បារមន ខេត្តកំពង់ស្ពឺ

-សុំលុបឈ្មោះជនបរទេសចំនួន៦នាក់ ដែលមានឈ្មោះ ហេង ទង ឈ្មោះជា ប៊ុនថុងឈ្មោះ ហេង ថាំ ឈ្មោះជូ ចាន់ថា ឈ្មោះងួន ឈឿង ឈ្មោះជា គឹមឆាវ ចេញពីការិយាល័យក្នុងបញ្ជីបោះឆ្នោតដំបូង ននៃសង្កាត់ច្បារមន ក្រុងច្បារមន ខេត្តកំពង់ស្ពឺ

សូម **ឯកឧត្តម** ទទួលនូវការគោរពដ៏ស្មោះអំពីខ្ញុំ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែមករា ឆ្នាំ២០១៧

ហត្ថលេខា និងត្រា

ព្រះរាជាណាចក្រកម្ពុជា មេធាវី AVOCAT ATTORNEY AT LAW KINGDOM OF CAMBODIA

មេធាវី.ម៉េង_សុភារី

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមប្រឹក្សាធម្មនុញ្ញ**

**សំណុំរឿង**

- លេខ : ៣០៤/០៤២/២០១៧
  ចុះថ្ងៃទី ២៧ ខែ មករា ឆ្នាំ២០១៧
- លេខ : ៣០៥/០៤៣/២០១៧
  ចុះថ្ងៃទី ២៧ ខែ មករា ឆ្នាំ២០១៧
- លេខ : ៣០៦/០៤៤/២០១៧
  ចុះថ្ងៃទី ២៧ ខែ មករា ឆ្នាំ២០១៧
- លេខ : ៣០៧/០៤៥/២០១៧
  ចុះថ្ងៃទី ២៧ ខែ មករា ឆ្នាំ២០១៧
- លេខ : ៣០៨/០៤៦/២០១៧
  ចុះថ្ងៃទី ២៧ ខែ មករា ឆ្នាំ២០១៧

**សេចក្តីសម្រេច**

លេខ : ១៧២/០១២/២០១៧ កបធ.ច

ចុះថ្ងៃទី ០៤ ខែ កុម្ភៈ ឆ្នាំ២០១៧

# ក្រុមប្រឹក្សាធម្មនុញ្ញ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ២០០៧ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣១៥/០០៣ ចុះថ្ងៃទី ២៦ ខែ មីនា ឆ្នាំ២០១៥ ប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញសេចក្តីសម្រេចលេខ០៦៨ លេខ០៦៩ លេខ០៧១ លេខ០៧២ លេខ០៧៣ លេខ០៧៤ លេខ០៧៥ លេខ០៧៦ លេខ០៧៧ លេខ០៧៩ ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០១៧ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- បានឃើញសេចក្តីសម្រេចលេខ០៨០ លេខ០៨១ លេខ០៨៣ លេខ០៨៦ លេខ០៨៨ លេខ០៩០ លេខ០៩១ លេខ០៩៧ លេខ០៩៩ ចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០១៧របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

- បានឃើញលិខិតប្រគល់សិទ្ធិតំណាងដោយអាណត្តិចុះថ្ងៃទី២៥ ខែមករា ឆ្នាំ២០១៧ របស់លោក **ចាន់ ស៊ីថា** លោក **ប៉ាល់ ហួន** និងលោក **អ៊ឹម សារ៉ាត** ប្រគល់សិទ្ធិជូនលោក **កែត ឃី** ជាមេធាវីតំណាង ក្នុងការប្តឹងទាស់នឹងសេចក្តីសម្រេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត និងការពារសំណុំរឿងនៅក្រុមប្រឹក្សាធម្មនុញ្ញតាមនីតិវិធី
- បានឃើញពាក្យបណ្តឹងរបស់លោក **កែត ឃី** ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០១៧ ប្តឹងជំទាស់នឹងសេចក្តីសម្រេចលេខ០៦៨ លេខ០៦៩ លេខ០៧១ លេខ០៧២ លេខ០៧៣ លេខ០៧៤ លេខ០៧៥ លេខ០៧៦ លេខ០៧៧ លេខ០៧៩ ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០១៧ និង សេចក្តីសម្រេចលេខ០៨០ លេខ០៨១ លេខ០៨៣ លេខ០៨៦ លេខ០៨៨ លេខ០៩០ លេខ០៩១ លេខ០៩៧ លេខ០៩៩ ចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០១៧ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- បានឃើញកំណត់ហេតុឆ្លើយបំភ្លឺរបស់លោក **កែត ឃី** កាលពីថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១៧ នៅចំពោះមុខក្រុមទី១នៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញលិខិតលេខ ១២៥ គ.ជ.ប ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០១៧ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតឧទ្ទេសនាមឯកឧត្តម **មាន សទិ** និង ឯកឧត្តម **កែ រីទ្ធិ** មកបំភ្លឺលើពាក្យបណ្តឹងរបស់លោក **កែត ឃី**
- បានឃើញកំណត់ហេតុបំភ្លឺរបស់ឯកឧត្តម **មាន សទិ** តំណាងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតនៅចំពោះមុខក្រុមទី១នៃក្រុមប្រឹក្សាធម្មនុញ្ញ កាលពីថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១៧ ភ្ជាប់ដោយសារណាមួយច្បាប់ចុះថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០១៧ និង ឯកសារពាក់ព័ន្ធនឹងអ្នកចុះឈ្មោះបោះឆ្នោត ចំនួន៦០នាក់ដែលត្រូវបានប្តឹងថាជាជនជាតិបរទេស
- បានឃើញកំណត់ហេតុនិងរបាយការណ៍ស៊ើបអង្កេតរបស់មន្ត្រីជំនាញនៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០១៧ នៅសង្កាត់ផ្ទះព្រៃ នៅសង្កាត់លលកស ក្រុងពោធិ៍សាត់ នៅឃុំវាល ស្រុកកណ្តៀង ខេត្តពោធិ៍សាត់ និងនៅឃុំសឿ ស្រុកមង្គលបុរី ខេត្តបន្ទាយមានជ័យ ។

**ក្រោយពីបានស្តាប់របាយការណ៍របស់សមាជិករាយការណ៍**

**ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ**

- យល់ឃើញថា បណ្តឹងចំនួន០៥ របស់លោក **កែត ឃី** ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០១៧ ស្ថិតក្នុងដំណាក់កាលបិទផ្សាយបញ្ជីបោះឆ្នោតដំបូង ។ យោងតាមមាត្រា៦២ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និង មាត្រា ២៦ ចំណុចទី៣ នៃច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុម ប្រឹក្សាធម្មនុញ្ញ បណ្តឹងរបស់លោក **កែត ឃី** បានធ្វើឡើងត្រឹមត្រូវតាមទម្រង់ច្បាប់ ដូច្នេះ

ក្រុមប្រឹក្សាធម្មនុញ្ញអាចទទួលយកមកពិនិត្យបាន

- យល់ឃើញថា នៅពេលឆ្លើយបំភ្លឺនៅចំពោះមុខក្រុមទី១ នៃក្រុមប្រឹក្សាធម្មនុញ្ញ លោកមេធាវី **កែត ឃី** បានបញ្ជាក់ដូចតទៅនេះ ៖

 • លោកឯកភាពបញ្ចូលសំណុំរឿង ដែលប្ដឹងជំទាស់នឹងសេចក្ដីសម្រេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតទាំង ១៩ នេះ ជាសំណុំរឿងតែមួយ ដោយសារអង្គហេតុតែមួយ និងអង្គច្បាប់ដូចគ្នា

 • ចំពោះការប្ដឹងនេះគឺមានជនបរទេស( វៀតណាម ) មានឈ្មោះក្នុងបញ្ជីបោះឆ្នោតឆ្នាំ ២០១៦

 • លោកមិនបានចុះទៅផ្ទាល់ទេ គឺសំអាងឯកសារដែលផ្ដល់ឲ្យដោយលោក **ចាន់ ស៊ីថា** លោក **អ៊ឹម សារ៉ាត** លោក **ប៉ាល់ ហួន** លោក **អែម សាអឿម** និង លោក **ឈន វណ្ណី** និងមានសាក្សីដែលស្គាល់ថា អ្នកទាំងនោះជាជនជាតិវៀតណាម

 • លោកមិនដឹងថាជនបរទេសទាំងនោះមានអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬមិនមានទេ ដើម្បីចុះឈ្មោះបោះឆ្នោត

 • ប៉ុន្តែទោះបីជាមានអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរក្ដី ជនបរទេសដែលមិនមានចូលសញ្ជាតិតាមព្រះរាជក្រឹត្យមិនអាចចុះឈ្មោះបោះឆ្នោតបានទេយោងតាមមាត្រា ៤៦ នៃច្បាប់ស្ដីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ

 • លោក **កែត ឃី** សំណូមពរសុំក្រុមប្រឹក្សាធម្មនុញ្ញកោះហៅជនដែលត្រូវប្ដឹងចូលមកបំភ្លឺចំពោះមុខ ដើម្បីធ្វើការសាកសួរឬសគល់នៃការចូលសញ្ជាតិខ្មែរ។ បើរកឃើញថាជនទាំងនោះជាជនបរទេសមែន សូមលុបឈ្មោះចេញពីបញ្ជីបោះឆ្នោតដំបូងឆ្នាំ២០១៦

- យល់ឃើញថា នៅពេលបំភ្លឺចំពោះមុខក្រុមទី១នៃក្រុមប្រឹក្សាធម្មនុញ្ញឯកឧត្តម **មាន សទិ** តំណាងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតបានបញ្ជាក់ថា ចំពោះពាក្យបណ្ដឹងចំនួន ១៩ ខាងលើនេះ លោកមេធាវី **កែត ឃី** បានអះអាងថា អ្នកចុះឈ្មោះបោះឆ្នោតទាំងនោះមិនមានសញ្ជាតិខ្មែរ ពុំមានព្រះរាជក្រឹត្យផ្ដល់សញ្ជាតិ ដែលផ្ទុយនឹងមាត្រា ១៦ និងមាត្រា ១៩ នៃច្បាប់ស្ដីពីសញ្ជាតិ ។ តាមការពិនិត្យនិងការស្រាវជ្រាវរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតឃើញថា អ្នកចុះឈ្មោះបោះឆ្នោតចំនួន ៦០នាក់ ក្នុងនោះចំនួន ៥៥នាក់ បានប្រើប្រាស់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ និងចំនួន ០៥នាក់ បានប្រើប្រាស់ឯកសារបញ្ជាក់អត្តសញ្ញាណបម្រើឲ្យការចុះឈ្មោះបោះឆ្នោត ហើយបានមកចុះឈ្មោះបោះឆ្នោតចំពោះមុខក្រុមចុះឈ្មោះបោះឆ្នោត ស្របតាមមាត្រា ៥១ នៃច្បាប់ស្ដីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ

- យល់ឃើញថា លោក **កែត ឃី** ជាដើមបណ្ដឹងដែលបានប្ដឹងជំទាស់សេចក្ដីសម្រេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ក្នុងការសុំលុបឈ្មោះជនបរទេស ពុំមានឯកសារ ឬភស្តុតាងជា

លាយលក្ខណ៍អក្សរដែលអាចឲ្យក្រុមប្រឹក្សាធម្មនុញ្ញ បដិសេធសេចក្ដីសម្រេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតបានឡើយ

- យល់ឃើញថា តាមការស៊ើបអង្កេតរបស់មន្ត្រីជំនាញនៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ អ្នកចុះឈ្មោះបោះឆ្នោតដែលត្រូវដើមបណ្ដឹងប្ដឹងសុំលុបឈ្មោះ អ្នកទាំងនោះសុទ្ធតែបានបំពេញលក្ខខណ្ឌចុះឈ្មោះបោះឆ្នោតត្រឹមត្រូវតាមច្បាប់ និង បទបញ្ជានិងនីតិវិធីចុះឈ្មោះបោះឆ្នោត
- យល់ឃើញថា សេចក្ដីសម្រេចលេខ០៦៨ លេខ០៦៩ លេខ០៧១ លេខ០៧២ លេខ០៧៣ លេខ០៧៤ លេខ០៧៥ លេខ០៧៦ លេខ០៧៧ លេខ០៧៩ ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០១៧ និង សេចក្ដីសម្រេចលេខ០៨០ លេខ០៨១ លេខ០៨៣ លេខ០៨៦ លេខ០៨៨ លេខ០៩០ លេខ០៩១ លេខ០៩៧ លេខ០៩៩ ចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០១៧ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត មានមូលដ្ឋានគតិយុត្តត្រឹមត្រូវ
- យល់ឃើញថា ការបញ្ជាក់អំពីជាតុពិតនៃអត្តសញ្ញាណរបស់បុគ្គលណាម្នាក់មិនមែនជាសមត្ថកិច្ចរបស់ក្រុមប្រឹក្សាធម្មនុញ្ញទេ ។

## សម្រេច

**មាត្រា ១.** ទទួលពាក្យបណ្ដឹងចុះថ្ងៃទី ២៦ ខែ មករា ឆ្នាំ២០១៧ របស់លោក **កែត យី** ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយខុសនឹងគតិច្បាប់ ។

**មាត្រា ២.** តម្កល់សេចក្ដីសម្រេចលេខ០៦៨ ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០១៧ សេចក្ដីសម្រេចលេខ០៦៩ ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០១៧ សេចក្ដីសម្រេចលេខ០៧១ ចុះថ្ងៃទី២០ខែមករា ឆ្នាំ២០១៧ សេចក្ដីសម្រេចលេខ០៧២ ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០១៧ សេចក្ដីសម្រេចលេខ០៧៣ ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០១៧ សេចក្ដីសម្រេចលេខ០៧៤ ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០១៧ សេចក្ដីសម្រេចលេខ០៧៥ ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០១៧ សេចក្ដីសម្រេចលេខ០៧៦ ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០១៧ សេចក្ដីសម្រេចលេខ០៧៧ ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០១៧ សេចក្ដីសម្រេចលេខ០៧៩ ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០១៧ សេចក្ដីសម្រេចលេខ០៨០ ចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០១៧ សេចក្ដីសម្រេចលេខ០៨១ ចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០១៧ សេចក្ដីសម្រេចលេខ០៨៣ ចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០១៧ សេចក្ដីសម្រេចលេខ០៨៦ ចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០១៧ សេចក្ដីសម្រេចលេខ០៨៨ ចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០១៧ សេចក្ដីសម្រេចលេខ០៩០ ចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០១៧ សេចក្ដីសម្រេចលេខ០៩១ ចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០១៧ សេចក្ដីសម្រេចលេខ០៩៧ ចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០១៧ និង សេចក្ដីសម្រេចលេខ០៩៩ ចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០១៧ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ទុកជាបានការពេញទាំងមូល ។

**មាត្រា ៣.-** សេចក្តីសម្រេចនេះ ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០១៧ ក្នុងកិច្ចប្រជុំពេញអង្គនៃក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្តីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និង ត្រូវចុះផ្សាយក្នុងរាជកិច្ច ។

រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ កុម្ភៈ ឆ្នាំ២០១៧

ជ. ក្រុមប្រឹក្សាធម្មនុញ្ញ

ប្រធាន

អ៊ឹម ឈុនលឹម

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
*******

ក្រុមប្រឹក្សាធម្មនុញ្ញ
ចូល លេខ [illegible] ថ្ងៃ [illegible] បញ្ជូន...............

# ពាក្យបណ្តឹង

ខ្ញុំមេធាវី **កែត ឃី** អត្តលេខ ០៧៩ មានការិយាល័យផ្ទះលេខ១៣៦E0 ផ្លូវទី៦ ភូមិទួលសំពៅ សង្កាត់ទួលសង្កែ ខណ្ឌឬស្សីកែវ រាជធានីភ្នំពេញ ទូរសព្ទ័លេខ០១២ ៣៧២ ៨២៨ ជាមេធាវីតំណាងឱ្យឈ្មោះ **ឈន ចន្ធី** ភេទប្រុស ថ្ងៃខែឆ្នាំកំណើត១៧-០២-១៩៥៧ សញ្ជាតិខ្មែរ ទីលំនៅបច្ចុប្បន្នផ្ទះ ភូមិឧត្តម ឃុំ ព្រៃកខ្យាយ(ក) ស្រុក ពាមរក៍ ខេត្ត ព្រៃវែង។

**សូមគោរពជូន**
**ឯកឧត្តម ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ**

**កម្មវត្ថុ៖** ប្តឹងជំទាស់នឹងសេចក្តីសម្រេចលេ០៦៨-០៦៩-០៧១-០៧២-០៧៣-០៧៤-០៧៥-០៧៦-០៧៧-០៧៩-០៨០-០៨១គជប.ចុះថ្ងៃទី២០និង២១/០១/ឆ្នាំ២០១៧ របស់ គ.ជ.ប ដែលតម្កល់សេចក្តីសម្រេចលេខ១០-១១-១២-១៣-១៤-១៥-១៦-១៧-១៨-១៩-២០-២១-/១៧ចុះថ្ងៃទី១២/០១/២០១៧ របស់ក្រុមប្រឹក្សាឃុំ ព្រៃកខ្យាយ(ក)ទុកជាបានការ។

**យោង៖** - លិខិតប្រគល់សិទ្ធិ ចុះថ្ងៃទី២៦/០១/២០១៧ របស់កូនក្តីឈ្មោះ [illegible]។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំបាទមានកិត្តិយសសូមជម្រាបជូន **ឯកឧត្តមប្រធាន** មេត្តាជ្រាបថា កូនក្តីខ្ញុំ កើតទុក្ខមិនសុខចិត្តនឹងការសម្រេចរបស់ គ.ជ.ប ដែលមិនបានលុបឈ្មោះជនជាតិបរទេស(វៀតណាម) ចេញពីបញ្ជីឈ្មោះបោះឆ្នោតឆ្នាំ២០១៦។ ការដែលកូនក្តីខ្ញុំបានប្តឹងឱ្យលុបឈ្មោះជនជាតិបរទេសទាំងនេះដោយសារជនទាំងនេះ និយាយខ្មែរមិនច្បាស់ និងអ្នកខ្លះ ឪពុកម្តាយជាជនជាតិវៀតណាម មិនដែលធ្លាប់បានធ្វើសញ្ជាតិតូបនីយកម្មម្តងណាឡើយហើយការសម្រេចសេចក្តីរបស់គជប ក៏មិនបានឱ្យជនចុងចម្លើយមកចូលរួមដេញដោរការពារខ្លួនចំពោះមុខអង្គសវនាការដែរ។ តែការសម្រេចចុងក្រោយរបស់គជប គឺរក្សាទុកឈ្មោះជនជាតិវៀតណាមក្នុងបញ្ជីបោះឆ្នោតនៅដដែលដោយពុំមានសំអាងហេតុឱ្យបានច្បាស់លាស់។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម **ឯកឧត្តមប្រធាន** មេត្តាពិនិត្យ និង ដោះស្រាយតាមនីតិវិធី ដោយក្តីអនុគ្រោះ។

សូម **ឯកឧត្តម** ទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំ។

រាជធានីភ្នំពេញថ្ងៃទី២៦ ខែ មករា ឆ្នាំ ២០១៧

**មេធាវី**

ព្រះរាជាណាចក្រកម្ពុជា មេធាវី AVOCAT ATTORNEY AT LAW KINGDOM OF CAMBODIA

មេធាវី កែត ឃី
Lawyer KET KHY

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
*******

ក្រុមប្រឹក្សាធម្មនុញ្ញ
ចូល លេខ 805/043/ច.17
ថ្ងៃ 27/01/2017 ម៉ោង 15:05
ហត្ថលេខា ...............

# ពាក្យបណ្ដឹង

ខ្ញុំមេធាវី **កែត ឃី** អត្តលេខ ០៧៩ មានការិយាល័យផ្ទះលេខ១៣៦E០ ផ្លូវទី៦ ភូមិទួលសំពៅ សង្កាត់ទួលសង្កែ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ទូរសព្ទ័លេខ០១២ ៣៧២ ៨២៨ ជាមេធាវីតំណាងឱ្យឈ្មោះ**ចាន់ ស៊ីថា** ភេទប្រុស ថ្ងៃខែឆ្នាំកំណើត២០-០៤-១៩៥៤ សញ្ជាតិខ្មែរ ទីលំនៅបច្ចុប្បន្នផ្ទះ ភូមិ ពាលញែក២ សង្កាត់ ផ្ទះព្រៃ ក្រុង ពោធិសាត់ ខេត្ត ពោធិសាត់ ។

**សូមគោរពជូន**
**ឯកឧត្ដម ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ**

**កម្មវត្ថុ៖** ប្ដឹងជំទាស់នឹងសេចក្ដីសម្រេចលេខ០៨៣ គជប.ចុះថ្ងៃទី២១/០១/ ឆ្នាំ២០១៧ របស់ គ.ជ.ប ដែលតម្កល់សេចក្ដីសម្រេចលេខ០២/១៧ចុះថ្ងៃទី១២/០១/២០១៧ របស់ក្រុមប្រឹក្សាសង្កាត់ផ្ទះព្រៃទុកជាបានការ។

**យោង៖** - លិខិតប្រគល់សិទ្ធិ ចុះថ្ងៃទី25...../០១/២០១៧ របស់កូនក្ដីឈ្មោះ **ចាន់ ស៊ីថា** ។
- សេចក្ដីសម្រេចលេខ០៨៣ ចុះថ្ងៃទី២១/០១/២០១៧ របស់គជប។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំបាទមានកិត្តិយសសូមជម្រាបជូន **ឯកឧត្ដមប្រធាន** មេត្តាជ្រាបថា កូនក្ដីខ្ញុំ កើតទុក្ខមិនសុខចិត្តនឹងការសម្រេចរបស់ គ.ជ.ប ដែលមិនបានលុបឈ្មោះជនជាតិបរទេស(វៀតណាម) ចេញពីបញ្ជីឈ្មោះបោះឆ្នោតឆ្នាំ២០១៦។ ការដែលកូនក្ដីខ្ញុំបានប្ដឹងឱ្យលុបឈ្មោះជនជាតិបរទេសទាំងនេះដោយសារជនទាំងនេះ និយាយខ្មែរមិនច្បាស់ និងអ្នកខ្លះ ឪពុកម្ដាយជាជនជាតិវៀតណាមមិនដែលធ្លាប់បានធ្វើសញ្ជាតិតូបនីយកម្មម្ដងណាឡើយហើយការសម្រេចសេចក្ដីរបស់គជប ក៏មិនបានឱ្យជនចុងចម្លើយមកចូលរួមដេញដោលការពារខ្លួនចំពោះមុខអង្គសវនាការដែរ។ តែការសម្រេចចុងក្រោយរបស់គជប គឺរក្សាទុកឈ្មោះជនជាតិវៀតណាមក្នុងបញ្ជីបោះឆ្នោតនៅដដែលដោយពុំមានសំអាងហេតុឱ្យបានច្បាស់លាស់។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម **ឯកឧត្ដមប្រធាន** មេត្តាពិនិត្យ និង ដោះស្រាយតាមនីតិវិធី ដោយក្ដីអនុគ្រោះ។

សូម **ឯកឧត្ដម** ទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំ។

រាជធានីភ្នំពេញថ្ងៃទី26...ខែ មករា ឆ្នាំ ២០១៧
**មេធាវី**

[ត្រា: ព្រះរាជាណាចក្រកម្ពុជា មេធាវី AVOCAT ATTORNEY AT LAW KINGDOM OF CAMBODIA]

មេធាវី កែត ឃី
Lawyer KET KHY

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
❋❋❋❋❋❋❋

ក្រុមប្រឹក្សាធម្មនុញ្ញ
ចូល
លេខ 306/044/2017
ថ្ងៃ 24/01/2017 ម៉. ...
ហត្ថលេខា..............

# ពាក្យបណ្តឹង

ខ្ញុំមេធាវី **កែត ឃី** អត្តលេខ ០៧៩ មានការិយាល័យផ្ទះលេខ១៣៦E0 ផ្លូវទី៦ ភូមិទួលសំពៅ សង្កាត់ទួលសង្កែ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ទូរស័ព្ទលេខ០១២ ៣៧២ ៨២៨ ជាមេធាវីតំណាងឱ្យឈ្មោះ**ប៉ាល់ ហួន** ភេទប្រុស ថ្ងៃខែឆ្នាំកំណើត១០-១១-១៩៦០ សញ្ជាតិខ្មែរ ទីលំនៅបច្ចុប្បន្នផ្ទះ ភូមិ កោះ សង្កាត់ លលកសរ ក្រុង ពោធិសាត់ ខេត្ត ពោធិសាត់ ។

**សូមគោរពជូន**
**ឯកឧត្តម ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ**

**កម្មវត្ថុ៖** ប្តឹងជំទាស់នឹងសេចក្តីសម្រេចលេខ០៨៦ គជប.ចុះថ្ងៃទី២១/០១/ ឆ្នាំ២០១៧ របស់ គ.ជ.ប ដែលតម្កល់សេចក្តីសម្រេចលេខ០២/១៧ចុះថ្ងៃទី១២/០១/២០១៧ របស់ក្រុមប្រឹក្សាសង្កាត់លលកសទុកជាបានការ។

**យោង៖** - លិខិតប្រគល់សិទ្ធិ ចុះថ្ងៃទី.19..../០១/២០១៧ របស់កូនក្តីឈ្មោះ **ប៉ាល់ ហួន** ។
- សេចក្តីសម្រេចលេខ០៨៦ ចុះថ្ងៃទី២១/០១/២០១៧ របស់គជប។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំបាទមានកិត្តិយសសូមជម្រាបជូន **ឯកឧត្តមប្រធាន** មេត្តាជ្រាបថា កូនក្តីខ្ញុំ កើតទុក្ខមិនសុខចិត្តនឹងការសម្រេចរបស់ គ.ជ.ប ដែលមិនបានលុបឈ្មោះជនជាតិបរទេស(វៀតណាម) ចេញពីបញ្ជីឈ្មោះបោះឆ្នោតឆ្នាំ២០១៦។ ការដែលកូនក្តីខ្ញុំបានប្តឹងឱ្យលុបឈ្មោះជនជាតិបរទេសទាំងនេះដោយសារជនទាំងនេះ និយាយខ្មែរមិនច្បាស់ និងអ្នកខ្លះ ឪពុកម្តាយជាជនជាតិវៀតណាមមិនដែលធ្លាប់បានធ្វើសញ្ជាតិតូបនីយកម្មម្តងណាឡើយហើយការសម្រេចសេចក្តីរបស់គជប ក៏មិនបានឱ្យជនចុងចម្លើយមកចូលរួមដេញដោលការពារខ្លួនចំពោះមុខអង្គសវនាការដែរ។ តែការសម្រេចចុងក្រោយរបស់គជប គឺរក្សាទុកឈ្មោះជនជាតិវៀតណាមក្នុងបញ្ជីបោះឆ្នោតនៅដដែលដោយពុំមានសំអាងហេតុឱ្យបានច្បាស់លាស់។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម **ឯកឧត្តមប្រធាន** មេត្តាពិនិត្យ និង ដោះស្រាយតាមនីតិវិធី ដោយក្តីអនុគ្រោះ។

សូម **ឯកឧត្តម** ទទួលនូការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំ។

រាជធានីភ្នំពេញថ្ងៃទី...20...ខែ មករា ឆ្នាំ ២០១៧

**មេធាវី**

មេធាវី AVOCAT ATTORNEY AT LAW KINGDOM OF CAMBODIA

មេធាវី កែត ឃី
Lawyer KET KHY

ក្រុមប្រឹក្សាធម្មនុញ្ញ
បាន លេខ ០០៨/០៤៦/២០១៧
ថ្ងៃ ២៥/០១/២០១៧ ម៉ោង ១៥:២០
បញ្ជី........................

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
*******

## ពាក្យបណ្ដឹង

ខ្ញុំមេធាវី **កែត ឃី** អត្តលេខ ០៧៩ មានការិយាល័យផ្ទះលេខ១៣៦E០ ផ្លូវទី៦ ភូមិទួលសំពៅ សង្កាត់ទួលសង្កែ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ទូរស័ព្ទលេខ០១២ ៣៧២ ៨២៨ ជាមេធាវីតំណាងឱ្យឈ្មោះ**អ៊ឹម សារ៉ាត** ភេទប្រុស ថ្ងៃខែឆ្នាំកំណើត០១-០៩-១៩៦៧ សញ្ជាតិខ្មែរ ទីលំនៅបច្ចុប្បន្នផ្ទះ ភូមិអន្លង់វិល ឃុំ អន្លង់វិល ស្រុក កណ្ដៀង ខេត្ត ពោធិសាត់។

**សូមគោរពជូន**
**ឯកឧត្តម ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ**

**កម្មវត្ថុ៖** ប្ដឹងជំទាស់នឹងសេចក្ដីសម្រេចលេ០៨៨-០៩១-០៩៧-៩៩គជប.ចុះថ្ងៃទី២១/០១/ឆ្នាំ២០១៧ របស់ គ.ជ.ប ដែលតម្កល់សេចក្ដីសម្រេចលេខ០៤/១៧-០២/១៧-០១/១៧-០៥/១៧ចុះថ្ងៃទី ១២/០១/២០១៧ របស់ក្រុមប្រឹក្សាឃុំ វាលទុកជាបានការ។

**យោង៖** - លិខិតប្រគល់សិទ្ធិ ចុះថ្ងៃទី២៥
/០១/២០១៧ របស់កូនក្ដីឈ្មោះ **អ៊ឹម សារ៉ាត** ។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំបាទមានកិត្តិយសសូមជម្រាបជូន **ឯកឧត្ដមប្រធាន** មេត្តាជ្រាបថា កូនក្ដីខ្ញុំ កើតទុក្ខមិនសុខចិត្តនឹងការសម្រេចរបស់ គ.ជ.ប ដែលមិនបានលុបឈ្មោះជនជាតិបរទេស(វៀតណាម) ចេញពីបញ្ជីឈ្មោះបោះឆ្នោតឆ្នាំ២០១៦។ ការដែលកូនក្ដីខ្ញុំបានប្ដឹងឱ្យលុបឈ្មោះជនជាតិបរទេសទាំងនេះដោយសារជនទាំងនេះ និយាយខ្មែរមិនច្បាស់ និងអ្នកខ្លះ ឪពុកម្ដាយជាជនជាតិវៀតណាម មិនដែលធ្លាប់បានធ្វើសញ្ជាតិតូបនីយកម្មម្ដងណាឡើយហើយការសម្រេចសេចក្ដីរបស់គជប ក៏មិនបានឱ្យជនចុងចម្លើយមកចូលរួមដេញដោលការពារខ្លួនចំពោះមុខអង្គសវនាការដែរ។ តែការសម្រេចចុងក្រោយរបស់គជប គឺរក្សាទុកឈ្មោះជនជាតិវៀតណាមក្នុងបញ្ជីបោះឆ្នោតនៅដដែលដោយពុំមានសំអាងហេតុឱ្យបានច្បាស់លាស់។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម **ឯកឧត្ដមប្រធាន** មេត្តាពិនិត្យ និង ដោះស្រាយតាមនីតិវិធី ដោយក្ដីអនុគ្រោះ។

សូម **ឯកឧត្ដម** ទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំ។

រាជធានីភ្នំពេញថ្ងៃទី២៦ ខែ មករា ឆ្នាំ ២០១៧

**មេធាវី**

ព្រះរាជាណាចក្រកម្ពុជា មេធាវី AVOCAT ATTORNEY AT LAW KINGDOM OF CAMBODIA

មេធាវី កែត ឃី
Lawyer KET KHY

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
*******

**ក្រុមប្រឹក្សាធម្មនុញ្ញ**
**ចូល** លេខ ៥០៧/០៥/២០១៧
ថ្ងៃ ២៧/០១/២០១៧ ម៉ោង ១៥:០០
បញ្ជូន..............

# ពាក្យបណ្ដឹង

ខ្ញុំមេធាវី **កែត ឃី** អត្តលេខ ០៧៩ មានការិយាល័យផ្ទះលេខ១៣៦E០ ផ្លូវទី៦ ភូមិទួលសំពៅ សង្កាត់ទួលសង្កែ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ទូរស័ព្ទលេខ០១២ ៣៧២ ៨២៨ ជាមេធាវីតំណាងឱ្យឈ្មោះ**អែម សាអឿម** ភេទប្រុស ថ្ងៃខែឆ្នាំកំណើត១៩៥៥ សញ្ជាតិខ្មែរ ទីលំនៅបច្ចុប្បន្នផ្ទះ ភូមិ សឿ ឃុំ សឿ ស្រុក មង្គលបុរី ខេត្ត បន្ទាយមានជ័យ ។

**សូមគោរពជូន**
**ឯកឧត្តម ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ**

**កម្មវត្ថុ៖** ប្ដឹងជំទាស់នឹងសេចក្ដីសម្រេចលេខ០៩០ គជប.ចុះថ្ងៃទី២១/០១/ ឆ្នាំ២០១៧ របស់ គ.ជ.ប ដែលតម្កល់សេចក្ដីសម្រេចលេខ០១/បឃសចុះថ្ងៃទី១៣/០១/២០១៧ របស់ក្រុមប្រឹក្សាសង្កាត់ ឃុំ សឿទុកជាបានការ។

**យោង៖** - លិខិតប្រគល់សិទ្ធិ ចុះថ្ងៃទី.26.../០១/២០១៧ របស់កូនក្ដីឈ្មោះ **អែម សាអឿម** ។
- សេចក្ដីសម្រេចលេខ០៩០ ចុះថ្ងៃទី២១/០១/២០១៧ របស់គជប។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំបាទមានកិត្តិយសសូមជម្រាបជូន **ឯកឧត្តមប្រធាន** មេត្តាជ្រាបថា កូនក្ដីខ្ញុំ កើតទុក្ខមិនសុខចិត្តនឹងការសម្រេចរបស់ គ.ជ.ប ដែលមិនបានលុបឈ្មោះជនជាតិបរទេស(វៀតណាម) ចេញពីបញ្ជីឈ្មោះបោះឆ្នោតឆ្នាំ២០១៦។ ការដែលកូនក្ដីខ្ញុំបានប្ដឹងឱ្យលុបឈ្មោះជនជាតិបរទេសទាំងនេះដោយសារជនទាំងនេះ និយាយខ្មែរមិនច្បាស់ និងអ្នកខ្លះ ឪពុកម្ដាយជាជនជាតិវៀតណាមមិនដែលធ្លាប់បានធ្វើសញ្ជាតិតូបនីយកម្មម្ដងណាឡើយហើយការសម្រេចសេចក្ដីរបស់គជប ក៏មិនបានឱ្យជនចុងចម្លើយមកចូលរួមដេញដោលការពារខ្លួនចំពោះមុខអង្គសវនាការដែរ។ តែការសម្រេចចុងក្រោយរបស់គជប គឺរក្សាទុកឈ្មោះជនជាតិវៀតណាមក្នុងបញ្ជីបោះឆ្នោតនៅដដែលដោយពុំមានសំអាងហេតុឱ្យបានច្បាស់លាស់។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម **ឯកឧត្តមប្រធាន** មេត្តាពិនិត្យ និង ដោះស្រាយតាមនីតិវិធី ដោយក្ដីអនុគ្រោះ។

សូម **ឯកឧត្តម** ទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំ។

រាជធានីភ្នំពេញថ្ងៃទី.26....ខែ មករា ឆ្នាំ ២០១៧
**មេធាវី**

ព្រះរាជាណាចក្រកម្ពុជា មេធាវី AVOCAT ATTORNEY AT LAW KINGDOM OF CAMBODIA

មេធាវី កែត ឃី
Lawyer KET KHY

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
លេខ: ១៩ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការបង្កើតយន្តការច្រកចេញចូលតែមួយ សម្រាប់ការផ្តល់សេវារដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលសមាសភាពសមាជិករាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញអនុក្រឹត្យលេខ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ

- បានឃើញអនុក្រឹត្យលេខ២១៥ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលរាជធានីភ្នំពេញ និងក្រុមប្រឹក្សា គណៈអភិបាលខណ្ឌនៃរាជធានីភ្នំពេញ
- បានឃើញអនុក្រឹត្យលេខ២១៦ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក
- បានឃើញអនុក្រឹត្យលេខ៦៨ អនក្រ.បក ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៣ ស្តីពីការផ្តល់សេវារដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ៦៨ អនក្រ.បក ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១២ ស្តីពីដំណើរការទូទៅនៃការផ្ទេរមុខងារ និងធនធានឱ្យទៅដល់រដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ១១៤ អនក្រ.បក ចុះថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីការកំណត់រចនាសម្ព័ន្ធគ្រប់គ្រង និងមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រងនៃក្រសួង ស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- យោងតាមសំណើរបស់ប្រធានគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១.-**

អនុក្រឹត្យនេះ មានគោលបំណងលើកកម្ពស់គុណភាព ប្រសិទ្ធភាព ប្រសិទ្ធផល តម្លាភាព និងគណនេយ្យភាពនៃការផ្តល់សេវារដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ តាមរយៈការប្រមូលផ្តុំការផ្តល់សេវារដ្ឋបាលលើវិស័យនានានៅកន្លែងតែមួយ ដើម្បីបង្កលក្ខណៈងាយស្រួល និងឆ្លើយតបទាន់ពេលវេលាទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋ។

**មាត្រា២.-**

អនុក្រឹត្យនេះ មានគោលដៅកំណត់អំពីយន្តការ គោលការណ៍ បែបបទ និងនីតិវិធីនៃការផ្តល់សេវារដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ព្រមទាំងការគាំទ្រ ការតាមដានត្រួតពិនិត្យ និងការវាយតម្លៃទៅលើការផ្តល់សេវារដ្ឋបាលទាំងនោះ។

**មាត្រា៣.-**

អនុក្រឹត្យនេះ មានវិសាលភាពអនុវត្តចំពោះការផ្តល់សេវារដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងក្របខ័ណ្ឌសមត្ថកិច្ចដែលទទួលបានតាមរយៈការប្រគល់ឬការធ្វើប្រតិភូកម្មពីក្រសួង ស្ថាប័នពាក់ព័ន្ធនានារបស់រាជរដ្ឋាភិបាល និងក្នុងក្របខ័ណ្ឌសមត្ថកិច្ចនៃអាណត្តិទូទៅរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

## ជំពូកទី២
## យន្តការនៃការផ្តល់សេវារដ្ឋបាលនៅរដ្ឋបាលរាជធានី ខេត្ត
### ផ្នែកទី១
### រចនាសម្ព័ន្ធនិងតួនាទី

**មាត្រា៤.-**

រដ្ឋបាលរាជធានី ខេត្តនីមួយៗ ត្រូវបង្កើតឱ្យមាន**អង្គភាពច្រកចេញចូលតែមួយ**សម្រាប់ផ្តល់សេវារដ្ឋបាលជូនប្រជាពលរដ្ឋនៅក្នុងក្របខ័ណ្ឌសមត្ថកិច្ចរបស់ខ្លួន។

**មាត្រា៥.-**

អង្គភាពច្រកចេញចូលតែមួយ គឺជាកន្លែងប្រមូលផ្តុំការផ្តល់សេវារដ្ឋបាលនៅកន្លែងតែមួយតាមនីតិវិធីសាមញ្ញ ប្រកបដោយគុណភាព ប្រសិទ្ធភាព ប្រសិទ្ធផល តម្លាភាព និងគណនេយ្យភាព។

អង្គភាពច្រកចេញចូលតែមួយ ត្រូវរៀបចំជាពីរផ្នែកគឺ ផ្នែកជួរមុខ និងផ្នែកជួរក្រោយ។

**ផ្នែកជួរមុខ** គឺជាកន្លែងសម្រាប់ប្រជាពលរដ្ឋប្រាស្រ័យទាក់ទងដោយផ្ទាល់ ដើម្បីទទួលព័ត៌មាននានាអំពីការផ្តល់សេវារដ្ឋបាល ទទួលទម្រង់បែបបទ ដាក់ពាក្យស្នើសុំ បង់ប្រាក់កម្រៃ និងទទួលលទ្ធផលសម្រេចជាផ្លូវការនៃសេវារដ្ឋបាលដែលបានស្នើសុំ។

**ផ្នែកជួរក្រោយ** គឺជាកន្លែងពិនិត្យ និងផ្តល់យោបល់ផ្នែកបច្ចេកទេសលើសំណុំបែបបទនៃការស្នើសុំសេវារដ្ឋបាល។

**មាត្រា៦.-**

អង្គភាពច្រកចេញចូលតែមួយត្រូវដឹកនាំដោយប្រធានមួយ(១)រូប និងអនុប្រធានយ៉ាងច្រើនពីរ(២)រូបជាជំនួយការ។

ប្រធានអង្គភាពច្រកចេញចូលតែមួយ មានឋានៈស្មើនាយកទីចាត់ការនៃសាលារាជធានី ខេត្ត។

អនុប្រធានអង្គភាពច្រកចេញចូលតែមួយ មានឋានៈស្មើនាយករងទីចាត់ការនៃសាលារាជធានី ខេត្ត។

ការតែងតាំងប្រធាននិងអនុប្រធានអង្គភាពច្រកចេញចូលតែមួយ ត្រូវអនុលោមលក្ខន្តិកៈដោយឡែកសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ និងលិខិតបទដ្ឋានគតិយុត្តដែលមានជាធរមាន។

**មាត្រា៧.-**

ការរៀបចំនិងការប្រព្រឹត្តទៅនៃអង្គភាពច្រកចេញចូលតែមួយនៃរដ្ឋបាលរាជធានី ខេត្ត ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

### ផ្នែកទី២
### ទីកន្លែងធ្វើការ បុគ្គលិក និងប្រភេទសេវារដ្ឋបាល

**មាត្រា៨.-**

អភិបាលរាជធានី ខេត្ត ត្រូវរៀបចំឱ្យមានទីកន្លែងបំពេញការងាររបស់អង្គភាពច្រកចេញចូលតែមួយឱ្យបានសមស្រប និងបំពាក់នូវសម្ភារៈ បរិក្ខារ ឧបករណ៍ និងមធ្យោបាយសម្រាប់គាំទ្រដល់បុគ្គលិកបំពេញការងារនៅក្នុងអង្គភាពនេះ ព្រមទាំងបង្កលក្ខណៈងាយស្រួលដល់ប្រជាពលរដ្ឋក្នុងការទទួលសេវារដ្ឋបាល។

**មាត្រា៩.-**

រដ្ឋបាលរាជធានី ខេត្ត ត្រូវរៀបចំចាត់តាំងបុគ្គលិកដែលមានសមត្ថភាព និងបទពិសោធការងារក្នុងចំនួនសមស្របតាមទំហំការងារ និងស្ថានភាពជាក់ស្តែងនៃរដ្ឋបាលរាជធានី ខេត្តនីមួយៗសម្រាប់បំពេញការងារនៅផ្នែកជួរមុខនៃអង្គភាពច្រកចេញចូលតែមួយ។

**មាត្រា១០.-**

អភិបាលរាជធានី ខេត្ត ត្រូវសម្របសម្រួលជាមួយប្រធានមន្ទីរ អង្គភាពជំនាញពាក់ព័ន្ធនឹងការផ្តល់សេវារដ្ឋបាលដើម្បីចាត់តាំងបុគ្គលិកជំនាញយ៉ាងតិចចំនួនមួយ(១)រូប ដែលមានសមត្ថភាព និងបទពិសោធមកបំពេញការងារពេញម៉ោងនៅផ្នែកជួរក្រោយនៃអង្គភាពច្រកចេញចូលតែមួយនៃរដ្ឋបាលរាជធានី ខេត្ត។

អភិបាលរាជធានី ខេត្ត ត្រូវរាយការណ៍អំពីការចាត់តាំងបុគ្គលិកមកបំពេញការងារនៅអង្គភាពច្រកចេញចូលតែមួយនេះជូនក្រុមប្រឹក្សារបស់ខ្លួន។

បុគ្គលិកដែលត្រូវបានចាត់តាំងឱ្យមកបំពេញការងារនៅផ្នែកជួរក្រោយនៃអង្គភាពច្រកចេញចូលតែមួយនៃរដ្ឋបាលរាជធានី ខេត្ត ត្រូវបានប្រគល់សិទ្ធិក្នុងការពិនិត្យ និងការផ្តល់យោបល់បច្ចេកទេសលើសេវារដ្ឋបាលតាមវិស័យជំនាញរបស់ខ្លួន លើកលែងតែប្រភេទសេវារដ្ឋបាលមួយចំនួនដែលមានលក្ខណៈបច្ចេកទេសសាំញ៉ាំ ស្មុគស្មាញ មានតម្រូវការបច្ចេកទេសច្រើន និងតម្រូវឱ្យមានការទទួលខុសត្រូវខ្ពស់។

ក្នុងករណីខាងលើនេះ អភិបាលរាជធានី ខេត្ត ត្រូវពិគ្រោះយោបល់ជាមួយប្រធានមន្ទីរ អង្គភាពជំនាញនីមួយៗ ដើម្បីកំណត់អំពីប្រភេទសេវារដ្ឋបាលមួយចំនួនដែលមានលក្ខណៈបច្ចេកទេសសាំញ៉ាំ ស្មុគស្មាញ មានតម្រូវការបច្ចេកទេសច្រើន និងតម្រូវឱ្យមានការទទួលខុសត្រូវខ្ពស់ ព្រមទាំងចាត់តាំងបុគ្គលិកជំនាញទទួលខុសត្រូវឱ្យបានច្បាស់លាស់នៅតាមមន្ទីរ អង្គភាពពាក់ព័ន្ធ ដើម្បីពិនិត្យ និងផ្តល់យោបល់បច្ចេកទេសលើប្រភេទសេវារដ្ឋបាលទាំងនេះ។

**មាត្រា១១.-**

អង្គភាពច្រកចេញចូលតែមួយនៃរដ្ឋបាលរាជធានី ខេត្ត ត្រូវផ្តល់សេវារដ្ឋបាលតាមប្រភេទសេវារដ្ឋបាលដូចបានកំណត់នៅក្នុងតារាងឧបសម្ព័ន្ធទី១ ភ្ជាប់នឹងអនុក្រឹត្យនេះ។

កម្រៃសេវា រយៈពេលនៃការផ្តល់សេវា និងសុពលភាពនៃសេវារដ្ឋបាល ត្រូវអនុវត្តតាមប្រកាសអន្តរក្រសួងរវាងក្រសួង ស្ថាប័នពាក់ព័ន្ធនីមួយៗ ជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ លើកលែងតែមានការកំណត់ផ្សេងពីនេះ។

ក្រសួង ស្ថាប័នពាក់ព័ន្ធនានា ត្រូវបន្តផ្ទេរមុខងារក្នុងការផ្តល់សេវារដ្ឋបាលបន្ថែមទៀតទៅឱ្យរដ្ឋបាលរាជធានី ខេត្ត ដើម្បីបង្កលក្ខណៈងាយស្រួល និងបង្ខិតការផ្តល់សេវារដ្ឋបាលឱ្យទៅជិតអ្នកប្រើប្រាស់សេវា។

**មាត្រា១២.-**

ក្រសួងមហាផ្ទៃដោយមានការពិគ្រោះយោបល់ជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធនានា ត្រូវផ្តល់ការណែនាំអំពីទម្រង់បែបបទ នីតិវិធី និងលក្ខខណ្ឌភ្ជាប់សម្រាប់ស្នើសុំសេវារដ្ឋបាលឱ្យមានលក្ខណៈសាមញ្ញ ងាយយល់និងច្បាស់លាស់។

## ជំពូកទី៣

## យន្តការនៃការផ្តល់សេវារដ្ឋបាលនៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ

### ផ្នែកទី១

### រចនាសម្ព័ន្ធនិងតួនាទី

**មាត្រា១៣.-**

រដ្ឋបាលក្រុង ស្រុក ខណ្ឌនីមួយៗ ត្រូវបង្កើតឱ្យមានការិយាល័យច្រកចេញចូលតែមួយ ឬយន្តការច្រកចេញចូលតែមួយសម្រាប់ផ្តល់សេវារដ្ឋបាលជូនប្រជាពលរដ្ឋនៅក្នុងក្របខ័ណ្ឌសមត្ថកិច្ចរបស់ខ្លួន។

លក្ខណសម្បត្តិនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ សម្រាប់បង្កើតការិយាល័យច្រកចេញចូលតែមួយ ត្រូវកំណត់ដោយសេចក្តីណែនាំរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

**មាត្រា១៤.-**

ការិយាល័យច្រកចេញចូលតែមួយ គឺជាកន្លែងប្រមូលផ្តុំការផ្តល់សេវារដ្ឋបាលនៅកន្លែងតែមួយ តាមនីតិវិធីសាមញ្ញ ប្រកបដោយគុណភាព ប្រសិទ្ធភាព ប្រសិទ្ធផល តម្លាភាព និងគណនេយ្យភាព។

ការិយាល័យច្រកចេញចូលតែមួយ ត្រូវរៀបចំជាពីរផ្នែកគឺ ផ្នែកជួរមុខ និងផ្នែកជួរក្រោយ។

**ផ្នែកជួរមុខ** គឺជាកន្លែងសម្រាប់ប្រជាពលរដ្ឋប្រាស្រ័យទាក់ទងដោយផ្ទាល់ ដើម្បីទទួលព័ត៌មាននានាអំពីការផ្តល់សេវារដ្ឋបាល ទទួលទម្រង់បែបបទ ដាក់ពាក្យស្នើសុំ បង់ប្រាក់កម្រៃ និងទទួលលទ្ធផលសម្រេចជាផ្លូវការនៃសេវារដ្ឋបាលដែលបានស្នើសុំ។

**ផ្នែកជួរក្រោយ** គឺជាផ្នែកដែលទ្រទ្រង់ដ៏សំខាន់លើការងារបច្ចេកទេស។ ផ្នែកជួរក្រោយមានតួនាទីពិនិត្យ និងផ្តល់យោបល់ផ្នែកបច្ចេកទេសលើការផ្តល់សេវារដ្ឋបាលតាមវិស័យជំនាញ។

**មាត្រា១៥.-**

ការិយាល័យច្រកចេញចូលតែមួយនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវអនុវត្តតាមប្រកាសលេខ ៩២៨ប្រក ចុះថ្ងៃទី១២ ខែមីនា ឆ្នាំ២០០៩ របស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃការិយាល័យច្រកចេញចូលតែមួយនៅក្រុង ស្រុក ខណ្ឌគោលដៅ។

បែបបទនិងនីតិវិធីនៃការបង្កើតយន្តការច្រកចេញចូលតែមួយសម្រាប់ផ្តល់សេវារដ្ឋបាលនៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវកំណត់ដោយសេចក្តីណែនាំរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

### ផ្នែកទី២

### ទីកន្លែងធ្វើការ បុគ្គលិក និងប្រភេទសេវារដ្ឋបាល

**មាត្រា១៦.-**

អភិបាលក្រុង ស្រុក ខណ្ឌ ត្រូវរៀបចំឱ្យមានទីកន្លែងបំពេញការងាររបស់ការិយាល័យច្រកចេញចូលតែមួយឱ្យបានសមស្រប និងបំពាក់នូវសម្ភារៈ បរិក្ខារ ឧបករណ៍ និងមធ្យោបាយសម្រាប់គាំទ្រដល់

បុគ្គលិកបំពេញការងារនៅក្នុងការិយាល័យនេះ ព្រមទាំងបង្កលក្ខណៈងាយស្រួលដល់ប្រជាពលរដ្ឋក្នុងការទទួលសេវារដ្ឋបាល។

**មាត្រា១៧.-**

រដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវចាត់តាំងបុគ្គលិកមានសមត្ថភាព និងបទពិសោធការងារក្នុងចំនួនសមស្របតាមទំហំការងារ និងតាមស្ថានភាពជាក់ស្តែងនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌនីមួយៗឱ្យមកបំពេញការងារនៅផ្នែកជួរមុខនៃការិយាល័យច្រកចេញចូលតែមួយនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ។

ក្រសួង ស្ថាប័ន មន្ទីរ អង្គភាពជំនាញពាក់ព័ន្ធនានា ត្រូវចាត់តាំងបុគ្គលិកជំនាញមានសមត្ថភាព និងបទពិសោធការងារឱ្យមកបំពេញការងារជាផ្នែកជួរក្រោយនៅក្នុងការិយាល័យច្រកចេញចូលតែមួយនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ។

អភិបាលក្រុង ស្រុក ខណ្ឌ ត្រូវរាយការណ៍អំពីការចាត់តាំងបុគ្គលិកមកបំពេញការងារនៅការិយាល័យច្រកចេញចូលតែមួយនេះជូនក្រុមប្រឹក្សារបស់ខ្លួន។

ក្នុងករណីដែលក្រសួង ស្ថាប័ន មន្ទីរ អង្គភាពណាមួយពុំទាន់មានបុគ្គលិកជំនាញសម្រាប់ចាត់តាំងឱ្យមកបំពេញការងារនៅផ្នែកជួរក្រោយ រដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវចាត់តាំងបុគ្គលិករដ្ឋបាលរបស់ខ្លួនឱ្យមកបំពេញការងារជាបុគ្គលិកផ្នែកជួរក្រោយទទួលរ៉ាប់រងក្នុងនាមជាភ្នាក់ងារតំណាងឱ្យវិស័យជំនាញនោះ។ ក្រសួង ស្ថាប័ន មន្ទីរ អង្គភាពជំនាញ ត្រូវផ្តល់ការបណ្តុះបណ្តាលដល់បុគ្គលិកដែលត្រូវបានចាត់តាំងនោះ។

បុគ្គលិកដែលបំពេញការងារនៅក្នុងការិយាល័យច្រកចេញចូលតែមួយ ត្រូវស្ថិតនៅក្រោមការគ្រប់គ្រងរបស់អភិបាលក្រុង ស្រុក ខណ្ឌ។ ក្របខ័ណ្ឌ និងបៀវត្សរបស់បុគ្គលិកមកពីក្រសួង ស្ថាប័នពាក់ព័ន្ធនានាដែលបំពេញការងារនៅការិយាល័យច្រកចេញចូលតែមួយ ត្រូវស្ថិតនៅក្នុងក្រសួង ស្ថាប័នសាមីដោយទទួលបានការដំឡើងថ្នាក់ ឋានន្តរស័ក្តិ គ្រឿងឥស្សរិយយស ការលើកទឹកចិត្ត និងអត្ថប្រយោជន៍នានាតាមនីតិវិធីជាធរមាន។

**មាត្រា១៨.-**

ការិយាល័យច្រកចេញចូលតែមួយ និងយន្តការច្រកចេញចូលតែមួយនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវផ្តល់សេវារដ្ឋបាលដូចបានកំណត់នៅក្នុងតារាងឧបសម្ព័ន្ធទី២ ភ្ជាប់នឹងអនុក្រឹត្យនេះ។

កម្រៃសេវា រយៈពេលនៃការផ្តល់សេវា និងសុពលភាពនៃសេវារដ្ឋបាល ត្រូវអនុវត្តតាមប្រកាសអន្តរក្រសួងរវាងក្រសួងមហាផ្ទៃជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ លើកលែងតែមានការកំណត់ផ្សេងពីនេះ។

ក្រសួង ស្ថាប័នពាក់ព័ន្ធនានា ត្រូវបន្តផ្ទេរមុខងារក្នុងការផ្តល់សេវារដ្ឋបាលបន្ថែមទៀតទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ ដើម្បីបង្កលក្ខណៈងាយស្រួល និងបង្កើតការផ្តល់សេវារដ្ឋបាលឱ្យទៅជិតអ្នកប្រើប្រាស់សេវា។

មាត្រា១៩.-

ក្រសួងមហាផ្ទៃ ដោយមានការពិគ្រោះយោបល់ជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធនានា ត្រូវផ្តល់ការណែនាំអំពីទម្រង់បែបបទ នីតិវិធី និងលក្ខខណ្ឌភ្ជាប់សម្រាប់ស្នើសុំសេវារដ្ឋបាលឱ្យមានលក្ខណៈសាមញ្ញ ងាយយល់ និងច្បាស់លាស់។

## ជំពូកទី៤

## យន្តការនៃការផ្តល់សេវារដ្ឋបាលនៅរដ្ឋបាលឃុំ សង្កាត់

មាត្រា២០.-

រដ្ឋបាលឃុំ សង្កាត់ត្រូវរៀបចំឱ្យមានយន្តការច្រកចេញចូលតែមួយសម្រាប់ការផ្តល់សេវារដ្ឋបាលជូនប្រជាពលរដ្ឋនៅក្នុងក្របខ័ណ្ឌសមត្ថកិច្ចរបស់ខ្លួន។

យន្តការច្រកចេញចូលតែមួយនៃរដ្ឋបាលឃុំ សង្កាត់ ត្រូវស្ថិតនៅក្រោមការដឹកនាំរបស់មេឃុំ ចៅសង្កាត់ក្នុងនាមក្រុមប្រឹក្សាឃុំ សង្កាត់ ដោយមានស្មៀនឃុំ សង្កាត់ជាសេនាធិការ។

មេឃុំ ចៅសង្កាត់ អាចប្រគល់សិទ្ធិក្នុងការពិនិត្យ ការសម្រេច និងការចុះហត្ថលេខាលើលិខិតអនុញ្ញាតឬលិខិតបញ្ជាក់ចាំបាច់មួយចំនួនជូនជំទប់ ចៅសង្កាត់រងរបស់ខ្លួនស្របតាមមាត្រា៤០នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់។

មាត្រា២១.-

មេឃុំ ចៅសង្កាត់ ត្រូវចាត់តាំងស្មៀន ឬបុគ្គលិកជំនួយការរដ្ឋបាលឱ្យបំពេញការកិច្ចជាបុគ្គលិកផ្តល់ព័ត៌មាន ទទួលប្រគល់ឯកសារ ទទួលកម្រៃសេវារដ្ឋបាល និងពិនិត្យផ្តល់យោបល់លើសំណើសុំសេវារដ្ឋបាលដើម្បីដាក់ជូនមេឃុំ ចៅសង្កាត់ពិនិត្យ និងសម្រេច។

ការចាត់តាំងឬការប្រគល់ភារកិច្ចជូនបុគ្គលិកផ្តល់ព័ត៌មាន ទទួលប្រគល់ឯកសារ និងទទួលកម្រៃសេវារដ្ឋបាល ត្រូវធ្វើឡើងដោយសេចក្តីសម្រេចរបស់រដ្ឋបាលឃុំ សង្កាត់។

មេឃុំ ចៅសង្កាត់ ត្រូវរៀបចំឱ្យមានទីកន្លែងសម្រាប់ការផ្តល់សេវារដ្ឋបាលឱ្យបានសមស្រប និងបំពាក់នូវសម្ភារៈ បរិក្ខារ ឧបករណ៍ និងមធ្យោបាយសម្រាប់គាំទ្រដល់ការផ្តល់សេវារដ្ឋបាល ព្រមទាំងបង្កលក្ខណៈងាយស្រួលដល់ប្រជាពលរដ្ឋក្នុងការទទួលសេវារដ្ឋបាល។

មាត្រា២២.-

យន្តការច្រកចេញចូលតែមួយនៃរដ្ឋបាលឃុំ សង្កាត់ ត្រូវផ្តល់សេវារដ្ឋបាលទៅតាមប្រភេទសេវា កម្រៃសេវា រយៈពេលនៃការផ្តល់សេវា និងសុពលភាពនៃសេវារដ្ឋបាល ដូចបានកំណត់នៅក្នុងប្រកាសអន្តរក្រសួងរវាងក្រសួងមហាផ្ទៃជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ លើកលែងតែមានការកំណត់ផ្សេងពីនេះ។

មាត្រា២៣.-

ក្រសួងមហាផ្ទៃត្រូវផ្តល់ការណែនាំអំពីទម្រង់បែបបទ នីតិវិធី និងលក្ខខណ្ឌភ្ជាប់សម្រាប់ស្នើសុំសេវារដ្ឋបាលឱ្យមានលក្ខណៈសាមញ្ញ ងាយយល់ និងច្បាស់លាស់។

## ជំពូកទី៥

## ការគ្រប់គ្រងនិងការចាត់ចែងចំណូលសេវារដ្ឋបាល

**មាត្រា២៤.‒**

រដ្ឋបាលថ្នាក់ក្រោមជាតិមានសិទ្ធិទទួលបានចំណូលពីកម្រៃសេវារដ្ឋបាល។

ចំណូលដែលទទួលបានពីកម្រៃនៃការផ្តល់សេវារដ្ឋបាលរបស់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់នីមួយៗ ត្រូវបង់ចូលថវិកាថ្នាក់ជាតិ និង/ឬថវិកាថ្នាក់ក្រោមជាតិតាមគោលការណ៍កំណត់។

ការគ្រប់គ្រងចំណូល ចំណាយ ការកត់ត្រា និងការបែងចែកប្រាក់រង្វាន់របស់រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវអនុវត្តតាមច្បាប់ លិខិតបទដ្ឋាន គោលការណ៍ និងនីតិវិធីនានាដែលពាក់ព័ន្ធនឹងការគ្រប់គ្រងហិរញ្ញវត្ថុរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

**មាត្រា២៥.‒**

ការបែងចែកចំណូលដែលប្រមូលបានពីការផ្តល់សេវារដ្ឋបាលនៃរដ្ឋបាលថ្នាក់ក្រោមជាតិ និងការបែងចែកប្រាក់រង្វាន់លើកទឹកចិត្តសម្រាប់ឧបត្ថម្ភដល់បុគ្គលិក និងសម្រាប់ពង្រឹងយន្តការផ្តល់សេវារដ្ឋបាល ត្រូវអនុវត្តតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន លើកលែងតែមានការកំណត់ផ្សេងពីនេះ។

## ជំពូកទី៦

## ការគាំទ្រ ការតាមដានត្រួតពិនិត្យ និងការវាយតម្លៃ

**មាត្រា២៦.‒**

គ.ជ.អ.ប មានតួនាទីក្នុងការសម្របសម្រួលជាមួយក្រសួង ស្ថាប័នជំនាញពាក់ព័ន្ធនានាក្នុងការគាំទ្រផ្នែកគោលនយោបាយ ការកៀរគរធនធាន និងការគាំទ្របច្ចេកទេសពីអ្នកពាក់ព័ន្ធនានាក្នុងដំណើរការនៃការផ្ទេរមុខងារ និងដំណើរការអនុវត្តការផ្តល់សេវារដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ។

គ.ជ.អ.ប អាចប្រើប្រាស់យន្តការដែលមានស្រាប់ដូចជា ក្រុមពិគ្រោះយោបល់បច្ចេកទេសអន្តរក្រសួងដើម្បីសម្របសម្រួលក្នុងដំណើរការនៃការផ្ទេរមុខងារ និងដំណើរការអនុវត្តការផ្តល់សេវារដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ។

**មាត្រា២៧.‒**

ក្រសួងមហាផ្ទៃមានតួនាទីសម្របសម្រួលក្នុងការបង្កើតអង្គភាពច្រកចេញចូលតែមួយនៃរដ្ឋបាលរាជធានី ខេត្ត ការិយាល័យច្រកចេញចូលតែមួយនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ និងយន្តការច្រកចេញចូលតែមួយនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ និងរដ្ឋបាលឃុំ សង្កាត់ ព្រមទាំងគាំទ្រផ្នែកបច្ចេកទេសដល់ដំណើរការផ្តល់សេវារដ្ឋបាល ការអភិវឌ្ឍសមត្ថភាព ការតាមដានត្រួតពិនិត្យ និងការវាយតម្លៃលើការអនុវត្តការផ្តល់សេវារដ្ឋបាលដោយសហការជាមួយក្រសួង ស្ថាប័ន និងអ្នកពាក់ព័ន្ធនានា។

ក្រសួងមហាផ្ទៃ ត្រូវសម្របសម្រួលជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួង ស្ថាប័នពាក់ព័ន្ធនានា និងរដ្ឋបាលរាជធានី ខេត្ត ដើម្បីគាំទ្រដល់ការរៀបចំទីកន្លែងផ្តល់សេវា និងបំពាក់សម្ភារៈ បរិក្ខារ ឧបករណ៍ និងមធ្យោបាយដល់អង្គភាពច្រកចេញចូលតែមួយនៃរដ្ឋបាលរាជធានី ខេត្ត និងការិយាល័យច្រកចេញចូលតែមួយនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ។

ក្រសួងមហាផ្ទៃ អាចប្រើប្រាស់ប្រព័ន្ធគ្រប់គ្រង ឬយន្តការដែលមានស្រាប់ដើម្បីជានាលើការគ្រប់គ្រង ការគាំទ្រ ការសម្របសម្រួល និងការអនុវត្តកិច្ចការនេះ។

**មាត្រា២៨.-**

ក្រសួង ស្ថាប័នពាក់ព័ន្ធនានា ត្រូវសម្របសម្រួល និងជំរុញមន្ទីរ អង្គភាពជំនាញរបស់ខ្លួនក្នុងការចាត់តាំងបុគ្គលិកដែលមានសមត្ថភាព និងបទពិសោធការងារឱ្យមកបំពេញការងារជាបុគ្គលិកផ្នែកជួរក្រោយនៅក្នុងអង្គភាពច្រកចេញចូលតែមួយ ការិយាល័យច្រកចេញចូលតែមួយ និងយន្តការច្រកចេញចូលតែមួយ ព្រមទាំងផ្តល់ការគាំទ្រលើការអភិវឌ្ឍសមត្ថភាព ការគាំទ្រផ្នែកបច្ចេកទេស ការតាមដានត្រួតពិនិត្យ និងការវាយតម្លៃលើការផ្តល់សេវារដ្ឋបាលដែលបានផ្ទេរទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ។

**មាត្រា២៩.-**

រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗត្រូវជានាឱ្យមានការតាមដាន ការត្រួតពិនិត្យ និងការវាយតម្លៃជាប្រចាំ ព្រមទាំងទទួលដោះស្រាយនូវរាល់ភាពមិនប្រក្រតីក្នុងការផ្តល់សេវារដ្ឋបាលនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

## ជំពូកទី៧

## អន្តរប្បញ្ញត្តិ

**មាត្រា៣០.-**

រដ្ឋបាលរាជធានី ខេត្ត ត្រូវបង្កើតអង្គភាពច្រកចេញចូលតែមួយឱ្យបានយ៉ាងយូរត្រឹមដំណាច់ឆមាសទី១នៃឆ្នាំ២០១៧។

រដ្ឋបាលក្រុង ស្រុក ខណ្ឌ ដែលមានលក្ខណសម្បត្តិស្របតាមការកំណត់របស់ក្រសួងមហាផ្ទៃ ត្រូវបង្កើតការិយាល័យច្រកចេញចូលតែមួយឱ្យបានយ៉ាងយូរត្រឹមដំណាច់ឆ្នាំ២០១៧។

រដ្ឋបាលក្រុង ស្រុក ខណ្ឌ ដែលពុំទាន់មានលក្ខណសម្បត្តិសមស្របសម្រាប់បង្កើតការិយាល័យច្រកចេញចូលតែមួយ និងរដ្ឋបាលឃុំ សង្កាត់ ត្រូវបង្កើតយន្តការច្រកចេញចូលតែមួយឱ្យបានយ៉ាងយូរត្រឹមដំណាច់ឆ្នាំ២០១៧។

## ជំពូកទី៨

## អវសានប្បញ្ញត្តិ

**មាត្រា៣១.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៣២._**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានស្ថាប័នពាក់ព័ន្ធ និងរដ្ឋបាលថ្នាក់ក្រោមជាតិទាំងអស់ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០១៧

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីសូមហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.អ.ប**

**សម្តេចក្រឡាហោម ស ខេង**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៣២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# តារាងឧបសម្ព័ន្ធទី១

## សេវារដ្ឋបាលនៃរដ្ឋបាលរាជធានី ខេត្ត

## ភ្ជាប់នឹងអនុក្រឹត្យលេខ ១៧.អនក្រ.បក. ចុះថ្ងៃទី .០៤. ខែ កុម្ភៈ ឆ្នាំ២០១៧

## ស្ដីពីការបង្កើតយន្តការច្រកចេញចូលតែមួយសម្រាប់ការផ្ដល់សេវារដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ

| ល.រ | បរិយាយ |
|---|---|
| **១. ការងារនីត្យានុកូលកម្ម (ការបញ្ជាក់លើឯកសារថតចម្លង)** | |
| ១ | សេចក្ដីអនុញ្ញាតឱ្យប្រកបអាជីវកម្ម អាហរ័ណ នីហរ័ណ សណ្ឋាគារ វិនិយោគទុនបរទេស |
| ២ | លក្ខន្តិកៈក្រុមហ៊ុនអាជីវកម្មនានា វិញ្ញាបនបត្រចុះបញ្ជីក្រុមហ៊ុន លិខិតក្រសួងពាណិជ្ជកម្ម កិច្ចសន្យា |
| ៣ | ប្លង់សាងសង់ |
| ៤ | វិញ្ញាបនបត្រសម្គាល់ម្ចាស់កម្មសិទ្ធិអចលនវត្ថុ |
| ៥ | សញ្ញាបត្រក្រោយឧត្តមសិក្សា(ក្នុងប្រទេស) |
| ៦ | សញ្ញាបត្រពុទ្ធិកសិក្សា |
| ៧ | លិខិតអនុញ្ញាតចុះបញ្ជីសមាគម អង្គការ ព្រះវិហារសាសនា និងសហគមន៍ |
| ៨ | លិខិត ឬឯកសារផ្សេងៗទៀត(ដែលមិនមែនជាសមត្ថកិច្ចរបស់ស្ថាប័នណាមួយ) |
| **២. ការងាររដ្ឋបាល** | |
| ១ | ការអនុញ្ញាតឱ្យជីកឆ្លងផ្លូវ ឬតាមបណ្ដោយផ្លូវក្នុងរាជធានី ខេត្ត |
| ២ | លិខិត/ប័ណ្ណឆ្លងព្រំដែន(laissez-passer) |
| ៣ | លិខិតអនុញ្ញាតទីតាំងប៉ាណូអចល័ត |
| ៤ | ការចេញលិខិតអនុញ្ញាតបំពេញអាចម៍ដីកម្មសិទ្ធិឯកជនចាប់ពី ១០០០ម៉ែត្រការ៉េឡើងទៅ |
| ៥ | ការចុះបញ្ជីវិនិយោគជាគម្រោងមានលក្ខណសម្បត្តិគ្រប់គ្រាន់នៅអនុគណៈកម្មាធិការវិនិយោគរាជធានី ខេត្ត(ទុនវិនិយោគក្រោម២លានដុល្លារអាមេរិក) |
| **៣. វិស័យសុខាភិបាល** | |
| ១ | ការផ្ដល់លិខិតអនុញ្ញាតដល់ឱសថស្ថានចំពោះ ការបើកថ្មី ការប្ដូរទីតាំង ការប្ដូរឈ្មោះឱសថការី និងការបន្តសុពលភាព |
| ២ | ការផ្ដល់លិខិតអនុញ្ញាតដល់អគារឱសថបុរាណចំពោះ ការបើកថ្មី ការប្ដូរទីតាំង ការប្ដូរឈ្មោះគ្រូឱសថបុរាណ និងការបន្តសុពលភាព |
| ៣ | ការផ្ដល់វិញ្ញាបនបត្របញ្ជាក់អនាម័យចំណីអាហារតាមភោជនីយដ្ឋាន និងអាហារដ្ឋានដែលមានចំណុះចាប់ពី៥១កៅអីឡើង(មិនមែនអាហារដ្ឋាននិងភោជនីយដ្ឋានប្រណីត) |
| **៤. វិស័យទេសចរណ៍** | |
| ១ | **អាជ្ញាប័ណ្ណទេសចរណ៍សម្រាប់សណ្ឋាគារ និងសេវាកម្មស្នាក់នៅទេសចរណ៍** |
| | - សណ្ឋាគារ ឬសណ្ឋាគារអាផាតមិន ឬសណ្ឋាគារស្វីត ឬសណ្ឋាគាររីសត ឬប៊ីងហ្គាឡូ ឬម៉ូតែល ឬឡូដ៍ (Lodge) ចំណុះត្រឹម២០បន្ទប់ |

| ល.រ | បរិយាយ |
|---|---|
| | - ផ្ទះភ្ញៀវត្រូវបង់ថ្លៃអាជ្ញាប័ណ្ណទេសចរណ៍ |
| | - អាជ្ញាប័ណ្ណទេសចរណ៍សម្រាប់ភោជនីយដ្ឋាន អាហារដ្ឋានទេសចរណ៍ចំណុះពី៥១ ដល់១០០នាក់ |
| | - អាជ្ញាប័ណ្ណទេសចរណ៍សម្រាប់បៀរហ្គាឌិន |
| | - អាជ្ញាប័ណ្ណទេសចរណ៍សម្រាប់ខារ៉ាអូខេចាប់ពី៦បន្ទប់ឡើងទៅ |
| | - អាជ្ញាប័ណ្ណទេសចរណ៍សម្រាប់ម៉ាស្សាសុខភាពចំណុះពី០៦ ដល់១០គ្រែ ឬកៅអី |
| | - អាជ្ញាប័ណ្ណទេសចរណ៍សម្រាប់ស្ប៉ា |
| | - អាជ្ញាប័ណ្ណទេសចរណ៍សម្រាប់រង្គសាលឌីស្កូតែក ឬរង្គសាល-ឌីស្កូតែក |
| | - អាជ្ញាប័ណ្ណទេសចរណ៍សម្រាប់ដឹកជញ្ជូនភ្ញៀវទេសចរណ៍តាមផ្លូវទឹក(មិនមែនជាលក្ខណៈក្រុមហ៊ុន) |
| | - អាជ្ញាប័ណ្ណទេសចរណ៍សម្រាប់ដឹកជញ្ជូនភ្ញៀវទេសចរណ៍តាមផ្លូវគោកចាប់ពី៦កៅអីឡើងទៅ |
| ២ | **អាជ្ញាប័ណ្ណទេសចរណ៍សម្រាប់កីឡាទេសចរណ៍** |
| | - កីឡាស្នូកឃ័រចាប់ពី៦តុឡើងទៅ |
| | - ម៉ាស៊ីនហ្គេម |
| | - កីឡាសៀក |
| | - កីឡាជិះកង់រង្វង់ |
| | - កីឡាជិះដំរី |
| | - កីឡាជិះសេះ |
| | - រថយន្ត ឬរថភ្លើងអគ្គិសនី |
| **៥. វិស័យសាធារណការ និងដឹកជញ្ជូន** | |
| | **ក. ផ្នែកដឹកជញ្ជូនផ្លូវគោក** |
| ១ | **ការប្រឡងយកប័ណ្ណបើកបរយានយន្ត និងប្តូរ ពន្យារ ទុតិយតា តតិយតា(លើកលែងជនបរទេស)** |
| | - ប្រឡងយកប័ណ្ណបើកបរទោចក្រយានយន្តប្រភេទ **ក** |
| | - ប្រឡងយកប័ណ្ណបើកបរឡើងវិញ ទោចក្រយានយន្តប្រភេទ **ក** |
| | - ប្តូរ ពន្យារ ទុតិយតា ឬតតិយតាប័ណ្ណបើកបរទោចក្រយានយន្តប្រភេទ **ក** |
| | - ប្រឡងយកប័ណ្ណបើកបររថយន្តប្រភេទ **ខ** |
| | - ប្រឡងយកប័ណ្ណបើកបរឡើងវិញ រថយន្តប្រភេទ **ខ** |
| | - ប្តូរ ពន្យារ ទុតិយតា ឬតតិយតាប័ណ្ណបើកបររថយន្ត |
| ២ | **ការចុះបញ្ជីយានយន្ត** |
| | - ផ្ទេរកម្មសិទ្ធិទោចក្រយានយន្ត ឬត្រីចក្រយានយន្តក្នុងរាជធានី-ខេត្ត |
| | - ផ្ទេរកម្មសិទ្ធិទោចក្រយានយន្ត ឬត្រីចក្រយានយន្តឆ្លងរាជធានី-ខេត្ត |
| | - ផ្ទេរកម្មសិទ្ធិរ៉ឺម៉ក(ទោចក្រយានយន្ត) ក្នុងរាជធានី-ខេត្ត |
| | - ផ្ទេរកម្មសិទ្ធិរ៉ឺម៉ក(ទោចក្រយានយន្ត) ឆ្លងរាជធានី-ខេត្ត |
| | - ចុះបញ្ជីរថយន្តធុនតូច |
| | - ចុះបញ្ជីរថយន្តធុនធំ |
| | - ចុះបញ្ជីរ៉ឺម៉ក ឬសឺមីរ៉ឺម៉ករថយន្ត |



ល

| ល.រ | បរិយាយ |
|---|---|
| | - ផ្ទេរកម្មសិទ្ធិរថយន្តធុនតូចក្នុងរាជធានី-ខេត្ត |
| | - ផ្ទេរកម្មសិទ្ធិរថយន្តធុនតូចឆ្លងរាជធានី-ខេត្ត |
| | - ផ្ទេរកម្មសិទ្ធិរថយន្តធុនធំក្នុងរាជធានី-ខេត្ត |
| | - ផ្ទេរកម្មសិទ្ធិរថយន្តធុនធំឆ្លងរាជធានី-ខេត្ត |
| | - ផ្ទេរកម្មសិទ្ធិរ៉ឺម៉ក ឬសឺមីរ៉ឺម៉ករថយន្តក្នុងរាជធានី-ខេត្ត |
| | - ផ្ទេរកម្មសិទ្ធិរ៉ឺម៉ក ឬសឺមីរ៉ឺម៉ករថយន្តឆ្លងរាជធានី-ខេត្ត |
| | - ប្តូរ ទុតិយតា ឬតតិយតាប័ណ្ណរថយន្តធុនតូច |
| | - ប្តូរ ទុតិយតា ឬតតិយតាប័ណ្ណរថយន្តធុនធំ រ៉ឺម៉ក ឬសឺមីរ៉ឺម៉ក |
| | - ប្តូរ ទុតិយតា ឬតតិយតាផ្លាកលេខរថយន្តធុនតូច(ផ្លាកម្ខាង) |
| | - ប្តូរ ទុតិយតា ឬតតិយតាផ្លាកលេខរថយន្តធុនតូច(ផ្លាក ១គូ) |
| | - ប្តូរ ទុតិយតា ឬតតិយតាផ្លាកលេខរថយន្តធុនធំ រ៉ឺម៉ក ឬសឺមីរ៉ឺម៉ក(ផ្លាកម្ខាង) |
| | - ប្តូរ ទុតិយតា ឬតតិយតាផ្លាកលេខរថយន្តធុនធំ(ផ្លាក ១គូ) |
| ៣ | **ការចុះបញ្ជី និងលិខិតអនុញ្ញាតធ្វើអាជីវកម្មសាលា និងសាខាសាលាបង្រៀនបើកបរយានយន្ត** |
| | - ផ្តល់លិខិតអនុញ្ញាតធ្វើអាជីវកម្មសាខាសាលាបង្រៀនបើកបរ |
| ៤ | **ការផ្តល់លិខិតអនុញ្ញាតធ្វើអាជីវកម្មយានយន្ត** |
| ៤.១ | **ការផ្តល់លិខិតអនុញ្ញាតយានយន្តធ្វើអាជីវកម្មក្នុងប្រទេស** |
| | - រថយន្តដឹកទំនិញមានចំណុះផ្ទុកមិនលើសពី៥តោន |
| | - រថយន្តដឹកទំនិញមានចំណុះផ្ទុកលើសពី៥តោន ដល់១០តោន |
| | - រថយន្តដឹកទំនិញមានចំណុះផ្ទុកលើសពី១០តោន |
| | - រថយន្តដឹកអ្នកដំណើរមានចំណុះផ្ទុកមិនលើសពី៩នាក់ |
| | - រថយន្តដឹកអ្នកដំណើរមានចំណុះផ្ទុកចាប់ពី១០នាក់ ដល់២០នាក់ |
| | - រថយន្តដឹកអ្នកដំណើរមានចំណុះផ្ទុកលើសពី២០នាក់ |
| ៤.២ | **ការចុះបញ្ជី និងផ្តល់លិខិតអនុញ្ញាតក្រុមហ៊ុនដឹកជញ្ជូនក្នុងប្រទេស** |
| | - ផ្តល់លិខិតអនុញ្ញាតបើកស្នាក់ការ ឬសាខាក្រុមហ៊ុនដឹកជញ្ជូន |
| ៥ | **ការចុះបញ្ជី និងផ្តល់លិខិតអនុញ្ញាតធ្វើអាជីវកម្មយានដ្ឋានជួសជុលកែច្នៃ ដំឡើងយានយន្ត** |
| | - ចុះបញ្ជី និងផ្តល់លិខិតអនុញ្ញាតធ្វើអាជីវកម្មយានដ្ឋានក្នុងរាជធានី ខេត្ត |
| | **ខ. សេវាសាធារណៈលើផ្នែកដឹកជញ្ជូនផ្លូវទឹក** |
| ៦ | **ការផ្តល់ប័ណ្ណសម្គាល់ជលយាន** |
| ៦.១ | **ជលយានដែលមានចំណុះផ្ទុក២០តោនចុះក្រោម កំលាំងម៉ាស៊ីន៤០សេះចុះក្រោម និង២៥កៅអីចុះក្រោម** |
| | - ផ្តល់ប័ណ្ណសម្គាល់ជលយាន(បញ្ជាក់អ៊ីវ/ប្លង់/ពន្ធនាំចូលជលយាន ជាបន្ទុករបស់ម្ចាស់ជលយាន) |
| | - ប្តូរម៉ាស៊ីន ពណ៌ កែមាឌ ឬផ្ទេរម្ចាស់កម្មសិទ្ធិជលយាន(បញ្ជាក់អ៊ីវ/ប្លង់កែមាឌ/ប្រថាប់ត្រា ជាបន្ទុករបស់ម្ចាស់ជលយាន) |
| | - ប្តូរ(ប្តូរឈ្មោះជលយាន) ទុតិយតា ឬតតិយតាប័ណ្ណសម្គាល់ជលយាន |
| ៦.២ | **ជលយានដែលមានចំណុះផ្ទុកលើសពី២០តោន ដល់៤០តោន កំលាំងម៉ាស៊ីនលើសពី៤០សេះ ដល់៩០** |

| ល.រ | បរិយាយ |
|---|---|
| | **សេះ និងលើសពី២៥កៅអី ដល់៥០កៅអី** |
| | - ផ្តល់ប័ណ្ណសម្គាល់ជលយាន(បញ្ជាក់អ៊ីវ/ប្លង់/ពន្ធនាំចូលជលយាន ជាបន្ទុករបស់ម្ចាស់ជលយាន) |
| | - ប្តូរម៉ាស៊ីន ពណ៌ កៃមាឌ ឬផ្ទេរម្ចាស់កម្មសិទ្ធិជលយាន(បញ្ជាក់អ៊ីវ/ប្លង់កៃមាឌ/ប្រថាប់ត្រា ជាបន្ទុករបស់ម្ចាស់ជលយាន) |
| | - ប្តូរ(ប្តូរឈ្មោះជលយាន) ទុតិយតា ឬ តតិយតាប័ណ្ណសម្គាល់ជលយាន |
| ៧ | **ត្រួតពិនិត្យលក្ខណៈបច្ចេកទេសជលយាន** |
| ៧.១ | **ជលយានដែលមានចំណុះផ្ទុក២០តោនចុះក្រោម កម្លាំងម៉ាស៊ីន៤០សេះចុះក្រោម និង២៥កៅអីចុះក្រោម** |
| | - ជលយានក្នុងស្រុក |
| | - ជលយានដចម្លង |
| ៧.២ | **ជលយានដែលមានចំណុះផ្ទុកលើសពី ២០តោន ដល់៤០តោន កំលាំងម៉ាស៊ីនលើសពី៤០សេះ ដល់៩០សេះ និងលើសពី២៥កៅអី ដល់៥០កៅអី** |
| | - ជលយានក្នុងស្រុក |
| | - ជលយានដចម្លង |
| ៨ | **លិខិតអនុញ្ញាតធ្វើអាជីវកម្មដឹកជញ្ជូនផ្លូវទឹក** |
| | - នាវាដឹកទំនិញ |
| | - សាឡង់ដឹកទំនិញ(គ្មានម៉ាស៊ីន) |
| | - នាវាដឹកអ្នកដំណើរ |
| | - ដចម្លង |
| | - នាវាសណ្តោង/រុញ |
| **៦. វិស័យវប្បធម៌ និងវិចិត្រសិល្បៈ** | |
| ១ | ការចេញលិខិតអនុញ្ញាតការប្រគំតន្ត្រីតាមទីសាធារណៈលក្ខណៈអន្តរជាតិ |
| ២ | ការផ្តល់ប័ណ្ណអនុញ្ញាតបើកអាជីវកម្មបណ្ណាគារដែលមានផ្ទៃក្រឡាចាប់ពី៥០ម៉ែត្រការ៉េឡើងទៅ |
| **៧. វិស័យព័ត៌មាន** | |
| ១ | **ការផ្តល់លិខិតអនុញ្ញាតចំពោះការស្នើសុំប្រកបអាជីវកម្ម និងបន្តសុពលភាព៖** |
| | - បោះពុម្ពដោយដៃ(អូសស្ប៊ែ) បោះពុម្ពលើអាវយឺត |
| | - តូបលក់កាសែត តូបលក់សៀវភៅ ផលិតផលបោះពុម្ព និងផលិតផលសោតទស្សន៍ |
| | - សេវាជួសជុលម៉ាស៊ីនថត ម៉ាស៊ីនថតចំលង សេវាជួសជុលកុំព្យូទ័រ វាយកុំព្យូទ័រ សេវាជួសជុលវិទ្យុ ទូរទស្សន៍ ម៉ាញេ រ៉ូណេអូ អំភ្លី មេក្រូ |
| | - អគារលក់ឧបករណ៍សោតទស្សន៍ |
| | - Internet Café |
| **៨. វិស័យបរិស្ថាន** | |
| ១ | ផ្តល់លិខិតអនុញ្ញាតបញ្ចេញសំណល់រាវចេញពីទីតាំងអាជីវកម្ម ចំណុះតិចជាង៥០ម៉ែត្រគូប/ថ្ងៃ(តម្រូវឱ្យស្នើសុំ) |
| ២ | ផ្តល់លិខិតអនុញ្ញាតបញ្ចេញសំណល់រឹងចេញពីទីតាំងអាជីវកម្ម(តម្រូវឱ្យស្នើសុំ) |



៥

| ល.រ | បរិយាយ |
|---|---|
| **៩. វិស័យឧស្សាហកម្ម និងសិប្បកម្ម** | |
| ១ | ការចុះបញ្ជីសហគ្រាស និងសិប្បកម្មដែលមានដើមទុនក្រោម២០០លានរៀល(៥០ ០០០ដុល្លារ) ដែលគ្មានហានិភ័យ |
| ២ | ការចេញវិញ្ញាបនបត្រដំណើរការសិប្បកម្ម(ថ្មី ឬបន្ត) ដែលមានដើមទុនក្រោម២០០លានរៀល (៥០ ០០០ដុល្លារ) |
| ៣ | ការចេញលិខិតអនុញ្ញាតពង្រីកសិប្បកម្ម ឬប្តូរទីតាំង ឬប្តូរម្ចាស់ ឬប្តូរឈ្មោះ ឬទុតិយតាដែលមានដើមទុនក្រោម២០០លានរៀល(៥០ ០០០ដុល្លារ) |
| ៤ | ការត្រួតពិនិត្យផ្ទៀងផ្ទាត់ប្រភេទឧបករណ៍មាត្រាសាស្ត្រដែលត្រូវបានប្រើសម្រាប់ការធ្វើអាជីវកម្ម(គិត១ឯកតានៃឧបករណ៍) |
| ៤.១ | **ផ្នែកទម្ងន់** |
| | **ជញ្ជីងមិនស្វ័យប្រវត្តិ** |
| | - ទម្ងន់តិចជាង ឬស្មើ១០គីឡូក្រាម(សម្រាប់ជញ្ជីងដាក់តាំងលក់) |
| | - ទម្ងន់លើសពី១០គីឡូក្រាម ដល់១០០គីឡូក្រាម(សម្រាប់ជញ្ជីងដាក់តាំងលក់) |
| | - ទម្ងន់លើសពី១០០គីឡូក្រាម ដល់១ ០០០គីឡូក្រាម |
| ៤.២ | **ឧបករណ៍បែងចែកវត្ថុរាវ(ប្រេងឥន្ធនៈ និងហ្គាស)** |
| | - ដៃបាញ់ប្រេងចំនួន១(តាមស្ថានីយ) |
| | - ធុងហ្គាស(អប្បបរមា ៧គីឡូក្រាម) |
| | - ធុងហ្គាស(១៥ គីឡូក្រាម) |
| | - ធុងហ្គាស(លើសពី១៥ គីឡូក្រាម) |
| | - ដៃវ៉ែបូមប្រេងចំនួន១ |
| ៥ | **ត្រួតពិនិត្យផ្ទៀងផ្ទាត់បរិមាណ និងផ្លាកសញ្ញាមាត្រាសាស្ត្រលើទំនិញផលិត និងទំនិញវេចខ្ចប់** |
| ៥.១ | **ទំនិញផលិត** |
| | **+ វាយនភ័ណ្ឌ(មួយមុខផលិតផល)** |
| | - សំលៀកបំពាក់ |
| | - កំរាលព្រំ |
| | សម្ភារៈសំណង់(មួយមុខផលិតផល) |
| | បរិក្ខារអគ្គិសនី អេឡិកត្រូនិច និងអុបទិក(មួយមុខផលិតផល) |
| ៥.២ | **ទំនិញវេចខ្ចប់** |
| | **+ ជាឧស្ម័ន ផលិតផលចំណីអាហារ និងវត្ថុរាវគ្រប់ប្រភេទ(មួយមុខផលិតផល)** |
| | - តិចជាង ឬស្មើ ៥គីឡូក្រាម ឬលីត្រ |
| | - លើសពី៥គីឡូក្រាម ឬលីត្រ ដល់១០គីឡូក្រាម ឬលីត្រ |
| | - លើសពី១០គីឡូក្រាម ឬលីត្រ ដល់២០គីឡូក្រាម ឬលីត្រ |
| | - លើសពី២០គីឡូក្រាម ឬលីត្រ ដល់៣០គីឡូក្រាម ឬលីត្រ |
| | - លើសពី៣០គីឡូក្រាម ឬលីត្រ ដល់៥០គីឡូក្រាម ឬលីត្រ |

| ល.រ | បរិយាយ |
|---|---|
| | - លើសពី៥០គីឡូក្រាម ឬលីត្រ |
| | - សំណើមក្នុងគ្រាប់ធញ្ញជាតិ |
| | - ភាពក្លឹលើគ្រាប់ធញ្ញជាតិ |
| | **+ ផលិតផលថ្នាំជក់ និងក្រដាស(មួយមុខផលិតផល)** |
| | **+ ផលិតផលគីមី** |
| | - សាប៊ូដុំ ម្សៅសាប៊ូ គ្រឿងសំអាត ប៉ូលាគ្រឿងក្រអូប ឬគ្រឿងសំអាង |
| | - ថ្នាំសម្លាប់សត្វល្អិត ឬជីគីមីកសិកម្ម |
| | - ថ្នាំលាបពណ៌ វ៉ែរនី ថ្នាំទ្រនាប់ ទឹកថ្នាំបោះពុម្ព ឬម៉ាស្ទិក |
| **១០. វិស័យរ៉ែ និងថាមពល** | |
| ១ | **ការផ្តល់អាជ្ញាប័ណ្ណធនធានរ៉ែ** |
| | - សេវាពិនិត្យ រៀបចំ និងដំណើរការឯកសារសម្រាប់ការផ្តល់អាជ្ញាប័ណ្ណសិប្បកម្មធនធានរ៉ែ និងអាជីវកម្មធនធានរ៉ែខ្នាតតូច(ការដាក់ពាក្យស្នើសុំ និងដំណើរការឯកសារ) ស្របតាមការកំណត់របស់ក្រសួងរ៉ែ និងថាមពល |
| | - សេវាពិនិត្យ រៀបចំ និងដំណើរការឯកសារសម្រាប់ការផ្តល់លិខិតអនុញ្ញាតលើសកម្មភាពធ្វើអាជីវកម្មជីកយកអាចម៍ដីសម្រាប់ប្រើប្រាស់ក្នុងមូលដ្ឋានដែលមានទំហំផ្ទៃក្រឡាមិនលើសពី៣០០ម៉ែត្រក្រឡា និងជម្រៅមិនលើសពី៣ម៉ែត្រ |
| ២ | **ការចុះបញ្ជីអាជ្ញាប័ណ្ណ** |
| | - អាជ្ញាប័ណ្ណសិប្បកម្មធនធានរ៉ែ និងអាជីវកម្មធនធានរ៉ែខ្នាតតូច |
| ៣ | **ការពិន័យអន្តរការណ៍ជាប្រាក់** |
| | ករណីដំណើរការដោយអាជ្ញាប័ណ្ណធនធានរ៉ែផុតសុពលភាពចំពោះ៖<br>- អាជ្ញាប័ណ្ណសិប្បកម្ម<br>- អាជ្ញាប័ណ្ណអាជីវកម្មធនធានរ៉ែខ្នាតតូច |
| **១១. វិស័យពាណិជ្ជកម្ម** | |
| ១ | ការចេញលិខិតអនុញ្ញាតប្រកបអាជីវកម្មលោហៈជាត្បូងថ្មមានតម្លៃជាងគ្រឿងអលង្ការ |
| ២ | ការចេញលិខិតអនុញ្ញាតបិទស្លាកថ្លៃជារូបិយប័ណ្ណបរទេស |
| **១២. វិស័យរៀបចំដែនដី នគរូបនីយកម្ម និងសំណង់** | |
| | **ក. សេវាសុរិយោដី និងភូមិសាស្ត្រ** |
| ១ | ការចុះបញ្ជីដីលើកដំបូង ដែលមានលក្ខណៈជាប្រព័ន្ធ(ក្នុង១ម$^{២}$) |
| ២ | ការចុះបញ្ជីដីលើកដំបូងមានលក្ខណៈដាច់ដោយដុំ និងចេញប័ណ្ណ(ក្នុង១ក្បាលដី) |
| ៣ | ការផ្ទេរអចលនវត្ថុទាំងមូល(ក្នុង១ប័ណ្ណ) |
| ៤ | ការបំបែកក្បាលដីដោយផ្ទេរ ឬដោយមិនផ្ទេរអចលនវត្ថុ(ក្នុង១ក្បាលដីដែលបំបែក) និងការបង្រួមក្បាលដី(ក្នុង១ក្បាលដីដើម) (តាមការស្នើសុំ) |
| ៥ | ការស្វែងរកចំណុចព្រំដីឡើងវិញ(ក្នុង១បង្គោល) |

| ល.រ | បរិយាយ |
|---|---|
| ៦ | ការចេញលិខិតបញ្ជាក់ព័ត៌មានសុរិយោដីក្នុង១ក្បាលដី(ការចេញលិខិតបញ្ជាក់ ការចេញសលាកប័ត្រព័ត៌មាន ការចេញលិខិតបញ្ជាក់សុរិយោដី) |
| ៧ | ការដាក់បន្ទុក និងការលើកលែង ៖ ឯកសិទ្ធិ ការដាក់បញ្ចាំ និងការដាក់ហ៊ីប៉ូតែក (ក្នុង១ក្បាលដី ឬ១ប័ណ្ណ) |
| ៨ | ការថតចម្លងឯកសារសុរិយោដី(ក្នុង១ទំព័រក្រដាស់ A4 ) |
| ៩ | ការប្តូរប្រភេទដី(ក្នុង១ម$^{២}$) |
| ១០ | ការចុះបញ្ជីចំណែកឯកជននៃអគារសហកម្មសិទ្ធិ(ក្នុង១ចំណែកឯកជន) |
| ១១ | ការចុះបញ្ជីសិទ្ធិជួលអចិន្ត្រៃយ៍(ក្នុង១ប័ណ្ណ) |
| ១២ | ការចុះបញ្ជីសិទ្ធិសម្បទានដីសេដ្ឋកិច្ច(ក្នុង១ប័ណ្ណ) |
| ១៣ | ការចុះបញ្ជីអចលនវត្ថុទាក់ទងនឹងក្រមនីតិវិធីរដ្ឋប្បវេណី(ក្នុង១ប័ណ្ណ) |
| ១៤ | ផែនទីជាក្រដាស(ក្នុង១សន្លឹក) |
| ១៥ | រូបថតអ័រតូហ្វូតូ ទំរង់ជាឌីជីថល(ក្នុង១គ.ម$^{២}$) |
| ១៦ | រូបថតអ័រតូហ្វូតូទំរង់ជាក្រដាស(បោះពុម្ពជាក្រដាសខ្នាតA0) ក្នុង០១សន្លឹក |
| ១៧ | ទិន្នន័យបង្គោលប្រថពីវិភាគ(ប្លង់ទីតាំង និងនិយាមកា) គិតក្នុង០១បង្គោល(តាមការស្នើសុំ) |
| | **ខ. សេវាសំណង់** |
| ១ | លិខិតអនុញ្ញាតសាងសង់សំណង់លំនៅដ្ឋានដែលមានក្រឡាផ្ទៃសំណង់ទំហំ ≤៣០០០ម$^{២}$ |
| ២ | សំណង់អគារផ្សេងៗក្រៅពីលំនៅដ្ឋានដែលមានក្រឡាផ្ទៃសំណង់ទំហំ ≤៣០០០ម$^{២}$ |
| ៣ | សំណង់រដ្ឋ សំណង់សប្បុរសជន ឬអង្គការមនុស្សធម៌ អំណោយជូនសហគមន៍ ឬជនក្រីក្រ ដែលមានក្រឡាផ្ទៃសំណង់ទំហំ ≤៣០០០ម$^{២}$ |
| ៤ | ការផ្តល់គោលការណ៍សាងសង់ និងអភិវឌ្ឍន៍ដី |
| | **គ. ការចុះបញ្ជីសហគ្រាស-ក្រុមហ៊ុនប្រកបអាជីវកម្មសំណង់ រូបវន្តបុគ្គលសិក្សាគម្រោងប្លង់ និងក្រុមជាងសំណង់** |
| ១ | ចុះបញ្ជីលើកដំបូង និងបន្តសុពលភាពសម្រាប់ក្រុមជាងសំណង់ |
| | **ឃ. ការថតចម្លងឯកសារប្លង់ និងផែនទី (តាមការស្នើសុំ)** |
| ១ | ឯកសារស្នើសុំសាងសង់(ក្នុង១ច្បាប់) |
| ២ | ប្លង់ស្ថាបត្យកម្ម ឬប្លង់គ្រឿងផ្គុំសំណង់(ក្នុង១ច្បាប់) |
| ៣ | ផែនទី ទំហំ A-4(ក្នុង១សន្លឹក) |
| ៤ | ផែនទី ទំហំ A-3(ក្នុង១សន្លឹក) |
| ៥ | ផែនទី ទំហំ A-2(ក្នុង១សន្លឹក) |
| ៦ | ផែនទី ទំហំ A-1(ក្នុង១សន្លឹក) |
| ៧ | ផែនទី ទំហំ A-0(ក្នុង១សន្លឹក) |
| | **ង. សេវាពិគ្រោះយោបល់លើផ្នែកច្បាប់ និងបច្ចេកទេស(តាមការស្នើសុំ)** |
| ១ | លើការងារទាក់ទងទៅនឹងដីធ្លី និងសំណង់ទូទៅ(សម្រាប់មួយករណី) |

| ល.រ | បរិយាយ |
|---|---|
| **១៣. វិស័យកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ** | |
| ១ | **ជលផល** |
| | - ចេញលិខិតអនុញ្ញាតធ្វើវារីវប្បកម្ម |
| ២ | **ផលិតកម្ម និងបសុព្យាបាល** |
| ២.១ | **ចេញលិខិតអនុញ្ញាតប្រមូលទិញសត្វនិងផលិតផលមានដើមកំណើតពីសត្វ "ប្រភេទ ខ"** |
| | - បង្កើតសត្តឃាតដ្ឋាន |
| | - ធ្វើអាជីវកម្មពិឃាតសត្វ |
| | - បង្កើតកន្លែងប្រមូលផ្តុំសត្វ |
| | - បង្កើតកន្លែងផលិត ឬលាយផ្សំចំណីសត្វ |
| | - បង្កើតកន្លែងផលិត កែច្នៃសាច់និងផលិតផលសត្វបឋម |
| | - បង្កើតកសិកដ្ឋានចិញ្ចឹមសត្វ |
| | - បង្កើតកន្លែងលក់សត្វកំដរ |
| | - បង្កើតកន្លែងពិនិត្យនិងព្យាបាលសត្វ |
| | - បង្កើតកន្លែងលក់បសុឱសថ និងសម្ភារៈ បរិក្ខាបេសុពេទ្យ-ចំណីសត្វ |
| | - បង្កើតកន្លែងស្តុកនិងចែកចាយសាច់ |
| | - បង្កើតកន្លែងឃ្លាំងស្តុកស្បែកគោក្របី |
| ២.២ | **សោហ៊ុយសេវាកម្មត្រួតពិនិត្យអនាម័យសត្វ និងផលិតផលមានដើមកំណើតពីសត្វ និងការប្រមូលកម្រៃសេវាកម្មត្រួតពិនិត្យអនាម័យសត្វ សាច់ និងផលិតផលសត្វនៅសត្តឃាតដ្ឋាន "ចរាចរក្នុងផ្ទៃប្រទេស"** |
| | **សេវាត្រួតពិនិត្យអនាម័យសត្វ និងផលិតផលមានដើមកំណើតពីសត្វ៖** |
| | **ក. សត្វ** |
| | - សត្វចតុប្បាទស្រុកធំ(ពេញវ័យ)៖ គោ ក្របី សេះ...(ក្បាល) |
| | - សត្វចតុប្បាទស្រុកធំ(កូន)៖ គោ ក្របី សេះ...(ក្បាល) |
| | - សត្វចតុប្បាទតូច(ពេញវ័យ)៖ ជ្រូក ពពែ ចៀម...(ក្បាល) |
| | - សត្វចតុប្បាទតូច(កូន)៖ ជ្រូក ពពែ ចៀម...ចំពោះកូនជ្រូកមានទម្ងន់តិចជាង ៣០គ.ក្រ(ក្បាល) |
| | - បក្សីស្រុក(ពេញវ័យ)៖ មាន់ ទា មាន់បារាំង ក្រួច ...(ក្បាល) |
| | - បក្សី(កូន)៖ មាន់ ទា មាន់បារាំង ក្រួច ...ទម្ងន់តិចជាង ១៨៥ក្រាម(ក្បាល) |
| | - ស៊ុតបក្សីសម្រាប់ភ្ញាស់(ក្បាល) |
| | - ទឹកកាមសត្វ(កំរិត) |
| | - អំប្រីយ៉ុងសត្វ(ក្បាល) |
| | **ខ. សាច់ និងផ្នែកបន្ទាប់បន្សំដទៃទៀតរបស់សត្វដែលអាចបរិភោគបាន "ចរាចរក្នុងផ្ទៃប្រទេស"** |
| | - សាច់សត្វ ឬបក្សីទាំងមូល សាច់សត្វ ឬបក្សីពុះជា២ផ្នាំង សាច់សត្វ ឬបក្សីកាប់ជាដុំ សាច់ជាប់ឆ្អឹង សាច់កាប់ជាប់ឆ្អឹង សាច់សុទ្ធ(គ្មានជាប់ឆ្អឹង) និងផ្នែកបន្ទាប់បន្សំដទៃទៀត ស្រស់ ឬរក្សាទុកក្នុងទីត្រជាក់ ឬបង្កក(គ.ក្រ) |
| | - សាច់ងៀត សាច់ក្រក ម្សៅសាច់ ស្បែកជ្រូកក្រៀម(គ.ក្រ) |



៥

| ល.រ | បរិយាយ |
|---|---|
| | - ខ្លាញ់សត្វគ្រប់ប្រភេទ មិនទាន់ចំរាញ់ នៅស្រស់ បង្កក ប្រឡាក់ ត្រាំទឹកអំបិល រាវ ឬ កក(គ.ក្រ) |
| | - ទឹកដោះស្រស់(លីត្រ) |
| | - ស៊ុតស្រស់ ប្រៃ កំណរកូន សម្ងួត ចំអិន និងបង្កក(គ្រាប់) |
| | **គ. ផលិតផលមានដើមកំណើតពីសត្វសម្រាប់ប្រើក្នុងផ្នែកផ្សេងៗ ដែលមិនអាចបរិភោគបាន "ចរាចរក្នុងផ្ទៃប្រទេស"** |
| | - ស្បែកស្រស់ប្រឡាក់អំបិល ឬ ស្ងួត(គ.ក្រ) |
| | - ផ្នែកបន្ទាប់បន្សំដទៃទៀតរបស់សត្វ ដូចជា ឈាមស្រស់ ម្សៅឈាម ឆ្អឹង ម្សៅឆ្អឹង...(គ.ក្រ) |
| | - ចំណីសត្វ(គ.ក្រ) |
| ២.៣ | **សេវាត្រួតពិនិត្យអនាម័យសត្វ សាច់ និងផលិតផលសត្វនៅសត្តឃាតដ្ឋាន** |
| ២.៤ | **ប្រាក់រង្វាន់លើកទឹកចិត្តដល់មន្ត្រីដែលបានចូលរួមបង្ក្រាបបទល្មើសអនាម័យសត្វសាច់និងផលិតផលមានដើមកំណើតពីសត្វ** |
| | - ប្រាក់រង្វាន់បង្ក្រាបបទល្មើសអនាម័យសត្វ និងផលិតផលមានដើមកំណើតពីសត្វ និងប្រាក់រង្វាន់បង្ក្រាបបទល្មើសអនាម័យសត្វ សាច់ និងផលិតផលសត្វនៅសត្តឃាតដ្ឋាន |
| ៣ | **នីតិកម្មកសិកម្ម** |
| ៣.១ | **កម្រៃសេវាកម្មលើការចេញលិខិតអនុញ្ញាតលក់ដុំលក់រាយថ្នាំកសិកម្ម ឬជីកសិកម្ម**<br>- កម្រៃលើការចេញលិខិតអនុញ្ញាតសម្រាប់ជីកសិកម្មតាមបរិមាណស្នើសុំធ្វើប្រតិបត្តិការប្រចាំឆ្នាំ<br>- កម្រៃលើការចេញលិខិតអនុញ្ញាតសម្រាប់ថ្នាំកសិកម្មតាមបរិមាណស្នើសុំធ្វើប្រតិបត្តិការប្រចាំឆ្នាំ<br>- ការស្នើសុំលិខិតអនុញ្ញាតលក់ដុំលក់រាយចម្រុះនូវថ្នាំកសិកម្ម និងជីកសិកម្ម |
| ៤ | **កម្រៃសេវាកម្មលើដំណើរការឆ្លងវគ្គអប់រំសមត្ថភាពវិជ្ជាជីវៈ សម្រាប់អ្នកផ្គត់ផ្គង់ចែកចាយ អ្នកលក់ដុំលក់រាយ និងប្រតិបត្តិការកម្ចាត់សមាសភាពចង្រៃ** |
សូមជម្រាបជូនថា "ឯកសារគោលនយោបាយស្តីពីការអភិវឌ្ឍយន្តការ PPP សម្រាប់គ្រប់គ្រងគម្រោងវិនិយោគសាធារណៈ ២០១៦-២០២០" ក៏អាចទាញយកបានពីគេហទំព័ររបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុផងដែរ តាមរយៈ៖

-http://www.ppp.mef.gov.kh/sites/default/files/Approved%20PPP%20Policy_KH.pdf (ភាសាខ្មែរ)

-http://www.ppp.mef.gov.kh/sites/default/files/Approved%20PPP%20Policy_Eng.pdf (ភាសាអង់គ្លេស)

សូមឯកឧត្តម លោកជំទាវទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់ ពីខ្ញុំ។

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**និងជាប្រធានគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

បណ្ឌិត. **អូន ព័ន្ធមុនីរ័ត្ន**

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

## ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

## រាជរដ្ឋាភិបាលកម្ពុជា

# ឯកសារគោលនយោបាយ

# ស្តីពី

# ការអភិវឌ្ឍយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន សម្រាប់គ្រប់គ្រងគម្រោងវិនិយោគសាធារណៈ ២០១៦-២០២០

រៀបចំដោយ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

## អារម្ភកថា

រាជរដ្ឋាភិបាល បានអនុវត្តប្រកបដោយជោគជ័យនូវយុទ្ធសាស្ត្រត្រីកោណ និងយុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី១ និងទី២ របស់ខ្លួន ហើយក្នុងនីតិកាលទី៥ នៃរដ្ឋសភា បានឈានដល់ការដាក់ចេញនូវយុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី៣ ដើម្បីកំណើន, ការងារ, សមធម៌, និងប្រសិទ្ធភាព នៅកម្ពុជា ។ ឯកសារយុទ្ធសាស្ត្រទាំងនេះ បានប្រកាសអំពីបេសកកម្ម, ការប្តេជ្ញា, និងកិច្ចប្រឹងប្រែងឥតរាថយរបស់រាជរដ្ឋាភិបាលកម្ពុជា ចាប់តាំងពីនីតិកាលទី១ នៃរដ្ឋសភារហូតមក ក្នុងការធានាចីរភាពនៃការអភិវឌ្ឍ និងការកាត់បន្ថយភាពក្រីក្រ ឆ្លើយតបទៅនឹងបំណងប្រាថ្នារបស់ប្រជាជន ដោយក្នុងនោះ បានប្រកាន់ខ្ជាប់នូវការកំណត់យក÷ (១) ការវិនិយោគហេដ្ឋារចនាសម្ព័ន្ធសាធារណៈជាវិស័យអាទិភាព សម្រាប់ទ្រទ្រង់ចីរភាពនៃកំណើនសេដ្ឋកិច្ចរយៈពេលវែង, បង្កើនប្រសិទ្ធភាពសេដ្ឋកិច្ច, ព្រមទាំងពង្រឹងភាពប្រកួតប្រជែង និងជំរុញពិពិធកម្មសេដ្ឋកិច្ចកម្ពុជា និង (២) ការចាត់ទុកវិស័យឯកជនជាក្បាលម៉ាស៊ីននៃកំណើនសេដ្ឋកិច្ច ដោយទទួលស្គាល់ថាវិស័យឯកជនមានតួនាទីគន្លឹះក្នុងការជំរុញកំណើននិងការអភិវឌ្ឍសង្គម និងការបញ្ចូលបច្ចេកវិទ្យាទំនើបនិងនវានុវត្តភាព សំដៅបង្កើនប្រសិទ្ធភាពនិងសមត្ថភាពប្រកួតប្រជែងនៃសេដ្ឋកិច្ចជាតិ។

ក្នុងន័យនេះ រាជរដ្ឋាភិបាលបានខិតខំវិនិយោគយ៉ាងគំហុក និងប្រកបដោយវិចារណកម្មខ្ពស់លើការស្តារ, កសាង, និងអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធសាធារណៈ ដោយប្រើប្រាស់ប្រភពទុនហិរញ្ញប្បទានជាប្រពៃណី ផ្អែកលើលទ្ធភាពថវិកាជាតិដែលខ្លួនមាន ក៏ដូចជាប្រភពធនធានហិរញ្ញប្បទានដែលកៀរគរបានពីដៃគូអភិវឌ្ឍន៍នានា។ ទន្ទឹមនេះ ស្របគ្នានឹងកិច្ចខិតខំប្រឹងប្រែងកៀរគរការវិនិយោគនានា ទាំងការវិនិយោគផ្ទាល់ពីបរទេស និងទាំងការវិនិយោគផ្ទាល់ពីឯកជនក្នុងស្រុក កម្ពុជាក៏បានបន្តខិតខំជំរុញវិស័យឯកជនឱ្យចូលរួមជាមួយរាជរដ្ឋាភិបាល ក្នុងការវិនិយោគហេដ្ឋារចនាសម្ព័ន្ធសាធារណៈផងដែរ ដែលនាំមកនូវប្រភពទុនហិរញ្ញប្បទានបន្ថែម, ចំណេះដឹង-ចំណេះធ្វើ, ព្រមទាំងបច្ចេកវិទ្យាទំនើបដល់វិស័យសាធារណៈ ក្នុងការរៀបចំ និងគ្រប់គ្រងប្រតិបត្តិការគម្រោងវិនិយោគហេដ្ឋារចនាសម្ព័ន្ធសាធារណៈ ប្រកបដោយនវានុវត្តភាព និងកាន់តែមានប្រសិទ្ធិភាពខ្ពស់ជាងមុន ឆ្លើយតបបានគ្រប់គ្រាន់ទាំងបរិមាណ និងប្រសិទ្ធភាពចំពោះតម្រូវការប្រើប្រាស់របស់ប្រជាជន ស្របតាមចក្ខុវិស័យនៃគោលនយោបាយរបស់រាជរដ្ឋាភិបាល។

ក្នុងគោលដៅនេះ ច្បាប់ស្តីពីសម្បទាន ត្រូវបានប្រកាសឱ្យប្រើនៅឆ្នាំ២០០៧ ដែលមានគោលបំណងជំរុញ និងសម្រួលការអនុវត្តគម្រោងវិនិយោគហេដ្ឋារចនាសម្ព័ន្ធសាធារណៈ ហិរញ្ញប្បទានដោយផ្អែកឯកជន។ តែទោះជាយ៉ាងនេះក្តី ការរៀបចំ និងការគ្រប់គ្រងគម្រោងនៅមានភាពរប៉ាត់រប៉ាយ, ប្រើប្រាស់យន្តការចំពោះកិច្ច, និងគ្មានការវាយតម្លៃហានិភ័យហិរញ្ញវត្ថុនៃគម្រោង ដែលមិនអនុលោមតាមឧត្តមានុវត្តជាអន្តរជាតិ។

ក្នុងបរិការណ៍នៃដំណាក់កាលអភិវឌ្ឍន៍ថ្មី ដែលកម្ពុជាទទួលបាននូវឋានៈជាប្រទេសមានចំណូលមធ្យមកម្រិតទាប ហើយកំពុងឈានទៅជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងបន្តទៅជាប្រទេសមានចំណូលខ្ពស់នៅឆ្នាំ២០៥០ រាជរដ្ឋាភិបាល បានពិនិត្យឃើញថា គោលនយោបាយនៃការជំរុញការវិនិយោគសាធារណៈ កំពុងស្ថិតក្នុងស្ថានភាពទ្វេទិស គឺមានទាំងបញ្ហាប្រឈម និងទាំងកាលានុវត្តភាព។

បញ្ហាប្រឈមធំៗ ដែលកម្ពុជាជួបប្រទះ រួមមាន៖ (១) ភាពចាំបាច់ក្នុងការកំណត់ឡើងវិញនូវគោលដៅនៃការប្រើប្រាស់ហិរញ្ញប្បទានសហប្រតិបត្តិការ ដោយសារនិន្នាការថយចុះនៃហិរញ្ញប្បទានឥតសំណងលើសកលលោក និងការផ្លាស់ប្តូរគោលនយោបាយផ្តល់ហិរញ្ញប្បទានរបស់ដៃគូអភិវឌ្ឍន៍នីមួយៗ និង (២) ការធ្លាក់ចុះ និងបាត់បង់នូវឥណទានសម្បទានកម្រិតខ្ពស់ នាពេលខាងមុខ។

ស្របពេលជាមួយគ្នានេះ កាលានុវត្តភាពថ្មីៗរបស់កម្ពុជា រួមមាន៖ (១) ការងើបឡើងក្នុងសន្ទុះលឿនគួរឱ្យកត់សម្គាល់របស់វិស័យឯកជននៅកម្ពុជាជាងមួយទសវត្សរ៍ចុងក្រោយ និងការកើនឡើងនូវសំណើសុំវិនិយោគរបស់វិស័យឯកជន តាមទម្រង់ "**សាងសង់-អាជីវកម្ម-ផ្ទេរ**" ដែលជាទម្រង់មួយនៃយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន ដោយផ្តោតជាពិសេស ក្នុងវិស័យផ្លូវថ្នល់, ស្ពាន, និងថាមពល ជាដើម; និង (២) ការដាក់ចេញនូវយុទ្ធសាស្ត្រហិរញ្ញប្បទានថ្មីរបស់ដៃគូអភិវឌ្ឍន៍ធំៗក្នុងការប្រើប្រាស់យន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន សម្រាប់ហិរញ្ញប្បទានគម្រោងវិនិយោគសាធារណៈ និងបានត្រៀមខ្លួនជួយដល់ប្រទេសកំពុងអភិវឌ្ឍន៍ ក្នុងការរៀបចំយន្តការនេះ ទាំងក្របខ័ណ្ឌបច្ចេកទេស និងទាំងក្របខ័ណ្ឌហិរញ្ញវត្ថុ។

លើមូលដ្ឋាននេះ កម្ពុជាមិនអាចនៅតែប្រើប្រាស់ "**យន្តការចំពោះកិច្ច**" ក្នុងការរៀបចំ និងគ្រប់គ្រងការអនុវត្តគម្រោងវិនិយោគសាធារណៈ តាមយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន បន្តទៀតបានទេ ដូច្នេះ រាជរដ្ឋាភិបាលត្រូវរៀបចំ "**ឯកសារគោលនយោបាយស្តីពីការអភិវឌ្ឍយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន សម្រាប់គ្រប់គ្រងគម្រោងវិនិយោគសាធារណៈ ២០១៦-២០២០**" ដើម្បីរួមចំណែកបង្កើតឡើងនូវបរិស្ថានអំណោយផលសម្រាប់បន្តជំរុញ និងលើកទឹកចិត្តការចូលរួមរបស់វិស័យឯកជននិងស្ថាប័នហិរញ្ញវត្ថុ ក្នុងការវិនិយោគលើវិស័យហេដ្ឋារចនាសម្ព័ន្ធសាធារណៈ, វិស័យបង្កើនផលិតភាពសេដ្ឋកិច្ច, និងវិស័យអាទិភាពផ្សេងទៀត ប្រកបដោយភាពគ្រប់ជ្រុងជ្រោយ និងស្របតាមឧត្តមានុវត្តជាអន្តរជាតិ សំដៅពង្រឹងភាពប្រកួតប្រជែងនៃសេដ្ឋកិច្ចកម្ពុជា ក្នុងតំបន់ និងសកលលោក។

ដើម្បីសម្រេចគោលបំណង, គោលដៅ, និងចក្ខុវិស័យវែងឆ្ងាយរបស់រាជរដ្ឋាភិបាល ឯកសារគោលនយោបាយនេះ សម្រេចដាក់ចេញនូវវិធានការគោលនយោបាយ និងការកំណត់យន្តការស្ថាប័ន ព្រមទាំងរៀបចំយន្តការគាំទ្រហិរញ្ញវត្ថុចាំបាច់នានា សំដៅរៀបចំឡើងនូវប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈ តាមយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន ប្រកបដោយប្រសិទ្ធភាព, ស័ក្តិសិទ្ធិភាព, តម្លាភាព, គណនេយ្យភាព, សង្គតិភាព, និងភាពប្រទាក់ក្រឡាគ្នា ឱ្យបាននៅមុនដំណាច់ឆ្នាំ២០២០។

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្នុងឋានៈជាសេនាធិការរបស់រាជរដ្ឋាភិបាល ត្រូវទទួលបន្ទុកជាស្ថាប័ននាំមុខក្នុងការសម្របសម្រួលលើការអនុវត្តរាល់វិធានការដែលបានដាក់ចេញក្នុងឯកសារគោលនយោបាយនេះ ឱ្យមានប្រសិទ្ធភាពខ្ពស់។ ទន្ទឹមនេះ រាជរដ្ឋាភិបាល សង្ឃឹមយ៉ាងមុតមាំថា គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ នឹងចូលរួមផ្តល់កិច្ចសហប្រតិបត្តិការពេញលេញ ប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ ក្នុងការអនុវត្ត **"ឯកសារគោលនយោបាយស្តីពីការអភិវឌ្ឍយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន សម្រាប់គ្រប់គ្រងគម្រោងវិនិយោគសាធារណៈ ២០១៦-២០២០"** ឱ្យបានជោគជ័យ សំដៅចូលរួមលើកស្ទួយការអភិវឌ្ឍសេដ្ឋកិច្ច-សង្គម លើដំណើរនៃមាគ៌ារបស់កម្ពុជាឆ្ពោះទៅកាន់វឌ្ឍនភាព, វិបុលភាព, និងភាពចុំចើ្ររុងរឿង។

រាជធានីភ្នំពេញ, ថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

# បុព្វកថា

## **បុព្វកថា**

គោរពតាមការចាត់តាំងដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានដឹកនាំរៀបចំ "**ឯកសារគោលនយោបាយស្តីពីការអភិវឌ្ឍយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន សម្រាប់គ្រប់គ្រងគម្រោងវិនិយោគសាធារណៈ ២០១៦-២០២០**" ដែលមានគោលបំណងជំរុញ និងលើកទឹកចិត្តការវិនិយោគរបស់វិស័យឯកជន និងស្ថាប័នហិរញ្ញវត្ថុ លើការស្តារ និងអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធសាធារណៈ ប្រកបដោយនវានុវត្តភាព និងប្រសិទ្ធភាពខ្ពស់ សំដៅរួមចំណែកទ្រទ្រង់ចីរភាពនៃកំណើនសេដ្ឋកិច្ចរយៈពេលវែង និងបង្កើនសមត្ថភាពប្រកួតប្រជែងរបស់កម្ពុជា។

ឯកសារគោលនយោបាយនេះ ត្រូវបានម្ចាស់ការរៀបចំដោយក្រុមមន្ត្រីបច្ចេកទេសជាន់ខ្ពស់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោយបានសិក្សាដកពិសោធន៍ពីប្រទេសមួយចំនួនលើពិភពលោកដែលទទួលបានជោគជ័យក្នុងការរៀបចំនិងអនុវត្តគម្រោងវិនិយោគសាធាណៈ តាមយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន ជាពិសេស ប្រទេសក្នុងទ្វីបអាស៊ី ព្រមទាំងធាតុចូលដែលទទួលបានពីការចូលរួមក្នុងវេទិកាពិគ្រោះយោបល់ថ្នាក់តំបន់ និងពីដៃគូអភិវឌ្ឍន៍មួយចំនួន។ ទន្ទឹមនេះ ការរៀបចំ "**ឯកសារគោលនយោបាយស្តីពីការអភិវឌ្ឍយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន សម្រាប់គ្រប់គ្រងគម្រោងវិនិយោគសាធារណៈ ២០១៦-២០២០**" ត្រូវបានធ្វើឡើងដោយផ្អែកលើបរិការណ៍បច្ចុប្បន្ននៃកម្ពុជាផង និងក៏អនុលោមតាមការអនុវត្តនិងនិន្នាការជាសកលផងដែរ។

"**ឯកសារគោលនយោបាយស្តីពីការអភិវឌ្ឍយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន សម្រាប់គ្រប់គ្រងគម្រោងវិនិយោគសាធារណៈ ២០១៦-២០២០**" គឺជាផែនទីបង្ហាញផ្លូវដ៏មានសារៈសំខាន់សម្រាប់ឈានទៅសម្រេចបានតាមចក្ខុវិស័យរបស់រាជរដ្ឋាភិបាល ដែលបានកំណត់យកមុនដំណាច់ឆ្នាំ២០២០ ជាពេលវេលាគោលដែលរាជរដ្ឋាភិបាលត្រូវបង្កើត និងអនុវត្តឱ្យបានពេញលេញ នូវប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈ តាមយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន ប្រកបដោយភាពប្រទាក់ក្រឡានិងគ្រប់ជ្រុងជ្រោយ ស្របតាមឧត្តមានុវត្តជាអន្តរជាតិ ព្រមទាំងរួមចំណែកពង្រឹងការគ្រប់គ្រងហានិភ័យនៃកាតព្វកិច្ចបំណុលជាយថាហេតុ ដែលកើតចេញពីការអនុវត្តគម្រោងវិនិយោគសាធារណៈតាមយន្តការនេះ។ ដើម្បីសម្រេចបានតាមចក្ខុវិស័យនេះ យុទ្ធសាស្ត្រគន្លឹះរបស់រាជរដ្ឋាភិបាល គឺការដាក់ចេញនូវវិធានការគោលនយោបាយរយៈពេលខ្លីដែលផ្តល់ផលភ្លាមៗ និងវិធានការរយៈពេលមធ្យមនិងវែង ដើម្បីរួមចំណែកបង្កើតឡើងនូវបរិស្ថានអំណោយផលសម្រាប់បន្តលើកកម្ពស់ការចូលរួមរបស់វិស័យឯកជន និងស្ថាប័នហិរញ្ញវត្ថុ ក្នុងការវិនិយោគសាធារណៈ ដោយចាប់ផ្តើមពីការពិនិត្យ និងកែសម្រួលក្របខ័ណ្ឌគតិយុត្ត, កំណត់យន្តការស្ថាប័ន, ដាក់ឱ្យអនុវត្តនីតិវិធីគ្រប់គ្រងប្រតិបត្តិការ, និងបង្កើត

យន្តការគាំទ្រហិរញ្ញវត្ថុតាមការចាំបាច់ ព្រមទាំងកំណត់ច្បាស់លាស់នូវវិស័យអាទិភាពវិនិយោគសាធារណៈតាមយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន ស្របតាមបរិការណ៍វិវឌ្ឍនាការរបស់កម្ពុជា។

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្នុងឋានៈជាសេនាធិការរបស់រាជរដ្ឋាភិបាល ប្តេជ្ញាខិតខំសម្រេចឱ្យបាននូវប្រសិទ្ធភាព, វិវឌ្ឍនភាព, និងសង្គតិភាពនៃការអនុវត្តវិធានការជាយុទ្ធសាស្ត្រដែលបានដាក់ចេញក្នុងឯកសារគោលនយោបាយនេះ និងស្នើសុំការចូលរួមផ្តល់កិច្ចសហប្រតិបត្តិការពេញលេញពីសំណាក់ក្រសួង ស្ថាប័នពាក់ព័ន្ធរបស់រាជរដ្ឋាភិបាល ដើម្បីឈានទៅសម្រេចឱ្យបានជោគជ័យនូវការបង្កើតប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈតាមយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន ស្របតាមចក្ខុវិស័យវែងឆ្ងាយរបស់រាជរដ្ឋាភិបាល។

រាជធានីភ្នំពេញ, ថ្ងៃទី[illegible] ខែ[illegible] ឆ្នាំ២០១៦

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**និងជាប្រធានគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន**

# ឯកសារគោលនយោបាយ
# ស្តីពី
# ការអភិវឌ្ឍយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន សម្រាប់គ្រប់គ្រងគម្រោងវិនិយោគសាធារណៈ
# ២០១៦-២០២០

## មាតិកា


ទំព័រ

១-សេចក្តីផ្តើម................................................................................................................... ១

២-ចក្ខុវិស័យ................................................................................................................... ៣

៣-គោលបំណង និងគោលដៅ................................................................................................ ៣

៤-និយមន័យ និងទម្រង់ទូទាត់នៃយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន .............................................. ៤

៥-បរិការណ៍បច្ចុប្បន្ននៃយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន........................................................ ៥

៥-១-បរិការណ៍សកល.......................................................................................................... ៥

៥-១-១-និន្នាការសកល.................................................................................................... ៥

៥-១-២-ការអនុវត្តជាសកល.............................................................................................. ៥

៥-២-បរិការណ៍កម្ពុជា.......................................................................................................... ៧

៥-២-១-ក្របខ័ណ្ឌគោលនយោបាយ ក្របខ័ណ្ឌគតិយុត្ត និងយន្តការស្ថាប័ន.................................... ៧

៥-២-២-បញ្ហាប្រឈម និងកាលានុវត្តភាព............................................................................ ៩

៦-យុទ្ធសាស្ត្រ................................................................................................................. ១២

៦-១-វិធានការគោលនយោបាយបន្ទាន់ចំពោះមុខ ..................................................................... ១២

៦-២-វិធានការគោលនយោបាយរយៈពេលមធ្យម និងវែង............................................................ ១៤

៧-ផែនការសកម្មភាពស្តីពីការអភិវឌ្ឍយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន ...................................... ១៥

៨-ការតាមដានត្រួតពិនិត្យ និងការវាយតម្លៃការអនុវត្តវិធានការគោលនយោបាយ ................................ ១៩

៩-សេចក្តីសន្និដ្ឋាន.............................................................................................................. ២០

ឧបសម្ព័ន្ធ÷ ផែនការអភិវឌ្ឍន៍សមត្ថភាពស្ថាប័ន និងធនធានមនុស្សសម្រាប់ការគ្រប់គ្រងវិនិយោគ សាធារណៈ តាមយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន

**១-សេចក្តីផ្តើម**

ក្នុងរយៈកាលជាងពីរទសវត្សរ៍ចុងក្រោយនេះ កម្ពុជាសម្រេចបាននូវស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងកំណើនសេដ្ឋកិច្ចខ្ពស់ ជាមធ្យមក្នុងកម្រិត ៧,៧ ភាគរយ ក្នុងមួយឆ្នាំ ហើយផលិតផលសរុបក្នុងស្រុក សម្រាប់ប្រជាជនម្នាក់ៗ បានកើនឡើងប្រមាណប្រាំមួយដង គឺពីប្រមាណជាង ២០០ ដុល្លារអាមេរិក នៅឆ្នាំ១៩៩២ ដល់ ១ ២២៨ ដុល្លារអាមេរិក នៅឆ្នាំ២០១៥។ ទន្ទឹមនេះ អត្រាភាពក្រីក្របានធ្លាក់ចុះពីប្រមាណ ៥០ ភាគរយ ក្នុងឆ្នាំ១៩៩២ មកត្រឹមរង្វង់ ១៦ ភាគរយ ក្នុងឆ្នាំ២០១៥។ ការសម្រេចបាននូវសមិទ្ធផលដ៏ធំធេងទាំងនេះ ពិតជាមិនអាចកាត់ផ្តាច់បានពីការរួមចំណែកដ៏សំខាន់ពីការវិនិយោគរបស់វិស័យឯកជន, ការវិនិយោគផ្ទាល់ពីបរទេស, និងជាពិសេស ការវិនិយោគសាធារណៈរបស់រដ្ឋលើវិស័យហេដ្ឋារចនាសម្ព័ន្ធរូបវន្ត។

ក្នុងន័យនេះ រាជរដ្ឋាភិបាលបានខិតខំវិនិយោគយ៉ាងគំហុក និងប្រកបដោយវិចារណកម្មខ្ពស់ លើហេដ្ឋារចនាសម្ព័ន្ធសាធារណៈ ដោយប្រើប្រាស់ប្រភពទុនហិរញ្ញប្បទានជាប្រពៃណី ផ្អែកលើលទ្ធភាពថវិកាជាតិដែលខ្លួនមាន និងក៏ដូចជាប្រភពធនធានហិរញ្ញប្បទានដែលកៀរគរបានពីដៃគូអភិវឌ្ឍន៍នានា។ បើទោះជាយ៉ាងនេះក្តី ក៏នៅតែមិនទាន់ឆ្លើយតបបានគ្រប់គ្រាន់ទាំងបរិមាណនិងប្រសិទ្ធភាពចំពោះតម្រូវការប្រើប្រាស់របស់ប្រជាជន ក៏ដូចជាប្រភពធនធានហិរញ្ញប្បទានដែលកៀរគរបានពីដៃគូអភិវឌ្ឍន៍នានានៅឡើយ ដែលតម្រូវឱ្យកម្ពុជានៅតែត្រូវបន្តខិតខំកៀរគរការចូលរួមវិនិយោគពីវិស័យឯកជនលើហេដ្ឋារចនាសម្ព័ន្ធសាធារណៈបន្ថែមទៀត។ ការចូលរួមវិនិយោគពីវិស័យឯកជន មិនត្រឹមតែនាំមកនូវប្រភពទុនហិរញ្ញប្បទានបន្ថែមប៉ុណ្ណោះទេ តែថែមទាំងនាំមកនូវចំណេះដឹង-ចំណេះធ្វើ ព្រមទាំងបច្ចេកវិទ្យាទំនើបដល់វិស័យសាធារណៈ ក្នុងការរៀបចំនិងគ្រប់គ្រងប្រតិបត្តិការគម្រោងវិនិយោគហេដ្ឋារចនាសម្ព័ន្ធសាធារណៈប្រកបដោយនវានុវត្តភាព និងកាន់តែមានប្រសិទ្ធិភាពខ្ពស់ជាងមុនទៀតផង។

ចាប់តាំងពីនីតិកាលទី១ នៃរដ្ឋសភា រាជរដ្ឋាភិបាលបានខិតខំជំរុញ និងលើកទឹកចិត្តវិស័យឯកជនក្នុងការចូលរួមវិនិយោគហេដ្ឋារចនាសម្ព័ន្ធសាធារណៈ ដោយបានដាក់ចេញនូវឧបករណ៍គោលនយោបាយ, បទដ្ឋានគតិយុត្ត, និងវិធានការចាំបាច់នានាក្នុងការពង្រឹងភាពជាដៃគូជាមួយតួអង្គអភិវឌ្ឍន៍ទាំងអស់ឱ្យកាន់តែទូលំទូលាយ ជាក់ស្តែងដូចបានកំណត់ក្នុង÷ (១) យុទ្ធសាស្ត្រត្រីកោណ និងផែនការអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គមកិច្ចលើកទី១ (១៩៩៦-២០០០) និងលើកទី២ (២០០១-២០០៥), (២) យុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី១ និង ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០០៦-២០១០, (៣) យុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី២ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម ២០០៩-២០១៣, និង (៤) យុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី៣ និង ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៤-២០១៨។

ក្នុងក្របខ័ណ្ឌនេះ ច្បាប់ស្តីពីសម្បទាន ក៏ត្រូវបានប្រកាសឱ្យប្រើនៅឆ្នាំ២០០៧ ដែលមានគោលបំណង ជំរុញ និងសម្រួលការអនុវត្តគម្រោងវិនិយោគហេដ្ឋារចនាសម្ព័ន្ធសាធារណៈ ហិរញ្ញប្បទានដោយផ្នែកឯកជន។ បើទោះបីជាយ៉ាងនេះក្តី អនុក្រឹត្យ, លិខិតបទដ្ឋានគតិយុត្ត, និងនីតិវិធីគ្រប់គ្រងប្រតិបត្តិការសម្រាប់គាំទ្រការអនុវត្ត ច្បាប់នេះ នៅមិនទាន់ត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្តនៅឡើយ ជាហេតុធ្វើឱ្យយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន នៅតែមិនទាន់អាចអនុវត្តបានទាំងស្រុងនិងមានប្រសិទ្ធភាពពេញលេញ ពោលគឺ កន្លងមក ការរៀបចំ, ការចរចា, និងការគ្រប់គ្រងការអនុវត្តគម្រោង មានភាពរប៉ាត់រប៉ាយ, ប្រើប្រាស់យន្តការចំពោះកិច្ច, និងគ្មានការវាយ តម្លៃហានិភ័យហិរញ្ញវត្ថុនៃគម្រោង ដែលមិនទាន់អនុលោមទាំងស្រុងតាមឧត្តមានុវត្តជាអន្តរជាតិនៅឡើយ។

ក្នុងដំណាក់កាលអភិវឌ្ឍន៍ថ្មីនេះ កម្ពុជាត្រូវប្រឈមចំពោះបញ្ហាធំៗ ចំនួន ០២ រួមមាន÷ (១) ភាពចាំបាច់ ក្នុងការកំណត់ឡើងវិញនូវគោលដៅនៃការប្រើប្រាស់ហិរញ្ញប្បទានសហប្រតិបត្តិការ ដោយសារនិន្នាការថយចុះ នៃហិរញ្ញប្បទានឥតសំណងលើសកលលោក និងការផ្លាស់ប្តូរគោលនយោបាយផ្តល់ហិរញ្ញប្បទានរបស់ដៃគូ អភិវឌ្ឍន៍នីមួយៗ និង (២) ការធ្លាក់ចុះនៃឥណទានសម្បទានកម្រិតខ្ពស់ នៅពេលដែលកម្ពុជាទទួលបាននូវឋានៈ ជាប្រទេសមានចំណូលមធ្យមកម្រិតទាប។

ស្របពេលជាមួយគ្នានេះ ចំពោះមុខស្ថានភាពដែលប្រទេសកំពុងអភិវឌ្ឍន៍ភាគច្រើននៅលើសកលលោក កំពុងរងសម្ពាធនៃការកើនឡើងនូវបន្ទុកសេវាបំណុលសាធារណៈ ដែលបណ្តាលមកពីការប្រើប្រាស់យ៉ាងច្រើន លើសលប់នូវឥណទានពីប្រភពនានាសម្រាប់ការវិនិយោគសាធារណៈ ដៃគូអភិវឌ្ឍន៍ពហុភាគីធំៗបានប្រកាស ដាក់ចេញនូវយុទ្ធសាស្ត្រហិរញ្ញប្បទានថ្មី គឺការប្រើប្រាស់ "**យន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន សម្រាប់ គម្រោងវិនិយោគសាធារណៈ**" និងបានត្រៀមខ្លួនជួយដល់ប្រទេសកំពុងអភិវឌ្ឍន៍ក្នុងការរៀបចំយន្តការនេះ ទាំង ក្របខ័ណ្ឌបច្ចេកទេស និងទាំងក្របខ័ណ្ឌហិរញ្ញវត្ថុ។

បើទោះជាស្ថានភាពបំណុលសាធារណៈរបស់កម្ពុជាមានចីរភាពក្នុងរយៈពេលវែង ខុសពីស្ថានភាពបំណុល សាធារណៈរបស់ប្រទេសកំពុងអភិវឌ្ឍន៍ និងប្រទេសអភិវឌ្ឍន៍មួយចំនួនក្តី ផ្អែកតាមចក្ខុវិស័យរបស់រាជរដ្ឋាភិបាល កម្ពុជានៅតែត្រូវការយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន សម្រាប់គ្រប់គ្រងការវិនិយោគសាធារណៈ។ លើមូលដ្ឋាន នេះ រាជរដ្ឋាភិបាលសម្រេចរៀបចំ និងដាក់ឱ្យអនុវត្តនូវ "**ឯកសារគោលនយោបាយស្តីពីការអភិវឌ្ឍយន្តការភាព ជាដៃគូរវាងរដ្ឋ និងឯកជន សម្រាប់គ្រប់គ្រងគម្រោងវិនិយោគសាធារណៈ ២០១៦-២០២០**" ប្រកបដោយភាពគ្រប់ ជ្រុងជ្រោយនិងស្របតាមឧត្តមានុវត្តជាអន្តរជាតិ ដែលនឹងជួយកែលម្អនិងលើកកម្ពស់បរិស្ថានអំណោយផល សម្រាប់បន្តជំរុញការចូលរួមរបស់វិស័យឯកជនលើការវិនិយោគសាធារណៈ, បង្កើតជាប្រភពហិរញ្ញប្បទានថ្មី សម្រាប់បំពេញបន្ថែមលើប្រភពទុនវិនិយោគសាធារណៈជាប្រពៃណីរបស់រដ្ឋ, និងរួមចំណែកដល់ការពង្រឹងការ គ្រប់គ្រងកាតព្វកិច្ចបំណុលជាយថាហេតុរបស់កម្ពុជា។ ឯកសារគោលនយោបាយនេះ ដាក់ចេញនូវវិធានការ គោលនយោបាយ ដែលជាផែនទីបង្ហាញផ្លូវស្តីពីការអភិវឌ្ឍយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន និងកំណត់

វិស័យអាទិភាពនៃគម្រោងវិនិយោគសាធារណៈតាមយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន រួមមាន÷ (១) វិធានការគោលនយោបាយបន្ទាន់ចំពោះមុខ និង (២) វិធានការគោលនយោបាយរយៈពេលមធ្យម និងវែង។ ទន្ទឹមនេះ ឯកសារគោលនយោបាយនេះ ក៏បានដាក់ចេញផងដែរនូវផែនការអភិវឌ្ឍសមត្ថភាពស្ថាប័ន និងធនធានមនុស្ស សម្រាប់ពង្រឹងសមត្ថភាពមន្ត្រីរាជការ ពាក់ព័ន្ធនឹងវដ្តនៃគម្រោងវិនិយោគសាធារណៈតាមយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន។

## ២-ចក្ខុវិស័យ

នៅមុនដំណាច់ឆ្នាំ២០២០ រាជរដ្ឋាភិបាលត្រូវបង្កើត និងអនុវត្តឱ្យបានពេញលេញ នូវប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈតាមយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន ប្រកបដោយភាពប្រទាក់ក្រឡានិងគ្រប់ជ្រុងជ្រោយស្របតាមឧត្តមានុវត្តជាអន្តរជាតិ ព្រមទាំងរួមចំណែកពង្រឹងការគ្រប់គ្រងហានិភ័យនៃកាតព្វកិច្ចបំណុលជាយថាហេតុ ដែលកើតចេញពីការអនុវត្តគម្រោងវិនិយោគសាធារណៈតាមយន្តការនេះ។ ការសម្រេចបាននូវចក្ខុវិស័យនេះ នឹងមិនត្រឹមតែគៀរគរបាននូវហិរញ្ញប្បទានពីវិស័យឯកជន និងស្ថាប័នហិរញ្ញវត្ថុពាក់ព័ន្ធ បន្ថែមលើប្រភពទុនហិរញ្ញប្បទានជាប្រពៃណីប៉ុណ្ណោះទេ តែថែមទាំងនាំមកជាមួយនូវបច្ចេកវិទ្យាទំនើប និងនវានុវត្តភាព ដើម្បីបង្កើនប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ និងសមត្ថភាពប្រកួតប្រជែងនៃសេដ្ឋកិច្ចជាតិ ផងដែរ។

## ៣-គោលបំណង និងគោលដៅ

ឯកសារគោលនយោបាយនេះ មានគោលបំណងជំរុញ និងលើកទឹកចិត្តការវិនិយោគរបស់វិស័យឯកជន និងស្ថាប័នហិរញ្ញវត្ថុ ក្នុងការចូលរួមស្តារ, កសាង, ជួសជុល, ប្រតិបត្តិការ, និងថែទាំហេដ្ឋារចនាសម្ព័ន្ធសាធារណៈ ព្រមទាំងវិស័យបង្កើនផលិតភាពសេដ្ឋកិច្ចផ្សេងទៀត ប្រកបដោយនវានុវត្តភាព និងប្រសិទ្ធភាពខ្ពស់ ស្របតាមឧត្តមានុវត្តជាអន្តរជាតិ សំដៅរួមចំណែកទ្រទ្រង់ចីរភាពនៃកំណើនសេដ្ឋកិច្ចរយៈពេលវែង និងបង្កើនសមត្ថភាពប្រកួតប្រជែងរបស់កម្ពុជា ក្នុងបរិការណ៍នៃសមាហរណកម្មសេដ្ឋកិច្ចតំបន់ និងសកលលោក។

ដើម្បីសម្រេចគោលបំណងខាងលើ តាមរយៈឯកសារគោលនយោបាយនេះ រាជរដ្ឋាភិបាលមានគោលដៅដាក់ចេញនូវយុទ្ធសាស្ត្រ, កំណត់យន្តការស្ថាប័ន, និងបង្កើតយន្តការគាំទ្រហិរញ្ញវត្ថុ សម្រាប់រយៈពេលខ្លី មធ្យម និងវែង សំដៅរៀបចំប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈ តាមយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន ប្រកបដោយប្រសិទ្ធភាព, ស័ក្តិសិទ្ធិភាព, តម្លាភាព, គណនេយ្យភាព, សង្គតិភាព, និងភាពប្រទាក់ក្រឡាគ្នា ព្រមទាំងរួមចំណែកពង្រឹងការគ្រប់គ្រងហានិភ័យនៃកាតព្វកិច្ចបំណុលជាយថាហេតុ ដែលកើតចេញពីការអនុវត្តគម្រោងវិនិយោគសាធារណៈ តាមយន្តការនេះ។

**៤-និយមន័យ និងទម្រង់ទូទាត់នៃយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន**

ភាពជាដៃគូរវាងរដ្ឋ និងឯកជន សំដៅដល់កិច្ចព្រមព្រៀងវិនិយោគរវាងរដ្ឋ ជាមួយដៃគូឯកជនមួយឬច្រើន ក្នុងការស្ថាបនា, កសាង, ជួសជុល, ថែទាំ, និង/ឬគ្រប់គ្រងប្រតិបត្តិការហេដ្ឋារចនាសម្ព័ន្ធសាធារណៈ ឬ វិស័យបង្កើនផលិតភាពសេដ្ឋកិច្ចផ្សេងទៀត ឬ ក្នុងការផ្តល់សេវាសាធារណៈ ក្នុងរយៈពេលជាកំណត់ ដែលភាគីឯកជនត្រូវដាក់ទុនវិនិយោគ ហើយទទួលរ៉ាប់រងហានិភ័យ និងផលប្រយោជន៍ តាមការកំណត់ក្នុងកិច្ចសន្យាសម្បទាន។

ការវិនិយោគសាធារណៈតាមយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន ត្រូវបានទូទាត់សងវិញតាម ០៣ ទម្រង់ទូទាត់ដូចខាងក្រោម÷

- **ការទូទាត់ផ្អែកលើផលចំណូល (Revenue-based Payment)÷** ជាទម្រង់ដែលអនុញ្ញាតឱ្យដៃគូឯកជន ប្រមូលចំណូលពីអ្នកប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធសាធារណៈ និង/ឬ ពីអ្នកទទួលសេវាសាធារណៈ ដែលកើតចេញពីគម្រោង។ ទម្រង់នេះ អាចអនុវត្តបានចំពោះគម្រោងវិនិយោគសាធារណៈទាំងឡាយណាដែលមានផលិតភាពសេដ្ឋកិច្ចខ្ពស់ និងមានលទ្ធភាពប្រមូលចំណូលពីអ្នកប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធសាធារណៈ និង/ឬ ពីអ្នកទទួលសេវាសាធារណៈ។
- **ការទូទាត់ផ្អែកលើថវិកាជាតិ (Availability-based Payment)÷** ជាទម្រង់ដែលរដ្ឋត្រូវទូទាត់ថ្លៃវិនិយោគ និង/ឬ កម្រៃសេវាពាក់ព័ន្ធ ជូនដៃគូឯកជនដែលវិនិយោគលើការស្ថាបនា, សាងសង់, ជួសជុល, ធ្វើប្រតិបត្តិការ, និង/ឬ ថែទាំហេដ្ឋារចនាសម្ព័ន្ធសាធារណៈ ឬផ្តល់សេវាសាធារណៈ។ ទម្រង់នេះ អាចអនុវត្តបានចំពោះករណី÷ (១) រដ្ឋជាអ្នកប្រើប្រាស់ ឬ ជាអ្នកទិញសេវាកម្មដោយផ្ទាល់ ឬ (២) គម្រោងវិនិយោគសាធារណៈមានលក្ខណៈសង្គមកិច្ច ដែលពុំមានលទ្ធភាពប្រមូលចំណូលពីអ្នកប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធសាធារណៈ និង/ឬ អ្នកទទួលសេវាសាធារណៈ។
- **ការទូទាត់តាមវិធីចម្រុះ (Hybrid Payment) ÷** ជាទម្រង់បានមកពីការផ្សំគ្នារវាងការទូទាត់ផ្អែកលើផលចំណូល និងការទូទាត់ផ្អែកលើថវិកាជាតិ។

Unofficial Translation

**Kingdom of Cambodia**

**Nation Religion King**

♦♦∞♦♦

**Royal Government of Cambodia**

# Policy Paper
# on
# Public-Private Partnerships
# For Public Investment Project Management
# 2016 – 2020

**Prepared by: Ministry of Economy and Finance**

Unofficial Translation

**PREFACE**

The Royal Government of Cambodia has successfully implemented its Triangular Strategy and Rectangular Strategy phase 1 and 2. In the fifth legislature of the National Assembly, the Royal Government has furthered laid out the Rectangular Strategy phase 3 around its central theme of growth, employment, equity and efficiency. These strategic documents affirm the government's mission, commitment, and genuine efforts in assuring sustainable development and poverty reduction which respond to the people's wills by cohesively identifying: (1) public infrastructure investments as priority to support sustainability of long-term economic growth, increase economic effectiveness, enhance competitiveness, and accelerate Cambodian economic diversification, and (2) private sector as a driving force for economic growth by recognizing that private sector plays a key role in accelerating growth and social development as well as in bringing about modern technology and innovation aiming to increase the effectiveness and competiveness of the economy.

In this regard, the Royal Government has invested tremendously with high consciousness on reconstructing, building and developing public infrastructure by utilizing traditional sources of funding from national budget and other funding sources mobilized from development partners. Meanwhile, as Cambodia is mobilizing investments from both Foreign Direct Investments and domestic investments, it also continues to encourage private sector to join the Royal Government in public infrastructure investments. Private sector involvement will bring about additional sources of funding, knowledge, knowhow, and modern technology to the public sector which allows the sector to develop and manage the operation of public infrastructure investment projects in a more innovative and effective manner to respond to increasing needs of the people which align with the government's policies and vision.

With this objective, the Law on Concession was promulgated in 2007 aiming to promote and facilitate the implementation of public infrastructure investment projects being financed by private sector. Nonetheless, project development and management are still disorganized using ad-hoc mechanism without analyzing project financial risks, which are inconsistent with international standards.

In the context of new development stage where Cambodia is becoming a lower-middle income country, with the prospect of reaching the status of upper-middle-income country in 2030, and high-income country in 2050, the Royal Government views that the policy on promoting public investment is facing both challenges and opportunities.

The major challenges Cambodia faces include: (1) the necessity to re-determine the target for utilizing cooperative financing fund due to global tendency of declined grants and changing

financing policy of each development partner, and (2) the declining and losing of concessional loans in the near future.

At the same time, new opportunities for Cambodia include: (1) a remarkable upsurge of private sector in Cambodia in the last decade and increased investment proposals for **"Build-Operate-Transfer"**, a form of Public-Private Partnerships (PPPs), which specifically focus on roads, bridges, and energy, etc., and (2) major development partners have embarked on new financing strategy by utilizing PPPs as a mean to finance public investment projects and are ready to provide both technical and financial supports to develop PPPs in developing countries.

Accordingly, Cambodia cannot continue using **"Ad-hoc mechanism"** in developing and managing public investment projects, thus the Royal Government is preparing the **"Policy Paper on Public-Private Partnerships for Public Investment Project Management, 2016 – 2020"** that will create an enabling environment to continue to promote and encourage private sector and financial institutions involvement in public infrastructure investments, economic productivity enhancement sectors, and other priority sectors in a comprehensive manner and in accordance with international standards, which in turn strengthen Cambodia's economic competitiveness regionally and globally.

To achieve the objectives, goal, and long-term vision of the Royal Government, this Policy Paper is to set out policy measures, identify institutional mechanism and other necessary financial support mechanism to develop an effective, efficient, transparent, accountable, consistent and interlinked system to manage public investment through PPPs by the end of 2020.

As an arm of the Royal Government, the Ministry of Economy and Finance is assigned as a lead institution to effectively facilitate the implementation of all measures set out in this Policy Paper. Together with this, the Royal Government strongly hopes that all line ministries/institutions involved will provide full collaboration with high responsibility to successfully implement this **"Policy Paper on Public-Private Partnerships for Public Investment Project Management, 2016 – 2020"** in order to contribute to promoting socio-economic development on a path towards achieving progressivity, prosperity and richness.

Phnom Penh, 22 June 2016

Prime Minister

Signed and Sealed

Samdech Akka Moha Sena Padei Techo **HUN SEN**

Unofficial Translation

# FOREWARD

Unofficial Translation

**FOREWARD**

With reference to the assignment made by Samdech Akka Moha Sena Padei Techo **HUN SEN**, Prime Minister of the Kingdom of Cambodia, the Ministry of Economy and Finance is taking lead to prepare the **"Policy Paper on Public-Private Partnerships for Public Investment Project Management, 2016 – 2020"** aiming to promote and encourage participation from private sector and financial institutions in reconstructing and developing public infrastructure in an innovative and effective manner to contribute to supporting sustainability of long-term economic growth and increasing Cambodia's competitiveness.

This Policy Paper has been prepared by senior level technical team of the Ministry of Economy and Finance with inputs obtained from regional consultative forums as well as from some development partners. In particular, the inputs from experience learned from a number of countries, especially those in Asia, that have been successful in the development and implementation of public investment projects using PPPs. Meanwhile, the preparation of **"Policy Paper on Public-Private Partnerships for Public Investment Project Management, 2016 – 2020"** was done based on current context of Cambodia and in accordance with global practices and trends.

**The "Policy Paper on Public-Private Partnerships for Public Investment Project Management, 2016 – 2020"** is a key roadmap to achieve the vision of the Royal Government set to obtain before 2020. By then, the Royal Government has to fully establish and implement a comprehensive and interlinked system to manage public investment through PPPs in consistent with international standards. The system shall also contribute to enhancing risk management of contingent liabilities that may arise from the implementation of public investment projects through PPPs. To achieve this vision, the Royal Government's key strategy is to set out immediate policy measures, that could instantaneously achieve the outputs, and medium-term and long-term measures, which are to create enabling environment for promoting the participation of private sector and financial institutions in public investments. The tasks shall start with reviewing and revising legal framework, identifying institutional mechanism, setting out operational management procedures, establishing necessary financial support mechanism, and clearly defining public investment priority sectors to be implemented through PPPs in conformity to the progressive context of Cambodia.

As an arm of the Royal Government, the Ministry of Economy and Finance is committed to making every effort to achieve effective, progressive, and consistent implementation of strategic measures set forth in this Policy Paper. The Ministry also requests for full collaboration from all line ministries/institutions involved in order to successfully establish a public investment management system using PPPs in accordance with the government's long-term vision.

Unofficial Translation

Phnom Penh, 22 June 2016

Senior Minister

Minister of Economy and Finance

And Chairman of Economic and Finance Policy Committee

Signed and Sealed

**Aun Pornmoniroth, Ph.D.**

Unofficial Translation

# Policy Paper
# on
# Public-Private Partnerships
# For Public Investment Project Management
# 2016 – 2020

Unofficial Translation

TABLE OF CONTENTS


1. INTRODUCTION ..... 1

2. VISION ..... 2

3. OBJECTIVES AND GOALS ..... 3

4. DEFINITION AND TYPES OF PUBLIC-PRIVATE PARTNERSHIPS ..... 3

5. CURRENT CONTEXT OF PUBLIC-PRIVATE PARTNERSHIPS ..... 4

5.1 Global Context ..... 4

*5.1.1 Global Trend* ..... 4

*5.1.2 Global Practice* ..... 4

5.2 Cambodian Context ..... 6

*5.2.1 Policy and Legal Framework and Institutional Mechanism* ..... 6

*5.2.2 Challenges and Opportunities* ..... 7

6. STRATEGY ..... 10

6.1 Immediate Policy Measures ..... 10

6.2 Medium-Term and Long-Term Policy Measures ..... 12

7. ACTION PLAN ON THE DEVELOPMENT OF PUBLIC-PRIVATE PARTNERSHIPS ..... 13

8. MONITORING AND EVALUATION OF THE IMPLEMENTATION OF POLICY MEASURES ..... 16

9. CONCLUSION ..... 16

**Annex: Institutional Capacity and Human Resource Development Plan for Management of Public Investment Projects through Public-Private Partnerships**

Unofficial Translation

# 1. Introduction

During the last two decades, Cambodia has achieved macroeconomic stability and high economic growth averaging at 7.7% per year. Cambodian Gross Domestic Product (GDP) per capita has increased six times from approximately USD 200 in 1992 to USD 1,228 in 2015. Meanwhile, poverty rate has dropped from approximately 50% in 1992 to around 16% in 2015. Such achievements were not separable from the contribution of private sector investments, foreign direct investments, and in particular public investments on physical infrastructure sector.

In this regard, the Royal Government of Cambodia has invested tremendously with high consciousness in public infrastructure by utilizing traditional financing funded from national budget, and financial resources mobilized from development partners. Despite such investment, Cambodia has not been able to sufficiently respond to the needs of its people, calling for further efforts in mobilizing private sector participation in investing on public infrastructure. The involvement of private sector investment brings about not only complementary source of financing, but also knowledge, knowhow, and modern technology to public sector to develop and manage the operation of public infrastructure investment projects in a more innovative and effective manner.

Since the first mandate of the National Assembly, the Royal Government has promoted and encouraged private sector to participate in public infrastructure investments by setting out policy and legal instruments and other necessary measures to strengthen and widen partnerships with all partners as reiterated in: (1) Triangle Strategy, 1st Socio-Economic Development Plan (SEDP I, 1996-2000), and 2nd Socio-Economic Development Plan (SEDP II, 2001-2005); (2) Rectangular Strategy phase 1 and National Strategic Development Plan, 2006–2010; (3) Rectangular Strategy phase 2 and Updated National Strategic Development Plan, 2009 – 2013; and (4) Rectangular Strategy phase 3 and National Strategic Development Plan, 2014–2018.

In this context, the Law on Concession was promulgated in 2007 aiming to promote and facilitate the implementation of public infrastructure investment projects being financed by private sector. Nonetheless, since sub-decrees, legal instruments and operational management procedures to support the implementation of the Law have not been developed and enforced, Public-Private Partnerships (PPPs) have not been fully and effectively implemented. In essence, by way of utilizing ad-hoc mechanism without analyzing project financial risks, until now the preparation, negotiation, and implementation of the projects are disorganized and not yet fully consistent with international standards.

During this new development stage, Cambodia faces two major challenges: (1) the necessity to re-determine the target for utilization of cooperative financing due to tendency of

declined grants globally and changing financing policy of each development partner; and (2) the decline of loans with high concessionality when Cambodia becomes a lower-middle income country.

While most developing countries are under pressure from increased public debt service burden resulting from excessive use of credit from various sources for finance public investments, major multilateral development partners have embarked on a new form of financing strategy through the use of **"Public-Private Partnerships for Public Investment Projects"** and are ready to provide both technical and financial supports to developing countries to develop PPPs.

Even though Cambodia's public debt status is sustainable in the long-run unlike those of some developing and developed countries, based on the government's long-term vision, Cambodia is still in need of PPPs for the management of public investment. Based on this, the Royal Government decided to develop and put into effect the **"Policy Paper on Public-Private Partnerships for Public Investment Project Management, 2016 – 2020"**, in a comprehensive manner and in accordance with international standards, aiming to improve and enhance an enabling environment to continue to promote participation from private sector in public investment. This will also serve as a new financing source to complement the traditional public investment sources and contribute to strengthening contingent liabilities management in Cambodia. This Policy Paper sets out policy measures that serve as PPP roadmap and identify priority sectors for public investment projects through PPPs, those include: (1) immediate policy measures, and (2) medium-term and long-term policy measures. The Policy Paper has also laid out the institutional capacity and human resource development plan to strengthen capacity of government officials whose line of work linked to project cycle using PPPs.

## 2. Vision

By the end of 2020, the Royal Government has to fully develop and implement a comprehensive and interlinked system in accordance with the international standards in order to manage public investment through PPPs. The system shall also contribute to enhancing the management of risks associated with contingent liabilities that may arise from the implementation of public investment projects through PPPs. Achieving this vision will bring about not only additional sources of funding from private sector and financial institutions which complement traditional sources, but also modern technology and innovation to increase the effectiveness of public service provisions as well as the economy's competitiveness.

## 3. Objectives and Goals

The objectives of this Policy Paper are to promote and encourage investments by private sector and financial institutions to contribute to restoring, building, operating and maintaining public infrastructure and other economic productivity enhancement sectors in an innovative and effective manner and in accordance with international standards. This will support long-term sustainable economic growth and increase Cambodia's competitiveness in the context of regional and global economic integration.

To achieve the above objectives through this Policy Paper, the goals of the Royal Government are to set out strategies, identify institutional mechanism, and establish financial support mechanism for the short-term, medium-term, and long-term timeframes in order to develop an effective, efficient, transparent, accountable, consistent and interlinked system to manage public investment through PPPs. The system shall also contribute to enhancing the management of contingent liabilities associated risks that may arise from the implementation of public investment projects through PPPs.

## 4. Definition and Types of Public-Private Partnerships

Public-Private Partnerships (PPPs) refer to an investment agreement between the state and one or more private partners to restore, build, repair, maintain and/or manage the operation of public infrastructure or other economic productivity enhancement sectors or to provide public services within a certain period of time by which the private party shall invest, bear risks and receive benefits in accordance with the provisions stipulated in the concession contract.

PPPs shall be repaid in three forms as follows:

- **Revenue-based Payment:** is a form of payment that allows the private partner to collect revenue from public infrastructure and/or public service users. This form of payment is used for public investment projects with high economic productivity where it is possible to collect revenue from the public infrastructure and/or public service users.

- **Availability-based Payment:** is a form of payment where the state shall pay the investment cost and/or relevant service fees to the private partner who has invested in the restoration, construction, repair, operation, and/or maintenance of public infrastructure or provided public services. This form of payment is used in the following cases: (1) the state is the direct user or purchaser of the services, or (2) public investment projects of social nature without the possibilities of collecting revenue from the public infrastructure and/or public service users.



តទៅរាជកិច្ចលេខ ១២

រក្សាសិទ្ធ និងបោះពុម្ពដោយ
អគ្គនាយកដ្ឋានរាជកិច្ច និងសេវាកុំព្យូទ័រ
នៃ ទីស្តីការគណៈរដ្ឋមន្ត្រី